ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ទ្រឹស្ដីរូប៊ីខុន និង ដំណើរឆ្ពោះទៅរកការសង្គ្រោះជាតិថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

◆ បណ្ណាល័យហោអដ្ឋិធាតុ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨៩ ខែមករា ឆ្នាំ២០២៤

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៩ ខែមករា ឆ្នាំ២០២៤



កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមចូលមកដល់ស្ពានក្បាលថ្នល់ ក្រុងភ្នំពេញ ដើម្បីវាយបណ្តេញខ្មែរក្រហម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាតិកា

## សំបុត្រ


- ទ្រឹស្តីរូបីខុន និង ដំណើរឆ្ពោះទៅរកការសង្គ្រោះជាតិថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ................ ១


## ផ្នែកឯកសារ


- ប្រវត្តិរូបរបស់ ស៊ុំ សាមឿន ហៅ រំ កម្មករដែ ...៨


## ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- បណ្ណាល័យហោអដ្ឋិធាតុ ......................... ១១
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកជើងព្រៃ និងស្រុកព្រៃឈររំពុកឡើងវិញពី..... ១៣
- មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបណ្តុះបណ្តាល... ១៧
- អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ដើម្បីចុះធ្វើការងារ. ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរ........ ១៧
- មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវគ្គបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ........២១
- មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវគ្គបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជា ............... ២៥
- សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលដង្វារ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី...... ២៩
- សិស្សវិទ្យាល័យមេសាង ចូលរួមបណ្តុះ ...... ៣៣
- រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកស្រីសន្ធរ និងស្រុកជើងព្រៃ........... ៤០
- វគ្គណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម ស្តីពីប្រវត្តិសាស្ត្រកម្ពុជា.. ៥០


## ផ្នែកវេទិកាពិភាក្សាសាធារណៈ


- វេទិកាផ្សព្វផ្សាយអប់រំពីការថែទាំសុខភាពឲ្យប្រសើរឡើងជាងមុនដល់ជនពិការក្នុងស្រុកអន្លង់វែង.. ៥៤
- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពី ប្រវត្តិសាស្ត្រកម្ពុជា...... ៥៨
- កម្មវិធីពិនិត្យ និងអប់រំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកត្រពាំង........ ៦១
- សិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុនសែន សង្កើប ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពី........ ៦៥
- មជ្ឈមណ្ឌលផ្សះផ្សារវាលវែងចុះពិនិត្យសុខភាពបឋមជូន ព្រះសង្ឃ ជនពិការ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ........... ៦៩


## ផ្នែកស្រាវជ្រាវរកគ្រួសារ


- ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម........... ៧២


**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ព្រុំ ដល្លា, មីន សាណាស់, សាំង ចាន់ធូ, សួត វិចិត្រ, វី ស៊ីថា, ផេង ពង្សរ៉ាស៊ី, ង៉ាន់ វីន, ឡុង ដានី, មេក វិន, ទូច វណ្ណេត, សួត វិចិត្រ និងលី ដេវីត
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ទ្រឹស្តីរូប៊ីខុន និង ដំណើរឆ្ពោះទៅរកការសង្គ្រោះជាតិថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

*ព្រុំ ផល្លា*



*សម្តេច ហ៊ុន សែន បានដឹកនាំព្រះសង្ឃ និងប្រជាជនចូលរួមការប្រារព្ធពិធីមីទិញបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅលើទឹកដីស្រុកស្នួល ខេត្តក្រចេះ ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

**អ្វីទៅជា រូប៊ីខុន** (Rubicon)?

ជូលីស សេសារ (Julius Caesar) ឃើញភាពអយុត្តិធម៌ដែលកើតឡើងដោយសារសង្គ្រាម ធ្វើឲ្យគាត់មានការតស៊ូជាបន្តបន្ទាប់រហូតក្លាយជាសមាជិកព្រឹទ្ធសភារបស់ទីក្រុងរ៉ូម (Rome) ។ បន្ទាប់មកបានក្លាយជាមេទ័ពប្រយុទ្ធក្នុងសង្គ្រាម ហ្គូល (Gaul) ដើម្បីអាជីពនយោបាយរបស់គាត់។ គាត់បានទទួលជ័យជម្នះសង្គ្រាមនៅ ហ្គូល (Gaul) ហើយបានគ្រប់គ្រងនៅទីនោះ។ បន្ទាប់ពីទទួលបានជ័យជម្នះ គាត់មានបំណងត្រឡប់ទៅរ៉ូមវិញ។ នៅថ្ងៃទី១០ ខែ មករា ឆ្នាំ៤៩ មុនគ្រិស្តសករាជ នៅត្រើយខាង ហ្គូល (Gaul) នៃទន្លេ រូប៊ីខុន (Rubicon), ជូលីស សេសារ (Julius Caesar) និងទាហានរបស់គាត់បានឈប់នៅទីនោះ ហើយបានថ្លឹងថ្លែងនូវជម្រើស ។

តាមពិត រូប៊ីខុន គ្រាន់តែធំជាងអូរបន្តិចតែប៉ុណ្ណោះ។ ទន្លេនេះមានសារសំខាន់សម្រាប់ទីក្រុងរ៉ូម បើគិតពីទីតាំង ព្រោះវាជាព្រំដែនរវាង អ៊ីតាលី និង ស៊ីសាល់ភីន ហ្គូល (Cisalpin Gaul) ដែលជាតំបន់នៅ

ខាងត្បូងជួរភ្នំអាល់(Alps) ដែលគ្រប់គ្រងដោយជូលីស សេសារ។ ការឆ្លងកាត់តំបន់នេះ នឹងនាំឲ្យមានផលអាក្រក់ធ្ងន់ធ្ងរ។ តាមច្បាប់សាធារណៈរដ្ឋរ៉ូម៉ាំង អ្នកគ្រប់គ្រងតំបន់ណាមួយដែលដឹកនាំទ័ពត្រឡប់ចូលទៅក្រុងរ៉ូមវិញ នឹងត្រូវបានចាត់ទុកជាសត្រូវ ជាជនក្បត់ និង ជាការបង្កសង្គ្រាម ។

ដោយ ខ្លាចឥទ្ធិពលរបស់ សេសារ កើនឡើងជាលំដាប់ ព្រឹទ្ធសភា បានបញ្ជាឲ្យ សេសារ ទម្លាក់អាវុធ។ ប៉ុន្តែ សេសារ មិនស្តាប់បង្គាប់ព្រឹទ្ធសភា ហើយគាត់បានដឹងយ៉ាងច្បាស់អំពីលទ្ធផលនៃការមិនចុះចូលរបស់គាត់។ គាត់ដឹងយ៉ាងច្បាស់ថា សង្គ្រាមស៊ីវិលនឹងកើតឡើងរវាងគាត់ និង រ៉ូម ដែលដឹកនាំដោយសត្រូវដែលខ្លាំងបំផុត និងជាអ្នកធ្លាប់ជាសម្ព័ន្ធមិត្តរបស់គាត់។ ប្រសិនបើគាត់ជ្រើសរើសការឆ្លងកាត់រូប៊ីខុន វានឹងមិនអាចត្រឡប់ក្រោយវិញបានឡើយ ។

បន្ទាប់ពីឈ្នះសង្គ្រាមស៊ីវិលនេះ សេសារ បានឡើងកាន់អំណាចផ្តាច់ការ និងបានចាប់ផ្តើមនូវសករាជចក្រពត្តិរ៉ូម។

ការឆ្លងកាត់ទន្លេរូប៊ីខុនរបស់ សេសារ បានក្លាយជាទ្រឹស្តីមួយសម្រាប់ប្រើប្រាស់នៅក្នុងសង្គ្រាម និងទំនាក់ទំនងអន្តរជាតិ។ ទ្រឹស្តី រូប៊ីខុន គឺជាទ្រឹស្តីមួយក្នុងចំណោមទ្រឹស្តីមួយចំនួនដែលយោធាអាមេរិកយកមកប្រើប្រាស់។ ទ្រឹស្តីនេះត្រូវបានដាក់បញ្ចូលនៅក្នុងវិទ្យាសាស្ត្រយោធាបង្រៀននៅសាកលវិទ្យាល័យ និងដាក់ចូលជាក្រិត្យក្រមរបស់យោធា។ គោលបំណងក្នុងការសិក្សាអំពីទ្រឹស្តីនេះ គឺដើម្បីយល់ឲ្យបានច្រើនអំពីបំណងរបស់សត្រូវ និងដើម្បីជៀសវាងនូវសកម្មភាពបង្កហេតុណាមួយ ដោយមិនបង្កការឆ្លើយតបមួយដែលនាំដល់ចំណុចមិនអាចត្រឡប់ក្រោយបាន ។

## ដំណាក់កាលធ្វើសកម្មភាព

អ្នកសិក្សាបានវិភាគទៅលើទម្រង់សកម្មភាពនៃទ្រឹស្តី រូប៊ីខុន ដែលព្យាយាមឆ្លើយទៅនឹងសំណួរដូចខាងក្រោម៖

- តើមនុស្សជ្រើសរើសគោលដៅរបស់ខ្លួនដោយរបៀបណា?
- តើគាត់រៀបចំគម្រោងយ៉ាងដូចម្តេចដើម្បីសម្រេចគោលដៅនោះ?
- តើគាត់អនុវត្តគម្រោងនេះដោយរបៀបណា?
- តើគាត់វាយតម្លៃទៅលើការប្រឹងប្រែងរបស់ខ្លួនដោយរបៀបណាដើម្បីទៅដល់គោលដៅរបស់ខ្លួន?

## តាមទ្រឹស្តី រូប៊ីខុន នៅក្នុងដំណាក់កាលសកម្មភាពផាក់ផងទៅនឹងដំណាក់កាលនៃ ៖

១. ការគ្រោងទុកជាមុននូវលទ្ធផលជាសក្តានុពលដែលវិជ្ជមាន និង អវិជ្ជមានទៅលើបំណងប្រាថ្នា និង ជម្រើសសកម្មភាព ( ដំណាក់កាលនៅមុនពេលសម្រេចចិត្ត)។

២. ដំណាក់កាលនៃការរៀបចំផែនការយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីទៅដល់គោលដៅដែលត្រូវបានសម្រេចនៅចុងបញ្ចប់នៃដំណាក់កាលសម្រេចចិត្ត ( ដំណាក់កាលនៅមុនសកម្មភាព ឬ នៅបន្ទាប់ពីការសម្រេចចិត្ត)។

៣. ដំណាក់កាលអនុម័តយកយុទ្ធសាស្ត្រដែលបានរៀបចំ ( ដំណាក់កាលសកម្មភាព)

៤. និង ចុងបញ្ចប់គឺជាដំណាក់កាលនៃការវាយតម្លៃលទ្ធផលនៃសកម្មភាព ( ដំណាក់កាលបន្ទាប់ពីសកម្មភាព) ។

## I. ដំណាក់កាលនៅមុនពេលសម្រេចចិត្ត

នៅដំណាក់កាលដំបូងនេះ គឺត្រូវកំណត់ ដោយការគ្រោងទុក។ បុគ្គលមួយរូបត្រូវតែសម្រេចថាតើបំណងប្រាថ្នាមួយណាក្នុងចំណោមបំណងប្រាថ្នាជាច្រើនរបស់ខ្លួន ដែលត្រូវតែបន្ត។ ការជំរុញទឹកចិត្ត (motivation) របស់បុគ្គលមួយរូបត្រូវបានសន្មត់ ដើម្បីបង្កើតនូវការប៉ងប្រាថ្នាដ៏ពិតប្រាកដ។ ក៏ប៉ុន្តែដោយសារតែសេចក្តីត្រូវការ និង កត្តាជំរុញលើកទឹកចិត្តរបស់

មនុស្សបង្កើតនូវបំណងប្រាថ្នាច្រើនជាងអ្វីដែលអាចសម្រេចយក ហើយដែលអាចធ្វើទៅបាន ដូចនេះហើយ គាត់ត្រូវតែបង្ខំចិត្តជ្រើសរើសយកក្នុងចំណោមនោះ ហើយប្ដេជ្ញាធ្វើដោយខ្លួនឯងសម្រាប់គោលដៅដែលត្រូវបានសម្រេចយកៗ ជាចុងបញ្ចប់គេត្រូវតែធ្វើការថ្លឹងថ្លែងលើចំណង់ និងការអាចធ្វើទៅបានទៅលើការប៉ងប្រាថ្នាជាច្រើនរបស់ខ្លួនៗ គោលបំណងនៃដំណាក់កាលដំបូងនេះគឺដើម្បីសម្រេចថា តើបំណងប្រាថ្នាណាមួយរបស់ខ្លួនដែលត្រូវចាប់យក ដោយផ្អែកទៅលើប្រភេទដែលអាចធ្វើទៅបាន (មានន័យថា សេចក្ដីសង្ឃឹមទៅលើលទ្ធផលនៃសកម្មភាពដែលចង់បាននោះទទួលបានជោគជ័យ) និងភាពគាប់ចិត្ត (មានន័យថា តម្លៃនៃលទ្ធផលរបស់សកម្មភាពដែលត្រូវបានរំពឹងទុក) ។

ដំណើរការនៃគម្រោងនេះបង្កើននូវការប្ដេជ្ញាទៅនឹងគោលដៅជាក់លាក់មួយ នៅក្នុងការឆ្លងកាត់រូប៊ីខុនរវាងការប៉ងប្រាថ្នា និងគោលដៅ។ ការផ្លាស់ប្ដូរពីការប៉ងប្រាថ្នាទៅជាគោលដៅជាក់លាក់បង្កើតបានជាភាពរឹងមាំនៃការប្ដេជ្ញាដើម្បីបកប្រែគោលដៅទៅជាសកម្មភាព ។

## II. ***ដំណាក់កាលនៅមុនសកម្មភាព ឬ នៅបន្ទាប់ពីសម្រេចចិត្ត***

គោលដៅដែលទើបបង្កើតថ្មីមិនអាចអនុវត្តបានភ្លាមៗនោះទេ។ បុគ្គលជាដំបូងអាចនឹងបញ្ចប់សកម្មភាពផ្សេងៗសិន ឬក៏រង់ចាំដល់ឱកាសសមរម្យដើម្បីចាប់ផ្ដើមៗ ជាងនេះទៅទៀតនោះ ចេតនារបស់គោលដៅជាច្រើនបញ្ជាក់នូវស្ថានភាពគោលដៅ ដែលមិនអាចសម្រេចបានក្នុងពេលភ្លាមៗនោះទេ។ ហេតុដូចនេះហើយបុគ្គលនោះត្រូវបង្ខំឲ្យរង់ចាំដល់ឱកាសអំណោយផល ដើម្បីចាប់ផ្ដើមនៅមុនពេលរំកិលទៅដល់គោលដៅដែលត្រូវបានដាក់ចេញៗ បើតាមទ្រឹស្ដីរូប៊ីខុន អ្នកដែលស្ថិតនៅក្នុងដំណាក់កាលរង់ចាំនេះ គឺស្ថិតនៅក្នុងជំហានទីពីរនៃសកម្មភាព គឺដំណាក់កាលឆន្ទៈនៅមុនពេលសកម្មភាព (ឬក៏ដំណាក់កាលនៅបន្ទាប់ពីការសម្រេចចិត្ត)។ ពាក្យថា "ឆន្ទៈ" នៅទីនេះបញ្ជាក់ថា ការជំរុញទឹកចិត្តទៅលើគម្រោងរៀបចំនៃគោលបំណងសកម្មភាពជាសក្ដានុពល (ការប៉ងប្រាថ្នា) ត្រូវបានកំណត់យកដោយការឆ្លងកាត់រូប៊ីខុន ហើយថា បុគ្គលនោះត្រូវបានប្ដេជ្ញាដើម្បីសម្រេចបាននូវគោលដៅដែលបានជ្រើសរើសៗ អាស្រ័យហេតុនេះហើយនៅក្នុងដំណាក់កាលនេះ វាលែងជាបញ្ហាចំពោះការជ្រើសរើសគោលដៅដែលគាប់ចិត្ត និងអាចធ្វើទៅបានទៀតហើយ ក៏ប៉ុន្តែវាជាដំណាក់កាលកំណត់ថា ត្រូវធ្វើយ៉ាងម៉េចដើម្បីឲ្យសម្រេចបាននូវគោលដៅដែលត្រូវបានជ្រើសរើស ។

ជាទូទៅ នៅក្នុងដំណាក់កាលមុនសកម្មភាព បុគ្គលនឹងបង្កើតផែនការជាក់លាក់ថា នៅពេលណា នៅទីណា និង វិធីដែលគោលដៅត្រូវបានអនុវត្តៗ ផែនការទាំងនេះហៅថា ការអនុវត្តគោលបំណងៗ អនុលោមតាមគំរូ និងទ្រឹស្ដី រូប៊ីខុន នៃការគ្រប់គ្រងសកម្មភាពគោលបំណង, ការអនុវត្តគោលបំណងទាក់ទងនឹងការផ្ដួចផ្ដើម, ការប្រព្រឹត្ត, និងការកំណត់យកសកម្មភាព គឺជួយក្នុងការជម្នះនូវផលលំបាកដែលត្រូវបានគិតទុកជាមុន នៅក្នុងខណៈដែលខ្លួនដំណើរ-ការទៅកាន់គោលដៅ (ឧទាហរណ៍ ចាប់ផ្ដើមធ្វើ និងតាមដានមើល)។ តាមរយៈការឆ្លងកាត់ រូប៊ីខុន មនុស្សប្ដេជ្ញាដោយខ្លួនឯងក្នុងការអនុវត្តយកនូវគោលដៅដែលត្រូវបានជ្រើសរើសៗ កម្លាំងនៃការប្ដេជ្ញានេះ ដែលត្រូវបានគំរូរូប៊ីខុន កំណត់ថាជា កម្លាំងឆន្ទៈ ដែលវាជាបន្ទាត់មុខងារជាវិជ្ជមាននៃកម្លាំងរបស់និន្នាការជំរុញចិត្ត (មានន័យថា ជាភាពគាប់ចិត្ត និងភាពអាចធ្វើទៅបាននៃគោលដៅដែលត្រូវបានជ្រើសរើស) ។

ជាសង្ខេបអាចនិយាយបានថា ដំណាក់កាលនៅមុនសកម្មភាព បុគ្គលគ្រប់រូបគិតដល់វិធីដ៏ល្អបំផុតដើម្បីបន្តទៅដល់គោលដៅដែលខ្លួនបានសម្រេចយកនៅចុងបញ្ចប់នៅដំណាក់កាលមុនការសម្រេចចិត្តៗ ពួកគេជ្រើសរើសយុទ្ធសាស្ត្រ និង បង្កើតផែនការដែលអាចសម្រេចបាននូវគោលដៅដែលចង់បាន ។

## III. ដំណាក់កាលសកម្មភាព

ការផ្តួចផ្តើមនូវសកម្មភាពបានរៀបចំឡើងដើម្បីបន្តផែនការដែលបានបង្កើតឡើងនៅក្នុងដំណាក់កាលនៅមុនសកម្មភាព គឺជាសញ្ញានៃការផ្លាស់ប្តូរទៅជាដំណាក់កាលសកម្មភាព។ នៅក្នុងដំណាក់កាលនេះ ការខិតខំរបស់បុគ្គលត្រូវផ្តោតទៅលើសកម្មភាពដែលទាក់ទងដោយផ្ទាល់ទៅនឹងគោលដៅ និងធ្វើរហូតដល់ទទួលបានជោគជ័យ។ កិច្ចខិតខំប្រឹងប្រែងត្រូវបានសម្រួលយ៉ាងល្អបំផុតដោយការបន្តដោយមិនប្រែប្រួលនៃគោលដៅ ដែលតម្រូវឲ្យមានការខិតខំប្រឹងប្រែងនៅក្នុងពេលដែលប្រឈមមុខនឹងសេចក្តីលំបាក និងបន្តសកម្មភាពឡើងវិញនៅពេលដែលសកម្មភាពត្រូវបានរំខាន។

## IV. ដំណាក់កាលបន្ទាប់ពីសកម្មភាព

នៅដំណាក់កាលនេះ បុគ្គលវាយតម្លៃលើលទ្ធផលនៃសកម្មភាពដែលសម្រេចបាន។ ប្រសិនបើពេញចិត្តនឹងលទ្ធផលសម្រេចបាន គេរក្សាទុកគោលដៅដែលកំណត់យកនៅចុងបញ្ចប់នៃដំណាក់កាលនៅមុនការសម្រេចចិត្ត។ ហើយប្រសិនបើខ្លួនមិនពេញចិត្តទៅនឹងលទ្ធផល គាត់នឹងបន្ថយកម្រិតសង្ឃឹមទុក ហើយរក្សាទុកគោលដៅនៅដដែល ឬក៏រក្សាទុកនូវកម្រិតសង្ឃឹមទុក ហើយបង្កើនការខិតខំប្រឹងប្រែងទៅទៀតដើម្បីសម្រេចបានគោលដៅជាទីគាប់ចិត្ត។

## ករណីដំណើរឆ្ពោះទៅសង្គ្រោះជាតិថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩

### ស្របទៅតាមនិយមន័យ

ការងើបបះបោរ និងផ្តាច់ខ្លួនដើម្បីការពារជីវិតខ្លួន និងដើម្បីសង្គ្រោះជាតិត្រូវបានមើលឃើញថា ជាដំណើរមិនអាចត្រឡប់ក្រោយបាន។ លទ្ធផលនៃការបះបោរនេះ ត្រូវបានទទួលស្គាល់ជាស្រេចថា ប្រសិនបើមិនងើបបះបោរដើម្បីការពារជីវិតខ្លួនឯង និងរំដោះប្រជាជនពីការកាប់សម្លាប់ដើម្បីកសាងប្រទេសទៅរកភាពប្រក្រតីដែលរស់នៅក្នុងសុខសន្តិភាពនោះទេ នោះខ្លួនក៏នឹងត្រូវបានចាប់ធ្វើទារុណកម្មសួរចម្លើយ និងសម្លាប់ចោលដោយគ្មានត្រាប្រណីពីខ្មែរក្រហមដែរ។ បញ្ហានៅត្រង់ថា តើត្រូវនៅរង់ចាំឲ្យគេចាប់យកទៅសម្លាប់ចោល ឬក៏ត្រូវងើបបះបោរ។ សេសារ ដឹងយ៉ាងច្បាស់ថា បើគាត់មិនឆ្លងទន្លេរូប៊ីខុន ក៏គាត់នៅតែនឹងត្រូវបានសម្លាប់ដោយរ៉ូមដែរ ហេតុដូចនេះហើយ គាត់ចាំបាច់ត្រូវតែធ្វើសង្គ្រាមជាមួយរ៉ូម។ និយាយដោយខ្លី គឺដើម្បីការពារជីវិតពីសត្រូវរបស់ខ្លួន។

## ការវិភាគព្រឹត្តិការណ៍ភ្ជាប់ទៅនឹងទ្រឹស្តីគ្រូខបានដកស្រង់ចេញពី ខ្សែភាពយន្តឯកសារដំណើរឆ្ពោះទៅរកការសង្គ្រោះជាតិថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩

### ដំណាក់កាលនៅមុនពេលសម្រេចចិត្ត

តាមគំរូរូប៊ីខុន នៃដំណាក់កាលពេលវេលា នៅដំណាក់កាលដំបូងនេះ គឺត្រូវកំណត់ ដោយការគ្រោងទុក ដែលកើតចេញមកពីការប៉ងប្រាថ្នា ដោយមានការជំរុញទឹកចិត្ត។ តើអ្វីទៅជាកត្តាជំរុញទឹកចិត្តដែលធ្វើឲ្យមានដំណើរឆ្ពោះទៅសង្គ្រោះជាតិ?

កត្តាជំរុញសំខាន់ជាងគេ គឺដោយសារមើលឃើញការកាប់សម្លាប់ប្រជាជន និងការប្រព្រឹត្តអំពើយង់ឃ្នងសាហាវព្រៃផ្សៃរបស់បក្សកុម្មុយនីស្តកម្ពុជាមកលើប្រជាជនខ្លួនឯង បើមិនស្លាប់ដោយសារការបោសសម្អាត ក៏ស្លាប់ដោយសារអត់អាហារ និងធ្វើការហួសកម្លាំង។

នៅឆ្នាំ១៩៧៧ ដោយឃើញប្រទេសស្ថិតនៅក្នុងភាពគ្រោះថ្នាក់ សម្តេច ហ៊ុន សែន មានជម្រើសទីមួយក្រោកឈរឡើងដើម្បីប្រយុទ្ធបះបោរប្រឆាំងនឹង ប៉ុល ពត។ តែបើក្រោកឈរឡើង ដើម្បីវាយយកស្រុកមេមត់ និង ស្នួល ដោយកម្លាំងប្រមាណ ២០០០នាក់ដើម្បីយកជាមូលដ្ឋាន នោះការតស៊ូដូចនេះនឹងមិនយូរជាង១ខែឡើយ ដែលនឹងស្លាប់ក្នុងថ្លុកឈាមដោយសារតែការបង្ក្រាបរបស់ ប៉ុល ពត។

តែនេះសម្តេច ហ៊ុន សែន បានទាយថា ជម្រើសនេះមិនអាចធ្វើទៅបានៗ ឯជម្រើសទីពីរ គឺត្រូវដកខ្លួនទៅប្រទេសវៀតណាមដើម្បីរកជំនួយនៅក្នុងការបង្កើតចលនាសង្គ្រោះជាតិ។ សម្តេច ហ៊ុន សែន ក៏នៅមានជម្រើសទីបី ទីបួនថែមទៀត តែវាសុទ្ធតែជម្រើសស្លាប់ទាំងអស់។ ជម្រើសទីបី កុំធ្វើអ្វីទាំងអស់ទុកឲ្យ ប៉ុល ពត ចាប់យកទៅសម្លាប់ និង ជម្រើសទីបួនគឺ ធ្វើអត្តឃាតខ្លួនឯង ។ ជម្រើសទីពីរនេះ (បំណងប្រាថ្នា = សង្គ្រោះជាតិ) មានភាពល្អប្រសើរជាងជម្រើសដទៃទៀត ដែលនេះវាស្របទៅនឹងទ្រឹស្តីរូប៊ីខុន ថាយើងត្រូវសម្រេចចាប់យកតែជម្រើសមួយក្នុងចំណោមជម្រើសជាច្រើន ដែលជម្រើសមួយនោះអាចធ្វើទៅបានដោយមានទំនុកចិត្ត។

មានសំណួរជាច្រើនបានលើកឡើងថា តើសម្តេច ហ៊ុន សែន ត្រូវស្លាប់ដោយជាន់មីននៅពេលឆ្លងព្រំដែន ឬក៏ត្រូវបានសម្លាប់ដោយទាហានព្រំដែនវៀតណាម ហើយថា តើវៀតណាមនឹងចាប់បញ្ជូនលោកមកកម្ពុជាវិញដែរឬទេ?

ដោយមានជម្រើសល្អតែមួយគត់ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ សម្តេច ហ៊ុន សែន បានសម្រេចចិត្តឆ្លងកាត់ព្រំដែន (ឆ្លងរូប៊ីខុន) ចូលប្រទេសវៀតណាម ដោយយកជីវិតជាដើមទុនក្នុងការតស៊ូរំដោះជាតិសង្គ្រោះប្រជាជនកម្ពុជា ។

## ដំណាក់កាលនៅមុនសកម្មភាព ឬនៅបន្ទាប់ពីការសម្រេចចិត្ត

តាមទ្រឹស្តីនៅពេលដែលឆ្លងកាត់ រូប៊ីខុន (ក្នុងករណីនេះឆ្លងកាត់ព្រំដែន) គោលដៅដែលទើបបង្កើតថ្មី មិនអាចអនុវត្តបានភ្លាមៗនោះទេ។ គឺត្រូវរង់ចាំឱកាសសមរម្យដើម្បីចាប់ផ្តើម។ គឺជាពេលដែលត្រូវជ្រើសរើសយុទ្ធសាស្ត្រ និង បង្កើតផែនការ ដែលអាចសម្រេចបាននូវគោលដៅដែលចង់បាន ។ នៅក្នុងដំណាក់កាលនេះ វាលែងជាបញ្ហាចំពោះការជ្រើសរើសគោលដៅដែលគាប់ចិត្ត និង អាចធ្វើទៅបានទៀតហើយ ក៏ប៉ុន្តែវាជាដំណាក់កាលកំណត់ថា ត្រូវធ្វើយ៉ាងម៉េចដើម្បីឲ្យសម្រេចបាននូវគោលដៅ (សង្គ្រោះជាតិ) ដែលត្រូវបានជ្រើសរើស ។

សម្តេច ហ៊ុន សែន នៅបន្ទាប់ពីសួរចម្លើយរួច គាត់បានជួបមេដឹកនាំវៀតណាមដើម្បីពន្យល់ពីស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា និង សុំជំនួយ (ផែនការ)។ តែសំណើលើកដំបូងត្រូវបានវៀតណាមច្រានចោល ដោយសារវៀតណាមគិតថា ខ្លួននឹងជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជា ។

ការវាយប្រហាររបស់ខ្មែរក្រហមទៅលើវៀតណាម ធ្វើឲ្យវៀតណាមផ្លាស់ប្តូរគោលជំហរក្នុងការផ្តល់ជំនួយជូនសម្តេច ហ៊ុន សែន ។ ដែលជាកត្តាធ្វើឲ្យផែនការរបស់លោកលេចចេញជារូបរាង។

វៀតណាម បានជួយឧបត្ថម្ភដោយមិនបានចាប់បញ្ជូនប្រជាជនកម្ពុជា ដែលឆ្លងកាត់ទៅប្រទេសវៀតណាម ដែលប្រការនេះធ្វើឲ្យសម្តេច ហ៊ុន សែន មានឱកាសចាប់ផ្តើមផែនការរបស់ខ្លួនក្នុងការកសាងកម្លាំងនៅក្នុងចំណោមជនភៀសខ្លួន តាមរយៈនយោបាយជ្រើសរើសមនុស្សឲ្យចូលរួមក្នុងកម្លាំងយោធា ត្រូវបានអនុវត្ត។ សម្តេច ហ៊ុន សែន បានកសាងបានមូលដ្ឋានជាច្រើន ហើយទទួលបានការគាំទ្រជាច្រើនដែលត្រូវបានរីកធំធាត់ ធ្វើឲ្យតួនាទីរបស់សម្តេចជាអគ្គមគ្គុទ្ទេសក៏កាន់តែច្បាស់ឡើង។ សម្តេច ហ៊ុន សែន ក្នុងពេលនេះក៏ទទួលស្គាល់ផងដែរថា រឿងបែបនេះមិនត្រូវប្រើពេលមួយថ្ងៃពីរថ្ងៃទេ គឺសម្តេចត្រូវសរសេររៀបចំដាក់ឈ្មោះកងទ័ព។

កម្លាំងចលករបន្ថែមទៀតនោះ គឺនៅដើមខែមេសា ឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំវៀតណាមសម្រេចចិត្តជួយគណៈដឹកនាំរបស់កម្ពុជាជាផ្លូវការ ក្នុងការកសាងកម្លាំងប្រដាប់អាវុធដើម្បីរំដោះជាតិ ដែលជាចម្លើយដែលសម្តេច ហ៊ុន សែន រង់ចាំជាច្រើនខែមកហើយ ។

នេះជារបត់មួយថ្មី ទោះជាជួបបញ្ហាលំបាកប៉ុនណាក្តីក៏ត្រូវតែប្រឈមដោះស្រាយ ដើម្បីប្រទេស និង ប្រជាជនកម្ពុជា។

ទីបញ្ចប់កងកម្លាំងប្រដាប់អាវុធដែលមានឈ្មោះថា កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា បានលេចចេញជាផ្លូវការនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ និងបង្កើតគណបញ្ជាការមានឈ្មោះថា ៥៧៨ នៅក្នុងខែឧសភា ឆ្នាំ១៩៧៨ ដែរ។ នៅក្នុងដំណាក់កាលនេះផែនការត្រូវបានសម្រេច។

## ដំណាក់កាលសកម្មភាព

សកម្មភាពត្រូវបានគិតចាប់តាំងពីពេលដែលធ្វើការស៊ើបការណ៍ចូលក្នុងតំបន់កាន់កាប់ដោយខ្មែរក្រហមនៅខែមីនា ឆ្នាំ១៩៧៨ និងការបង្កើតក្រុមចារកិច្ចចំនួន៧ ក្រុមដើម្បីចូលមកស្រុកខ្មែរដើម្បីស៊ើបការណ៍ ។

បន្ទាប់មកមានការទទួលដំណឹងដ៏រីករាយដោយមានការបះបោរឡើងនៅភូមិភាគបូព៌ា ដែលដឹកនាំដោយលោក ហេង សំរិន លោក ជា ស៊ីម ដែលបង្កលក្ខណៈឲ្យកងកម្លាំងសហការគ្នាដណ្តើមកាន់កាប់ស្រុកមេមត់ ស្រុកស្នួល និងបណ្តាឃុំភូមិមួយចំនួននៅជាប់ព្រំដែនជាមួយវៀតណាមតាំងពីខេត្តក្រចេះ កំពង់ចាម ព្រៃវែង និង ស្វាយរៀង ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៨ ។

នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ មេដឹកនាំនៃចលនាតស៊ូ៤ក្រុម ក្នុងចំណោម៥ ក្រុម បានជួបគ្នាដោយសារតែក្រុមឯកឧត្តម សាយ ភូថង និងសម្តេច ទៀ បាញ់ មិនអាចចូលរួមបានដោយត្រូវរក្សាសម្ងាត់ ព្រោះកម្លាំងកំពុងនៅបរទេស។ ក្នុងពេលនោះហើយដែលថ្នាក់ដឹកនាំមានទាំងសម្តេច ហេង សំរិន សម្តេច ជា ស៊ីម បានចូលរួមផងដែរដើម្បីរៀបចំកម្មវិធីនយោបាយរណសិរ្សមួយ ដែលមានឈ្មោះថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ឲ្យស្របទៅនឹងឈ្មោះ កងកម្លាំងប្រដាប់អាវុធសាមគ្គី សង្គ្រោះជាតិកម្ពុជា ដែលជាភាពងាយស្រួលដោយមិនបាច់ដូរឈ្មោះកងទ័ពទៅតាមឈ្មោះរណសិរ្ស។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សត្រូវបានប្រកាសជាផ្លូវការនៅលើទឹកដីរំដោះស្រុកស្នួល ខេត្តក្រចេះ ។

សម្តេច ហ៊ុន សែន បានលើកឡើងថា "តើមេមាន់កើតមុនកូនមាន់ ឬ កូនមាន់កើតមុនមេមាន់?" ដោយសារតែជាទូទៅអង្គការចាត់តាំងនយោបាយត្រូវកើតមុន ហើយកងកម្លាំងប្រដាប់អាវុធកើតក្រោយ។ នេះជាករណីពិសេសជាប្រវត្តិសាស្ត្រមួយសម្រាប់ចលនាជាប្រវត្តិសាស្ត្រនេះ ។

សម្តេច ហ៊ុន សែន មានការជឿជាក់ថា កម្ពុជានឹងអាចរំដោះនៅក្នុងរយៈពេល១ ឆ្នាំ ដែលនឹងត្រូវរំដោះនៅដើមឆ្នាំ១៩៧៩។ ជំនឿមុតមាំនេះដោយសារតែសម្តេចដឹងទឹកចិត្តប្រជាជនដោយពួកគេរង់ចាំតែមានអ្នកណាមកជួយ និងមានកម្លាំងមានឱកាស មានពេលវេលា នេះជាចំណុចដែលហ៊ានសន្និដ្ឋានថាអាចសង្គ្រោះលឿន។ ភាពជឿជាក់គឺនៅត្រង់ម្ខាងគឺសមត្ថភាពកងទ័ព ហើយម្ខាងទៀតរឿងកំហឹងឈឺចាប់របស់ប្រជាជន ដែលមិនអាចទុកឲ្យពួកនេះ (ខ្មែរក្រហម) នៅបានទេ ។

ការវាយសម្រុកដោយមានការគាំទ្រពីវៀតណាម ការរង់ចាំក្នុងការវាយចូលដើម្បីរំដោះប្រទេសកម្ពុជាបានមកដល់ ហើយសូម្បីតែសម្តេច ហ៊ុន សែន ក៏មានការភ្ញាក់ផ្អើលដែរ ដោយទទួលបានជ័យជម្នះយ៉ាងឆាប់រហ័សដោយរំដោះរាជធានីភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានបង្កើតឡើង ដែលមានសម្តេច ហេង សំរិន ជាប្រធាន សម្តេច ជា ស៊ីម ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសម្តេច ហ៊ុន សែន ជារដ្ឋមន្ត្រីក្រសួងការបរទេស។

## ដំណាក់កាលបន្ទាប់ពីសកម្មភាព

តាមទ្រឹស្តី រូប៊ីខុន ពេលនេះគឺជាពេលវេលាវាយតម្លៃទៅលើលទ្ធផលនៃសកម្មភាពដែលសម្រេចបាន។ បើទោះបីជារបបខ្មែរក្រហមត្រូវបានវាយផ្តួលរំលំក៏ដោយ ក៏រណសិរ្សមិនបានគ្រប់គ្រងប្រទេសបានពេញលេញនោះទេ ដោយសារតែសង្គ្រាមស៊ីវិលនៅតែបន្តនៅក្នុងប្រទេស ដែលប្រជាជននៅតែមានភាពភ័យខ្លាចចំពោះការវិល

ត្រឡប់មកវិញនៃការកាន់អំណាចរបស់របបឃោរឃៅ។ ប៉ុន្តែរឿងសំខាន់បំផុតនោះ គឺការសង្គ្រោះជាតិ ដែលមិនឲ្យមានការកាប់សម្លាប់របស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា។ ទ្រឹស្តីបានលើកឡើងថា "ប្រសិនបើខ្លួនមិនពេញចិត្តទៅនឹងលទ្ធផល បុគ្គលនឹងបន្តយកម្រិតសង្ឃឹមទុក ហើយរក្សាទុកគោលដៅនៅដដែល ឬក៏រក្សាទុកនូវកម្រិតសង្ឃឹមទុក ហើយបង្កើនការខិតខំប្រឹងប្រែងទៅទៀតដើម្បីសម្រេចបានគោលដៅជាទីគាប់ចិត្ត ។ នៅក្នុងលក្ខខណ្ឌបែបនេះ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានមើលឃើញថា ជ្រើសរើសនូវចំណុចចុងក្រោយគឺខិតខំប្រឹងប្រែងតទៅទៀតដើម្បីសម្រេចបានគោលដៅជាទីគាប់ចិត្ត។ គោលដៅជាទីគាប់ចិត្តគឺការបញ្ចប់សង្គ្រាម ដើម្បីកសាងសុខសន្តិភាពជានិរន្តរ៍។

សង្គ្រាមរំដោះប្រទេសពិតជាមានការលំបាក ដោយសារតែមានការបាត់បង់ជីវិត តែការបន្តគ្រប់គ្រងជ័យជម្នះនៅតែជាជំហានវែងឆ្ងាយដែលត្រូវតស៊ូយូរអង្វែងបន្ថែមទៀត។ នៅបន្ទាប់ពីជ័យជម្នះនេះ ប្រទេសកម្ពុជាបានប្រឈមនឹងសង្គ្រាមស៊ីវិលបន្តជាងមួយទសវត្សរ៍។ នៅពេលដែលឥទ្ធិពលសង្គ្រាមត្រជាក់ត្រូវបានថមថយ ការចរចាលើកិច្ចព្រមព្រៀងឈប់បាញ់ដើម្បីសន្តិភាពត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩១។ ប៉ុន្តែកិច្ចព្រមព្រៀងនេះមិនទទួលបាននូវសន្តិភាពពេញលេញនោះទេ ដោយសារការមិនគោរពតាមកិច្ចព្រមព្រៀងដោយភាគីខ្មែរក្រហម និងការអន្តរាគមន៍របស់អង្គការសហប្រជាជាតិមិនទទួលបានជោគជ័យដែលធ្វើឲ្យសង្គ្រាមផ្ទៃក្នុងនៅតែបន្ត។ នយោបាយឈ្នះ-ឈ្នះ ជាជម្រើសបន្ទាប់ដោយកម្ពុជាខ្លួនឯង ដោយផ្អែកលើបរិបទវប្បធម៌ និងប្រវត្តិសាស្ត្រ ដែលនាំឲ្យទទួលបាននូវសុខសន្តិភាពដែលឈានដល់ការអភិវឌ្ឍន៍ប្រទេស។ សមិទ្ធផលនៃនយោបាយឈ្នះ-ឈ្នះ គឺជាគោលដៅជាទីគាប់ចិត្តរបស់ទ្រឹស្តី រូប៊ីខុន ។



សម្តេច ហ៊ុន សែន សួរសុខទុក្ខប្រជាជនឃុំទន្លូង ដែលបានភៀសខ្លួនទៅរស់នៅតាមជំរំក្នុងស្រុកស្នួល ខេត្តក្រចេះ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិរូបរបស់ ស៊ុំ សាមឿន ហៅ រំ កម្មករផែកំពង់សោម

**មីន សាណាស់**



កំពង់ផែកំពង់សោម ក្នុងឆ្នាំ១៩៧៨។
(ហ្វុនណា បឺយស្ត្រម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស៊ុំ សាមឿន ហៅ រំ អាយុ២៦ឆ្នាំ (នៅឆ្នាំ១៩៧៧) មានស្រុកកំណើតនៅភូមិបឹងរៃ ឃុំបុស្សរីកែវ ស្រុកព្រែកប្រសប់ តំបន់៤២។ តាំងពីកុមារភាពរហូតដល់ធំដឹងក្តីខ្ញុំរស់នៅធ្វើស្រែចម្ការជាមួយឪពុកម្តាយរបស់ខ្ញុំ។ ដល់ខ្ញុំអាយុ១៨ឆ្នាំ ខ្ញុំក៏សម្រេចចិត្តទៅបួសជានេននៅក្នុងវត្តបឹងរៃ។ ខ្ញុំបួសបានរយៈ២វស្សាក៏សឹកមករកស៊ីធ្វើស្រែជាមួយឪពុកម្តាយនៅផ្ទះវិញ។

នៅចុងឆ្នាំ១៩៦៩ ឈ្មោះ ឃ្លាំង គឺជាជំទប់ឃុំបុស្សរីកែវ (ឆ្នាំ១៩៧០ រត់ទៅភ្នំពេញ) និង ឈ្មោះ ឆាយ គឺជាជំទប់ឃុំបុស្សរីកែវ (ឆ្នាំ១៩៧១ រត់ទៅភ្នំពេញ) បានអប់រំខ្ញុំឲ្យស្អប់ខ្មែរក្រហម ដោយលើកពីចំណុចឃោរឃៅ ការកាប់សម្លាប់ប្រជារាស្ត្រ និងអប់រំពីប្រាក់ខែរបស់គិញ និងចាត់តាំងខ្ញុំឲ្យទទួលភារកិច្ចជាគិញយកការណ៍ពីតំបន់ខ្មែរក្រហម និងកសាងកម្លាំងគិញ។ ខ្ញុំកសាងបានកម្លាំងដំបូងឈ្មោះ ជ្រូក អតីតជាអ្នកធ្លាប់បួស។ ក្រោយឈ្មោះ ជ្រូក ចូលធ្វើជាគិញរួចឆាយ និង ឃ្លាំង បានឲ្យខ្ញុំ និងជ្រូក ទាក់ទងខ្សែគិញ

ពីររូបទៀត ដែលមានឈ្មោះដូចតទៅ ១) ហ៊ាង អតីតជាអ្នកនេសាទ និង ២) ឈ្មោះ ស្រុន អតីតអ្នកដួញគោ រួមធ្វើសកម្មភាពយកការណ៍ពីប្រជាជនថ្មីដែលចូលក្នុងភូមិ ហើយរាយការណ៍ឲ្យឈ្មោះ ឃ្លាំង និង ឆាយ ចាំចាប់ប្រជាជនថ្មីទាំងនោះ។ ខ្ញុំមិនដឹងថា ឃ្លាំង និង ឆាយ ចាប់យកទៅណានោះទេ។

ក្រោយមកទៀត ខ្ញុំ, ហ៊ាង និង ស្រុន បានទាក់ទងវិញឈ្មោះ ឈិន អតីតទាហានចាស់ រួមធ្វើសកម្មភាពតាមដានខ្មែរក្រហមក្នុងឃុំ តែមិនបានលទ្ធផលអ្វីទេ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចសីហនុ កងទ័ពបដិវត្តន៍ក៏ចូលដល់ភូមិ ចំណែកជីទប់ ឃ្លាំង ក៏រត់ចូលតំបន់ខ្មាំង ដូច្នេះខ្ញុំក៏ដាច់ខ្សែទាក់ទង និងសកម្មភាពជាវិញ។ នៅដើមឆ្នាំ១៩៧១ ខ្ញុំចូលធ្វើបដិវត្តន៍ និងត្រូវមកនៅបម្រើការងារនៅមន្ទីរសិល្បៈស្រុកកំពង់សៀម ចំណែកការរស់នៅរបស់ខ្ញុំគឺធ្វើខ្លួនសេរី ហេតុនេះឈ្មោះ វុធ (ឆ្នាំ១៩៧៣ ជាសមាជិកគណៈសិល្បៈស្រុកកំពង់សៀម) បានមកអប់រំខ្ញុំថា ធ្វើការងារក្នុងបដិវត្តន៍អនាគតទៅ ស៊ីអង្ករកំប៉ុង លើកពីសង្គមថ្មី និងប្រទេសសេរីសម្បូរបែបរស់នៅសេរីតាមចិត្តមិនតឹងតែងដូចសង្គមបដិវត្តន៍។

ដល់ខែឧសភា ឆ្នាំ១៩៧១ ឈ្មោះ វុធ ក៏សម្រេចបញ្ចូលខ្ញុំជា សេ-អ៊ី-អា ក្រោមវត្តមានឈ្មោះ ភឹន អតីតសិស្ស (ឆ្នាំ១៩៧៣ ប្រធានសិល្បៈស្រុកកំពង់សៀម), ស្លួន អតីតសិស្ស និងជាលេខាស្រុកកំពង់សៀម (ឆ្នាំ១៩៧២ ស្លាប់)។ ចំណែកអ្នកដែលចូល សេ-អ៊ី-អា ដណាលខ្ញុំគឺមានឈ្មោះ សេន អតីតប៉ូលីស (ឆ្នាំ១៩៧៣ ប្រធានក្រុមភ្លេងសិល្បៈ ស្រុកកំពង់សៀម) និង ឈ្មោះ យ៉េង អតីតទាហាន (ឆ្នាំ១៩៧៣ យុវជនសិល្បៈស្រុកកំពង់សៀម)។ ភារកិច្ចរបស់ពួកខ្ញុំពេលបញ្ចូលជា សេ-អ៊ី-អា រួចគឺ៖ ១) បំផុសយុទ្ធជនឲ្យរត់ចូលតំបន់ខ្មាំង ២) កសាងកម្លាំង សេ-អ៊ី-អា បន្ថែម និង ៣) បំផ្លាញផលរបស់បដិវត្តន៍។ នៅចុងឆ្នាំ១៩៧១ វុធ បានចាត់តាំងឲ្យខ្ញុំទាក់ទងកម្លាំង សេ-អ៊ី-អា ផ្សេងទៀតដែលមានឈ្មោះ ដូចជា ខន អតីតទាហាន (ឆ្នាំ១៩៧៣ សិល្បៈស្រុកកំពង់សៀម), ឆ្លូ អតីតទាហាន (ឆ្នាំ១៩៧៣ សិល្បៈស្រុកកំពង់សៀម) និង ឆន អតីតទាហាន (ឆ្នាំ១៩៧៣ សិល្បៈស្រុកកំពង់សៀម)។ សកម្មភាពថ្មីរបស់ពួកខ្ញុំគឺលួចទម្លាយធ្នូសត្រីក្នុងព្រៃកពាមក្នុង។

ដើមឆ្នាំ១៩៧២ ឈ្មោះ វុធ និង ភឹន ប្រមូលបក្ខពួកប្រជុំ ដែលអ្នកចូលរួមប្រជុំមានខ្ញុំ, សេន, យ៉េង, ឆន, ឆ្លូ និង ខន។ ខ្លឹមសារប្រជុំគឺ បំផ្លិចបំផ្លាញផលបដិវត្តន៍ កសាងកម្លាំង សេ-អ៊ី-អា និងលួចបាញ់ ឡានដឹកជញ្ជូនគ្រាប់។ ក្រោយទទួលផែនការរួច ខ្ញុំបានលួចដុតមន្ទីរកុមារស្រុកឆេះអស់មួយខ្នង រួចមកខ្ញុំ, ខន និង យ៉េង បានអុក ឡុកមន្ទីរនារីឲ្យផ្អើលឆោឡោ និងយកសត្វខ្លួយឲ្យទិចជ្រូកងាប់អស់៧ក្បាល។ ក្នុងពាក់កណ្តាលឆ្នាំ១៩៧២ ឈ្មោះ វុធ បានចាត់តាំងខ្ញុំឲ្យទាក់ទងកម្លាំង សេ-អ៊ី-អា ដែលមានឈ្មោះ ថា ជាអតីតទាហាន (ឆ្នាំ១៩៧៣ យុវជនអង្គភាពសិល្បៈស្រុកកំពង់សៀម) រួមធ្វើសកម្មភាពជាមួយឈ្មោះ ជឿន មេចោរព្រៃ ដែលមានសមាជិក៣០នាក់ នៅក្នុងព្រៃនាមបឹងធំ ឲ្យចូលមកធ្វើសកម្មភាពប្លន់ប្រជាជនក្នុងភូមិវិហារធំ ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ក្រោយមកទៀត ប្រហែលជាចុងឆ្នាំ១៩៧២ វុធ បានឲ្យទាក់ទងសកម្មភាពបន្ថែមទៀត ដែលមានឈ្មោះ ហ៊ុម អតីតប៉ូលីស (ឆ្នាំ១៩៧៣ ប្រធានភូមិកំពង់រលឹង ឃុំវិហារធំ ស្រុកកំពង់សៀម) ខ្លឹមសារទាក់ទងគឺឲ្យឈ្មោះ ហ៊ុម ទាក់ទង សក្តិ២ សី នៅបន្ទាយធ្លា ដើម្បីសុំគ្រាប់យកមកឲ្យកម្លាំងចោរព្រៃ។ រំលងបាន៣ថ្ងៃក្រោយ ខ្ញុំ, ថា, សេន, យ៉េង និង ខន បានទៅយកគ្រាប់កាំភ្លើងពីឈ្មោះ ហ៊ុម ឲ្យទៅ ខាងកម្លាំងចោរព្រៃ ដែលមានឈ្មោះ ជឿន ជាមេ។

នៅឆ្នាំ១៩៧៣ វុធ នៅតែមានផែនការឲ្យខ្ញុំទាក់ទងខ្សែរយៈ សេ-អ៊ី-អា ជាបន្តបន្ទាប់ដូចជា

*ឈ្មោះ ផ្លូច អតីតជាទាហាន រួមគ្នាធ្វើសកម្មភាព យកដីខ្សាច់ ទឹកអំបិល ដាក់ចូលក្នុងម៉ាស៊ីនដេរខូចអស់៣គ្រឿង។ នៅពាក់កណ្ដាលឆ្នាំ១៩៧៣ ខ្ញុំនិងគ្នីគ្នាបានដុតស្រូវទុំក្នុងស្រែអេះអស់៤ហិចតា។ ដល់ខែមិថុនា ឆ្នាំ១៩៧៣ វុធ ចាត់តាំងឲ្យខ្ញុំចូលបង្កប់ខ្លួនក្នុងយោធាស្រុកកំពង់សៀម រួចបន្តភ្ជាប់ខ្សែ សេ-អ៊ី-អា ចំនួន២រូបទៀត ឈ្មោះ ងួន ជាប្រធានកងតូចយោធាស្រុកកំពង់សៀម ក្នុងឆ្នាំ១៩៧៣ និង ឈ្មោះ ស៊ឹម ជាអនុកងតូច។ ក្រោយមក ងួន និង ស៊ឹម បាននាំខ្ញុំឲ្យស្គាល់ខ្សែ សេ-អ៊ី-អា បន្ថែមទៀត ដូចជា ចក់ អតីតស៊ុយត្រាណ, ព្រាប ប្រធានវរសេនាតូច៤០៨, ស្មាញ អតីតអ្នកបួស, ចាន់ សមាជិកក្រុមអនុសេនាធំ៣វរសេនាតូច៤០៨ និងអាតអតីតបួស(ឆ្នាំ១៩៧៤ យុវជនអនុសេនាធំ៣វរសេនាតូច៤០៨)។ សកម្មភាព គឺ លួចបាញ់កងនារីឲ្យផ្អើលឆោឡោក្នុងអង្គភាព និង បំផុសឲ្យរត់ត្រឡប់ទៅរស់នៅផ្ទះវិញ។*

*នៅឆ្នាំ១៩៧៤ ឈ្មោះ ស្មាញ បានប្រមូលបក្ខពួកប្រជុំជាថ្មី ដើម្បីប្រមូលកម្លាំង សេ-អ៊ី-អា ថ្មីបន្ថែមទៀត។ កម្លាំង សេ-អ៊ី-អា ថ្មីមានឈ្មោះ សារី ជាយុវជនអនុសេនាធំ៣វរសេនាតូច៤០៨។ សាន អតីតបួស ជាយុវជនអនុសេនាធំ៣ វរសេនាតូច៤០៨។ រស់ មានតួនាទីក្នុងឆ្នាំ១៩៧៥ ជាប្រធានសាលាអប់រំយោធាភាគកណ្ដាល។ សឿន សមាជិកមន្ទីរអប់រំ មុនចាប់ខ្លួនមានតួនាទីជាសមាជិកអនុសេនាធំ វរសេនាតូច៣២។ ថង យុវជនកងការពារសាលាអប់រំ។ គូ ឆ្នាំ១៩៧៥ មានតួនាទីជាយុវជនកងការពារសាលានយោបាយ និង ជឿន ឆ្នាំ១៩៧៥ មានតួនាទីជាយុវជនកងការពារសាលានយោបាយ។*

*ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការដក ឡូត, សឿន និងខ្ញុំឲ្យមកនៅផ្នែកដឹកជញ្ជូនយានដ្ឋាន ក្នុងក្រសួងពាណិជ្ជកម្ម ក្រុងកំពង់សោម។ ខ្ញុំមានតួនាទីជាយុវជន បន្ទាប់មក សឿន បាននាំខ្ញុំមកទាក់ទងខ្សែ សេ-អ៊ី-អា ដែលមានឈ្មោះ អួន តួនាទីជាប្រធានយានដ្ឋាន។ តាមរយៈឈ្មោះ អួន បានឲ្យខ្ញុំទាក់ទងឈ្មោះ ទៀង តួនាទីក្នុងឆ្នាំ១៩៧៦ ជាអនុក្រុមផ្នែកយានដ្ឋានពាណិជ្ជកម្មកំពង់សោម។ នៅខែមិថុនា ឆ្នាំ១៩៧៦ សឿន ហៅ ខ្ញុំ, ឡូត, ទៀង និង ថា ប្រជុំលើកផែនការ បំផ្លាញគ្រឿងម៉ាស៊ីន និង បំផ្លាញប្រេងឥន្ធនៈ។ បន្ទាប់មកទៀត សកម្មភាពរបស់ខ្ញុំបានកសាងកម្លាំងថ្មីម្នាក់ទៀត ឈ្មោះ ចេក មុនចាប់ខ្លួនមានតួនាទីសមាជិកក្រុមវរសេនាតូច៣១ វរសេនាធំ៣។*

*នៅខែសីហា ឆ្នាំ១៩៧៦ អង្គភាពយានដ្ឋានត្រូវអង្គការរំសាយចូលក្នុងអង្គភាពកំពង់ផែ ក្នុងពេលនោះ ខ្ញុំ, ឡូត, សឿន, ចេក, អេង, សេង និង សែ ត្រូវចូលក្នុងវរសេនាតូច៣២ វរសេនាធំ៣ កម្មករផែកំពង់សោម។ បន្ទាប់ពីចូលធ្វើជាកម្មផែកំពង់សោម ខ្ញុំ, ភី និង ចេក បានរួមគ្នាធ្វើសកម្មភាពយកអាចម៍ដែកដាក់ក្នុងម៉ូទ័រអេះអស់មួយ និងខូចម៉ាស៊ីនក្រឡឹងមួយគ្រឿង។ ដល់ចុងឆ្នាំ៧៦ អង្គការដកខ្ញុំមកនៅផ្នែកបើកបរ លើកដាក់ ក្នុងផែកំពង់សោម។ នៅទីនេះ ខ្ញុំធ្វើសកម្មភាពលួចផ្ដាច់ខ្សែភ្លើងដែលចូលក្នុងមន្ទីរពេទ្យឲ្យរលត់។*

*ចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ១៩៧៧ សឿន និង ខ្ញុំនៅតែបន្តកសាងខ្សែ សេ-អ៊ី-អា និងធ្វើសកម្មភាពជាច្រើនដូចជា កាច់ផ្លូវរថភ្លើង ធ្វើឲ្យរថភ្លើងបើកខុសផ្លូវ យកទឹកចាក់លាយជាមួយប្រេងម៉ាស៊ូត លាយជាមួយសាំងជាដើម។ រហូតដល់ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនខ្ញុំតែម្ដង។*

***កំណត់ចំណាំ ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាព J00038។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខខ្មែរក្រហម សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ស៊ុំ សាមឿន ហៅ រំ ពិត ប៉ុយ៉ាងណានោះទេ។***

# បណ្ណាល័យហោអដ្ឋិធាតុ

សោម ប៊ុនថន



«បណ្ណាល័យហោអដ្ឋិធាតុ» មានទីតាំងស្ថិតនៅវត្តលង្កា ក្នុងទីក្រុងភ្នំពេញ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

«បណ្ណាល័យហោអដ្ឋិធាតុ» មានទីតាំងស្ថិតនៅវត្តលង្កា ក្នុងទីក្រុងភ្នំពេញ។ គំនិតបង្កើតឡើងឲ្យមានបណ្ណាល័យនេះ គឺកើតឡើងនៅពេលដែលលោក ឆាំង យុ បានសាងផ្នួសនៅវត្តលង្កាអំឡុងពេលបងស្រីរបស់លោកឈ្មោះ កែវ កុលធីតាឯកស័ក្ត គឺជាមនុស្សគរថ្ងន់ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ធ្វើមរណកាលកាលពីឆ្នាំ២០១៨ ដោយសារជំងឺមហារីកធ្ងន់ធ្ងរ។ លោក ឆាំង យុ បានប្រទះឃើញកោដ្ឋដាក់អដ្ឋិធាតុប្រមាណជាង៨០០ ស្ថិតនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងព្រះវិហារចាស់វត្តលង្កា ដែលបងប្អូន និងសាច់ញាតិយកមកផ្ញើជាមួយព្រះសង្ឃឲ្យជួយថែរក្សាក្នុងសម័យសង្គ្រាមទសវត្សរ៍ឆ្នាំ១៩៧០ និងក្រោយរបបខ្មែរក្រហមដួលរលំនៅទសវត្សរ៍៨០។ កោដ្ឋដាក់អដ្ឋិធាតុមួយចំនួនមានឈ្មោះ និងចុះកាលបរិច្ឆេទ ដោយឡែកកោដ្ឋមួយចំនួនទៀតមិនមានការចុះកាលបរិច្ឆេទ និងឈ្មោះឡើយ។

ភ្លាមៗនោះ លោក ឆាំង យុ បានស្នើសុំសម្តេចព្រះធម្មលិខិតបណ្ឌិត សៅរ៍ ចន្ទថុល ព្រះចៅអធិការវត្តលង្កាដើម្បីសម្អាតកោដ្ឋដាក់អដ្ឋិធាតុ ដែលគ្មាន



«បណ្ណាល័យហោអដ្ឋិធាតុ» មានទីតាំងស្ថិតនៅវត្តលង្កា ក្នុងទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





សាច់ញាតិទាំងនេះ និងបានរៀបចំដាក់នៅលើធ្នើក្នុងទូឈើ ដែលទាហានជើងទឹកអាមេរិកប្រចាំនៅប្រទេសជប៉ុន ជួយសាងសង់។ ទូដាក់អដ្ឋិធាតុទាំងនោះ ស្ថិតនៅខាងក្រោយព្រះពុទ្ធរូប ក្នុងព្រះវិហារចាស់។ តាមជំនឿរបស់ប្រជាជនខ្មែរ ការរៀបចំទុកដាក់អដ្ឋិធាតុឲ្យបានត្រឹមត្រូវ និងមានទីកន្លែងច្បាស់លាស់ គឺដើម្បីឲ្យព្រលឹងអ្នកដែលស្លាប់ទៅហើយមានទីពឹងពំនាក់ និងមិនវិលវល់ តែលតោល។ ព្រលឹងទាំងនោះនឹងតាមថែរក្សាកូនចៅ និងអ្នកដែលកំពុងនៅរស់រានមានជីវិត។

លោក ឆាំង យុ ចាប់ផ្តើមប្រមូលឈ្មោះអ្នកស្លាប់ និងកាលបរិច្ឆេទដើម្បីរៀបចំធ្វើបញ្ជីឡើងវិញ។ បន្ទាប់មក លោក ឆាំង យុ បានបោះពុម្ពសៀវភៅមួយក្បាលដែលមានចំណងជើងថា «អដ្ឋិធាតុ ៖ គ្មានអ្វីជាអមតៈ» ដើម្បីឲ្យសមាជិកក្រុមគ្រួសារដែលនៅរស់អាចមកស្វែងរកអដ្ឋិធាតុរបស់សាច់ញាតិបងប្អូនឪពុកម្តាយដែលរក្សាទុកនៅវត្តលង្កា ដើម្បីយកអដ្ឋិធាតុទាំងនោះត្រឡប់ទៅវិញ ដែលរហូតមកដល់ពេលនេះមានអដ្ឋិធាតុប្រមាណជាង១០ប៉ុណ្ណោះ ត្រូវបានបងប្អូននិងសមាជិកក្រុមគ្រួសាររកឃើញ។

កាលពីខែធ្នូ ឆ្នាំ២០២៣ កន្លងមក លោក ឆាំង យុ បានស្នើសុំបន្ទប់នៅក្នុងអគារដែលទើបសាងសង់ពីព្រះចៅអធិការវត្តលង្កា ដើម្បីរៀបចំបណ្ណាល័យមួយដោយដាក់ឈ្មោះថា «បណ្ណាល័យហោអដ្ឋិធាតុ» ។ បណ្ណាល័យនេះ ក៏មានទីកន្លែងសម្រាប់ទទួលភ្ញៀវ ធ្វើសមាធិ និងស្រាវជ្រាវដែរ។ គោលបំណងនៃការបង្កើត «បណ្ណាល័យហោអដ្ឋិធាតុ» គឺសម្រាប់ដាក់អដ្ឋិធាតុរបស់ប្រជាជនខ្មែរដែលស្លាប់ទៅហើយ ហើយបងប្អូនសាច់ញាតិដែលនៅរស់គ្មានលទ្ធភាពថែរក្សា និងរៀបចំទីកន្លែងដើម្បីទុកដាក់អដ្ឋិធាតុអ្នកដែលស្លាប់ទាំងនោះឲ្យបានសមរម្យ ជាពិសេសប្រជាជនដែលរស់នៅតាមតំបន់ដាច់ស្រយាល ដែលមានជីវភាពក្រីក្រ និងគ្មានសាច់ញាតិ ហើយផ្លាស់មករស់នៅទីក្រុងភ្នំពេញ។

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកជើងព្រៃ និងស្រុកព្រៃឈររំឭករឿងរ៉ាវពីការងារលើកទំនប់ក្នុងរបបខ្មែរក្រហម

សាំង ចាន់ធូ



ទំនប់ស្រុក ស្ថិតនៅឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ (សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយ លោក ទូច វណ្ណេត, សាំង ចាន់ធូ, លី ដេវីត និង ស៊ាង ចិន្តា បានចុះទៅកាន់តំបន់ទំនប់ដែលកសាងឡើងក្នុងរបបខ្មែរក្រហម សរុបចំនួន៧ ទីតាំង គឺ ១) ទំនប់អណ្ដូងអាង, ២) ទំនប់ទឹកឆា, ៣) ទំនប់តាកុង, ៤) ទំនប់ក្បាលទឹក, ៥) ទំនប់បឹងធំ, ៦) ទំនប់ស្រុកជើងព្រៃ និង៧) ទំនប់តំបន់៤១ ស្ថិតនៅក្នុងស្រុកជើងព្រៃ និងស្រុកព្រៃឈរ ក្នុងភូមិសាស្ត្រតំបន់៤១ នៃភូមិភាគកណ្ដាល (ភូមិភាគឧត្តរចាស់) ក្នុងរបបខ្មែរក្រហម។ ទីតាំងទំនប់ខាងលើ បច្ចុប្បន្នប្រែក្លាយទៅជាអាងស្តុកទឹកសម្រាប់ស្រោចស្រពដំណាំស្រែចម្ការ និងជាកន្លែងសម្រាប់ប្រជាជនមូលដ្ឋានមកទស្សនាកម្សាន្តនាពេលល្ងាច និងចុងសប្តាហ៍។

នៅក្នុងរបបខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨ ប្រជាជននៅភូមិសាស្ត្រតំបន់៤១ ត្រូវអង្គការចាត់តាំង និងប្រមូលផ្តុំរួចហើយបញ្ជូនទៅធ្វើការងារនៅតាមការដ្ឋានទំនប់ខាងលើ។ ប្រជាជន

ជាច្រើនបានបាត់បង់ជីវិតដោយសារការបង្ខំឲ្យធ្វើការលើកទំនប់ហួសកម្លាំង, ការគ្មានអាហារបរិភោគគ្រប់គ្រាន់, ការធ្លាក់ខ្លួនឈឺដោយគ្មានថ្នាំព្យាបាល និងការកាប់សម្លាប់។

***ខាងក្រោម គឺជាការរៀបរាប់អំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់ធ្វើការងារនៅតាមការដ្ឋានទំនប់ក្នុងតំបន់៤១៖***



ខ្ញុំឈ្មោះ **ហ៊ាង សាយ** អាយុ៨២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិបឹងជ្រោយ ឃុំសូទិព្ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៦០ ខ្ញុំរៀបការប្តីឈ្មោះ គ្រីន និងមានកូនប្រុសស្រីសរុបចំនួន៧ នាក់។ ខ្ញុំគឺជាបងស្រីច្បងក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៧ នាក់ ហើយខ្ញុំគឺជាកូនទី១។ ខ្ញុំមិនបានរៀនសូត្រទេ ពីព្រោះខ្ញុំទទួលបន្ទុកដាំបាយ និងមើលថែប្អូនៗ នៅពេលដែលឪពុកម្តាយខ្ញុំចេញទៅទៅធ្វើស្រែចម្ការ។

នៅឆ្នាំ១៩៧០ ស្រាប់តែមានរដ្ឋប្រហារទម្លាក់សម្តេចឪ។ ពេលនោះខ្ញុំឃើញបាតុករដង្ហែគ្នាទៅធ្វើបាតុកម្មនៅភ្នំពេញ។ ចន្លោះពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ កងទ័ពរំដោះខ្មែរក្រហមចូលដល់ភូមិខ្ញុំជាបន្តបន្ទាប់។ នៅពេលនោះ ការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមចាប់ផ្តើមផ្ទុះឡើង។ ខ្ញុំ និងគ្រួសារបានរត់ភៀសខ្លួនចេញពីភូមិទៅរស់នៅម្តុំដូងដុំ។ នៅឆ្នាំ១៩៧៣ មានការទម្លាក់គ្រាប់បែកពីសំណាក់ទាហាន លន់នល់ ក្នុងទ្រង់ទ្រាយធំ រហូតដល់ទីកន្លែងដែលគ្រួសារខ្ញុំរស់នៅ។ ក្រុមគ្រួសារខ្ញុំរត់គេចខ្លួននិងចូលសម្ងំក្នុងរណ្តៅត្រង់សេ។ នៅឆ្នាំ១៩៧៤ នៅពេលដែលប្តីខ្ញុំទៅមើលស្រែប្រាំងនៅត្រើយម្ខាង យន្តហោះទាហាន លន់នល់ បើកមកទម្លាក់គ្រាប់បែក និងបាញ់រះពីលើ បណ្តាលឲ្យគាត់រងរបួស។ ភ្លាមៗនោះ បងប្អូនខ្ញុំហែលឆ្លងទឹកមកយកប្តីខ្ញុំដែលកំពុងពួនក្នុងព្រៃដើម្បីយកទៅពេទ្យព្យាបាលរបួស។

នៅពេលដែលខ្មែរក្រហមវាយដណ្តើមបានទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំបានវិលត្រឡប់មករស់នៅភូមិកំណើតវិញ។ នៅឆ្នាំ១៩៧៦ អង្គការខ្មែរក្រហមបានបង្កើតសហករណ៍ ដែលតម្រូវឲ្យប្រជាជនធ្វើការរួម និង ហូបរួម។ បន្ទាប់មក ឪពុកខ្ញុំបានធ្លាក់ខ្លួនឈឺ និងត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅ ខាងដូងដុំ។ ចំណែកឯម្តាយខ្ញុំវិញត្រូវបានអង្គការបញ្ជូនទៅធ្វើការ ខាងកំពង់ចាម។ ខ្ញុំទទួលដំណឹងពីអ្នកភូមិថា ឪពុកខ្ញុំបានយំនឹកម្តាយខ្ញុំ និងកូនៗ រហូតដល់ធ្លាក់ខ្លួនឈឺ។ ចាប់ពីពេលនោះមក ខ្ញុំមិនដែលបានឃើញគាត់ទាំងពីរទៀតទេ។ ខ្ញុំត្រូវអង្គការដាក់ផែនការឲ្យនៅធ្វើការងារនៅកងចល័ត ដើម្បីស្ទូងស្រូវ និងលើកទំនប់។ ខ្ញុំធ្វើការដកស្ទូងជាមួយមិត្តៗសរុបចំនួន៣៥នាក់ ដែលមានមិត្ត សារ៉ូន ជាប្រធានកងចល័ត និងមិត្ត ខុន់ ជាអនុប្រធានកង។

បន្ទាប់មក ខ្ញុំត្រូវបានអង្គការបញ្ជូនទៅធ្វើអង្គរនៅតាមសហករណ៍ដូងដុំ។ ការហូបចុក គឺមិនគ្រប់គ្រាន់នោះទេ ដោយទទួលបានតែបបររាវមួយចាន ក្នុងមួយពេល ដូច្នេះពេលខ្លះ ខ្ញុំលួចបេះត្រួយដំឡូងបុស្សិកដ្ឋី លាយជាមួយបបរហូប។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅលើកទំនប់តំបន់ដែលមានទីតាំងស្ថិតនៅស្រុកជើងព្រៃ។ បន្ទាប់ពីវែកដីបានមួយរយៈ ខ្ញុំគ្រេចជើង និងហើមជើង ហើយទោះបីយ៉ាងណាខ្ញុំត្រូវក្រោកទៅធ្វើការនៅទំនប់ពីព្រលឹមទល់ព្រលប់ដដែល។ ប្តីខ្ញុំត្រូវអង្គការឲ្យទៅកាប់ដើមឈើយកមកធ្វើថ្នាំ ខណៈពេលដែលកូនរបស់ខ្ញុំត្រូវបានអង្គការចាត់ចូលធ្វើការនៅក្នុងកងកុមារ។ គ្រួសារខ្ញុំត្រូវរស់នៅបែកបាក់គ្នា និងរស់នៅ ទាំងលំបាកវេទនា រហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ទើបគ្រួសារខ្ញុំអាចរស់នៅជួបជុំគ្នាវិញ។ រាល់ពេលដែលខ្ញុំរំឭកអំពីរបបខ្មែរក្រហម ខ្ញុំនៅតែមានអារម្មណ៍តក់ស្លុត និងមិនអាចបំភ្លេចបាន ដូចជា ការធ្វើការងារហួសកម្លាំង និងគ្មានអាហារហូបចុកគ្រប់គ្រាន់។



ខ្ញុំឈ្មោះ **ស៊ន់ ឆាង** អាយុ៦៨ឆ្នាំ កើតនៅភូមិតាកុដ ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ហើយបច្ចុប្បន្នខ្ញុំរស់នៅឃុំដដែល។ ខ្ញុំរៀបការប្ដីឈ្មោះ ឃុន និងមានកូនសរុបចំនួន៥នាក់។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។

កាលពីកុមារភាព ខ្ញុំរៀនសូត្របានតិចតួចណាស់ ពីព្រោះតែសង្គ្រាម។ ក្នុងពេលសង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ខ្ញុំរត់គៀសខ្លួនទៅរស់នៅក្នុងភូមិគេស។ ក្រោយមកទៀត ខ្ញុំឃើញកងទ័ពរំដោះខ្មែរក្រហមចូលមកក្នុងភូមិជាបណ្ដើរៗ។

ចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ ទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម បើកការប្រយុទ្ធគ្នាកាន់តែខ្លាំងឡើងៗ។ ឪពុកម្ដាយខ្ញុំ នាំខ្ញុំនិងកូនៗរត់គេចខ្លួន និងចូលពួនក្នុងព្រៃ។ ចន្លោះឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៤ សមរភូមិប្រយុទ្ធរវាងភាគីទាំង២ផ្ទុះកាន់តែខ្លាំងរួមទាំង ការទម្លាក់គ្រាប់បែក និងការបាញ់រះពីលើអាកាស។ ដូច្នេះ ឪពុករបស់ខ្ញុំក៏ជីករណ្ដៅត្រង់សេដើម្បីការពារខ្លួន។

នៅឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមឡើងកាន់កាប់អំណាចទាំងស្រុង។ ប្រជាជនត្រូវអង្គការចាត់តាំងឲ្យធ្វើការងារប្រវាស់ដៃអស់រយៈពេល ៤ទៅ៥ខែ ទើបសហករណ៍ត្រូវបានបង្កើត។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅក្នុងកងចល័តនារី ដើម្បីដើរដកស្ទូង។ ក្រោយមកទៀត អង្គការបញ្ជូនខ្ញុំទៅលើកទំនប់តំបន់ដែលស្ថិតនៅព្រំប្រទល់រវាងស្រុកជើងព្រៃ និងស្រុកព្រៃឈរ។ មានប្រជាជនជាច្រើនពាន់នាក់ត្រូវបានបញ្ជូនមកលើកទំនប់តំបន់ ដោយកងចល័តបុរសគឺជាអ្នកកាប់ដី បំណែកឯកងចល័តនារី គឺជាអ្នករែកដីរហូតដល់ទំនប់នេះសាងសង់រួចរាល់។

នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានមកដល់ និងគ្រប់គ្រងការដ្ឋានទំនប់។ អង្គការកំណត់របបអាហារចំពោះប្រជាជនគឺឲ្យហូបមិនបានគ្រប់គ្រាន់, ការធ្វើការងារគ្មានពេលសម្រាក និងការធ្លាក់ខ្លួនឈឺស្លាប់ដោយសារតែគ្មានថ្នាំព្យាបាល។ ខ្ញុំរួចផុតពីការបង្ខំឲ្យធ្វើការងារជាទម្ងន់នៅទំនប់ បន្ទាប់ពីប្រជាជនត្រូវបានរំដោះដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចេញពីខ្មែរក្រហម។ ខ្ញុំធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។



ខ្ញុំឈ្មោះ **គ្រី អូនទូត** អាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅភូមិទូល ឃុំបាធាយ ស្រុកជើងព្រៃ (បច្ចុប្បន្ន ស្រុកបាធាយ) ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧៧ ប្រធានកងចុងភៅរបស់ខ្ញុំឈ្មោះ មិត្តណែត ដឹកនាំខ្ញុំមកលើកទំនប់។ នៅពេលនោះ គឺជាពេលដែលកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកកាន់កាប់តំបន់ខ្ញុំរស់នៅ។ ប្រជាជនដែលមកលើកទំនប់ គឺជាប្រជាជនមកពីស្រុកជើងព្រៃ និងស្រុកព្រៃឈរ។ ក្រោយមកទៀត ខ្ញុំត្រូវបានដកទៅលើកទំនប់ផ្សេងទៀតនៅស្រុកជើងព្រៃ រហូតដល់រំដោះប្រទេសនៅឆ្នាំ១៩៧៩។



ខ្ញុំឈ្មោះ **កែវ ហុកគ្រី** អាយុ៦០ឆ្នាំ កើតនៅភូមិ

បឹងជ្រោយ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំគឺជាមេឃុំសូទិព្វ។ ខ្ញុំរៀបការប្រពន្ធឈ្មោះ ធុច តែឆេង និងមានកូនចំនួន៣នាក់។ នៅឆ្នាំ១៩៧៦ ប្រជាជនជាច្រើនរយនាក់ត្រូវបានចល័តមកលើកទំនប់ស្រុក។ ប្រជាជនលើកទំនប់ទាំងអស់ស្លៀកពាក់ខ្មៅ ទិ៍ងមើលទៅឃើញតែខ្មៅនៅពាសពេញដី។ ខ្ញុំត្រូវជីកដី និងរែកដី ទៅតាមការកំណត់របស់អង្គការ ចាប់ពីព្រលឹមទល់ព្រលប់។ ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមឲ្យធ្វើជាមេ៥០ខ្នង (បើគិតនាពេលបច្ចុប្បន្ននេះវិញ គឺជាមេភូមិ)។ មួយរយៈពេលក្រោយមក ឪពុកខ្ញុំ និងមិត្តភក្តិគាត់២នាក់ផ្សេងទៀត ត្រូវបានចាត់តាំងឲ្យទៅរកថ្នាំខ្មែរនៅស្រុកលើសម្រាប់ព្យាបាលអ្នកជំងឺរយៈពេលប្រមាណ៣ខែ ទើបគាត់វិលត្រឡប់មកភូមិវិញ។ ចំណែកម្តាយរបស់ខ្ញុំជរា និងមិនអាចទៅណាឆ្ងាយពីភូមិបានទេ ដូច្នេះការងាររបស់គាត់គឺមើលថែក្មេងៗ។ បន្ទាប់មក ឪពុកខ្ញុំត្រូវបានឲ្យធ្វើជាមេក្រុម ដែលគ្រប់គ្រងមនុស្សចំនួន១២នាក់ ដើម្បីរែកអង្ករ និងស្បៀងអាហារផ្សេងៗយកទៅឲ្យកងទ័ពខ្មែរក្រហមនៅសមរភូមិមុខ។ នៅពេលដែលប្រជាជនត្រូវបានរំដោះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបគ្រួសាររបស់ខ្ញុំអាចរស់នៅជួបជុំគ្នា និងប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត។



ទំនប់តំបន់៤១ ស្ថិតនៅព្រំប្រទល់ស្រុកព្រៃឈរ និងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ (សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទំនប់អណ្តូងអាង ស្ថិតនៅឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ (សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទំនប់តាកុដ ស្ថិតនៅព្រំប្រទល់ស្រុកជើងព្រៃ និងស្រុកកងមាស ខេត្តកំពង់ចាម។ (សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទំនប់ក្បាលទឹក ស្ថិតនៅឃុំក្រូច ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ (សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទំនប់ទឹកឆា ស្ថិតនៅឃុំក្រូច ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ (សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបណ្តុះបណ្តាល អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ដើម្បីចុះធ្វើការងារជាមួយអ្នករស់រាន មានជីវិតពីរបបខ្មែរក្រហមនៅតាមមូលដ្ឋាន

**សួត វិចិត្រ**



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ចំនួន៨៣នាក់ ដើម្បីពង្រឹងសមត្ថភាពដល់យុវជននៅក្នុងការសម្ភាសន៍ ស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងប្រមូលព័ត៌មានទាក់ទងនឹងស្ថានភាពសុខភាព អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងពេលបច្ចុប្បន្ន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ចំនួន៨៣នាក់ ដើម្បីពង្រឹងសមត្ថភាពដល់យុវជននៅក្នុងការសម្ភាសន៍ ស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងប្រមូលព័ត៌មានទាក់ទងនឹងស្ថានភាពសុខភាពនៅក្នុងពេលបច្ចុប្បន្ន។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដោយបែងចែកជាក្រុមតូចៗផ្សេងៗគ្នា គិតចាប់ពីថ្ងៃទី៤ ដល់ទី៦ ខែមករា ឆ្នាំ២០២៤ ជាមួយនឹងយុវជនមកពីស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ និងក្រុងសំរោងនៃខេត្តឧត្តរមានជ័យ និងស្រុកអង្គរធំ នៃខេត្តសៀមរាប ដោយក្នុងដំណើរការនេះ គឺផ្តោតសំខាន់ទៅលើរបៀបនៃការធ្វើបទសម្ភាសន៍ និងការប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមមូលដ្ឋាន, ការសង្ខេបសាច់រឿង និងការបញ្ចូល

ទិន្នន័យ ទាំងនោះទៅក្នុងប្រព័ន្ធឌីជីថលផ្តល់ជូនគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។

គម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ២០២១មក នៅអំឡុងពេលជំងឺកូវីដ-១៩ រាតត្បាតនៅទូទាំងប្រទេសកម្ពុជា និងសាកលលោកទាំងមូល ប៉ុន្តែយុវជនកម្ពុជាបានចូលរួមនៅក្នុងគម្រោងនេះជាបន្តបន្ទាប់ មកទល់នឹងជំនាន់ទី៨ ដើម្បីរៀនសូត្រអំពីបទពិសោធន៍ជីវិតដ៏លំបាក និងមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជាដែលឆ្លងកាត់របបខ្មែរក្រហម។ យុវជននៅក្នុងជំនាន់ទី៨ នឹងមានរយៈពេលបីខែសម្រាប់បំពេញការងារនៅក្នុងសហគមន៍របស់ខ្លួន ដោយគិតចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។

កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានបង្ហាត់បង្ហាញអំពី តើអ្វីជាកិច្ចការដែលយុវជនត្រូវធ្វើនៅក្នុងគម្រោងខាងលើនេះ? តើលក្ខខណ្ឌអ្វីខ្លះដែលយុវជនត្រូវបំពេញ? តើគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ខ្លួន និងចាស់ៗដែលជាអ្នករស់រានមានជីវិតយ៉ាងដូចម្តេច? គោលដៅសំខាន់បំផុតនៅក្នុងគម្រោងនេះ គឺចង់ឲ្យយុវជនស្តាប់សាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការផ្តល់ជូនសេវាពិនិត្យសុខភាពដោយឥតគិតថ្លៃ។ នៅក្នុងការសួរនាំ និងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតម្នាក់ យុវជនត្រូវបំពេញលក្ខខណ្ឌចំនួន៤សំខាន់ៗរួមមាន៖ ១) ការថតសំឡេងសម្ភាសន៍, ២) ការសង្ខេបសាច់រឿងឡើងវិញ ៣) ការថតរូប ,៤) ការបញ្ចូលទិន្នន័យ ទាំងអស់ដាក់ទៅក្នុងកម្មវិធី One-Drive ឬ Server ដើម្បីធានាថា រឿងរ៉ាវទាំងនោះត្រូវបានចងចាំ និងរក្សាទុកប្រកបដោយសុវត្ថិភាព។ នៅត្រង់ចំណុចនេះ អ្នកស្ម័គ្រចិត្តបានសួរនាំច្រើនទៅកាន់វាគ្មិន ដោយសារអ្នកស្ម័គ្រចិត្តមិនធ្លាប់មានបទពិសោធន៍ធ្វើកិច្ចការទាំងនេះ។ អ្នកស្ម័គ្រចិត្តម្នាក់ៗហាក់មិនទាន់យល់ថា តើអ្វីទៅជាការសម្ភាសន៍នៅឡើយ ព្រមទាំងមិនដឹងគួរចាប់ផ្តើមពីចំណុចណា ហើយបញ្ចប់ទៅវិញត្រង់ចំណុចណានោះទេ។




មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ចំនួន៨៣នាក់ ដើម្បីពង្រឹងសមត្ថភាពដល់យុវជននៅក្នុងការសម្ភាសន៍ ស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងប្រមូលព័ត៌មានទាក់ទងនឹងស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងពេលបច្ចុប្បន្ន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យ៉ាងណាមិញ នៅក្នុងការបណ្តុះបណ្តាលនេះ អ្នកស្ម័គ្រចិត្តត្រូវបានតម្រូវឲ្យអនុវត្តផ្ទាល់ធ្វើជាគំរូជាមួយនឹងអ្នកស្ម័គ្រចិត្តនៅក្នុងក្រុម ដោយអ្នកស្ម័គ្រចិត្តម្នាក់ត្រូវបានតំណាងជាអ្នកស្ម័គ្រចិត្ត និងម្នាក់ទៀតគឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលនឹងផ្តល់បទសម្ភាសន៍។ យុវជនស្ម័គ្រចិត្តម្នាក់ៗបានសង្កេតមើល និងផ្តល់យោបល់ទៅលើការអនុវត្តផ្ទាល់នោះ ដើម្បីឈ្វេងយល់ និងត្រៀមខ្លួនបត់បែនទៅលើអ្វីៗដែលនឹងជួបប្រទះនៅពេលខ្លួន ចុះទៅជួបផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកស្ម័គ្រចិត្តមួយចំនួនហាក់យល់ដឹងឆាប់រហ័ស ខណៈដែលអ្នកស្ម័គ្រចិត្តមួយចំនួនបានសួរនាំអំពីផលប្រឈមនៃការគិតទុកជាមុននៅឡើយ ដូចជា តើគួរធ្វើដូចម្តេចដើម្បីសម្ភាសន៍ប្រកបដោយទំនុកចិត្ត? តើយើងអាចសម្គាល់បានយ៉ាងដូចម្តេចថាអ្នកណាជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម? ឯកសារមួយចំនួនរួមមានប្រតិចារឹកនៃបទសម្ភាសន៍ដែលបានយកចេញពីបណ្ណសាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង, សេចក្តីសង្ខេបសាច់រឿង និងឯកសារមួយចំនួនទៀតដែលត្រូវការប្រើប្រាស់នៅក្នុងកិច្ចការងារស្ម័គ្រចិត្តនៅក្នុងគម្រោងថែទាំសុខភាព ដើម្បីផ្តល់ជាឧទាហរណ៍ ដល់យុវជនអំពីរបៀបនៃការសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅក្នុងការសម្ភាសន៍អ្នករស់រានមានជីវិតម្នាក់ យុវជនត្រូវចំណាយពេលចាប់ពី១ម៉ោងឡើងទៅដែលមានលក្ខណៈលម្អិត និងអាចយកជាការបាន។ បន្ទាប់មក យុវជនត្រូវសង្ខេបសាច់រឿងឡើងវិញនៅពេលត្រឡប់មកផ្ទះ ដែលមានខ្លឹមសារគ្រប់គ្រាន់យ៉ាងហោចណាស់ចំនួន២ទំព័រ ឬច្រើនជាងនេះ។ យុវជននឹងបន្តធ្វើកិច្ចការបែបនេះទៅតាមពេលវេលាជាក់ស្តែងរបស់ខ្លួនប្រកបដោយការច្នៃប្រឌិត និងការតាំងចិត្តខ្ពស់ ហើយយុវជនក៏ទទួលបានការឧបត្ថម្ភទៅតាមកិច្ចការជាក់ស្តែងរបស់ខ្លួនដែរ។

អ្នកស្ម័គ្រចិត្តមួយចំនួនក៏កំពុងស្ថិតនៅក្នុងការសិក្សានៅឡើយ ដូច្នេះហើយការបែងចែក និងការប្រើប្រាស់ពេលវេលាឲ្យអស់លទ្ធភាព ក៏បង្ហាញអំពីការចង់ចេះចង់ដឹងពីប្រវត្តិសាស្ត្រ និងការចូលរួមនៅក្នុងការងារសហគមន៍។ នៅផ្នែកបន្ទាប់មកទៀតគឺជាដំណាក់កាលចុងក្រោយដែលអ្នកស្ម័គ្រចិត្តត្រូវបំពេញ គឺការរក្សាទុកទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណែត ធ្វើបទបង្ហាញដោយ មេក វិន និង សួត វិចិត្រ ដែលជាសហការីៗ អ្នកទាំងពីរបានប្រាប់ពីរបៀបទាញយក និងប្រើប្រាស់កម្មវិធី One Drive ដើម្បីសម្រួលដល់ការរក្សាទុកឯកសារពីចម្ងាយ ហើយយុវជនទាំងអស់ក៏ត្រូវបានរំឭកអំពីការបញ្ចូលឯកសារឲ្យទាន់ពេលវេលា និងការរក្សាទុកឲ្យមានសុវត្ថិភាពបំផុតជៀសវាងការបាត់ ឬលុបដោយអចេតនាណាមួយ។ មួយវិញទៀតរាល់សំឡេង ឬទិន្នន័យទាំងអស់ត្រូវពិនិត្យមើលម្តងហើយម្តងទៀត ដើម្បីធានាថាទិន្នន័យទាំងនោះត្រូវបានផ្ញើចេញ ឬ បញ្ជូនមកក្រុមការងាររួចរាល់ហើយ។

បន្ទាប់ពីចូលរួមវគ្គបណ្តុះបណ្តាលនេះ ក្រុមការងារបានផ្តល់អាវ មួក និងទស្សនាវដ្តីស្វែងរកការពិតលេខពិសេសដល់អ្នកស្ម័គ្រចិត្តទាំង៨៣នាក់ ដើម្បីចាប់ផ្តើមកិច្ចការរបស់ខ្លួនចាប់ពីថ្ងៃបណ្តុះបណ្តាលនេះ។ ជារួមគម្រោងខាងលើនេះ មិនត្រឹមតែបើកឱកាសឲ្យយុវជនមានភាពក្លាហាន និងសកម្មភាពនៅក្នុងសហគមន៍របស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឱកាសដល់អ្នករស់រានមានជីវិតដែលស្ថិតនៅក្នុងសហគមន៍របស់ខ្លួន ទទួលបានសេវាពិនិត្យសុខភាព ដើម្បីថែរក្សាអាយុជីវិតឱ្យមានរយៈពេលវែង និងចងចាំរឿងរ៉ាវប្រវត្តិសាស្ត្រសម្រាប់យុវជនជំនាន់ក្រោយ។ គួរបញ្ជាក់ថា នៅចុងបញ្ចប់នៃកិច្ចការងារស្ម័គ្រចិត្តជំនាន់ទី៨ អ្នកស្ម័គ្រចិត្តទាំងអស់នឹងត្រូវបានអញ្ជើញឲ្យចូលរួមទស្សនកិច្ចដោយជិះរថភ្លើងដើម្បីឈ្វេងយល់អំពីប្រវត្តិសាស្ត្រ ដែលប្រជាជនកម្ពុជាត្រូវបានជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីចប់វគ្គបណ្តុះបណ្តាល អ្នកស្ម័គ្រចិត្តចំនួន២នាក់បានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ ក្អម ស្រីឌី ភេទស្រី អាយុ២៧ឆ្នាំ រស់នៅភូមិខ្ញុំ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ខ្ញុំមានអារម្មណ៍រំភើបផង ភ័យផង និងអរផង ដែលបានចូលក្នុងវគ្គបណ្តុះបណ្តាលថ្ងៃនេះ។ ខ្ញុំបានមកជួបជុំគ្នា និងហូបអាហារជុំគ្នា ដោយមានលោកគ្រូ អ្នកគ្រូរួសរាយរាក់ទាក់។ លោកគ្រូអ្នកគ្រូបានបង្រៀនខ្ញុំដោយយកចិត្តទុកដាក់ និងបើកឱកាសឲ្យខ្ញុំសួរសំណួរ ហើយឆ្លើយតបភ្លាមៗ។ លោកគ្រូអ្នកគ្រូមិនស្មាក់ស្មើរ និងទុកសំណួររបស់ខ្ញុំចោលឡើយ ដែលធ្វើឲ្យខ្ញុំឆាប់ទទួលបាននូវចំណេះដឹងដែលយើងចង់បាន។ នៅក្នុងនោះក៏មានការប្រជុំវែកញែកនូវតម្រូវការរបស់យុវជនម្នាក់ៗដែរ។ លើសពីនេះ ខ្ញុំក៏បានថតរូបទុកជាអនុស្សាវរីយ៍ជាមួយលោកគ្រូអ្នកគ្រូដែរ។





ខ្ញុំឈ្មោះ ជួរ ដានុត ភេទប្រុស អាយុ១៧ឆ្នាំ គឺជាយុវជនស្ម័គ្រចិត្តនៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ខ្ញុំយល់ឃើញថាវគ្គបណ្តុះបណ្តាលផ្ទាល់បែបនេះ គឺល្អជាងការរៀនតាមហ្សូម ឬតាមអនឡាញ។ ការបង្ហាត់បង្រៀនដោយផ្ទាល់ដល់អ្នកស្ម័គ្រចិត្តដូចជាខ្ញុំ គឺពេលខ្ញុំឆ្ងល់ ឬស្រពិចស្រពិលមិនយល់ត្រង់ណាមួយ ខ្ញុំអាចសួរបានភ្លាមៗ ឬអាចទំនាក់ទំនងគ្នាដើម្បីដោះស្រាយបញ្ហាបានភ្លាមៗ។ ខ្ញុំចាប់អារម្មណ៍មួយទៀត ជាពិសេសនៅពេលការងារស្ម័គ្រចិត្តបីខែខាងមុខត្រូវបានបញ្ចប់ អ្នកស្ម័គ្រចិត្តអាចមានឱកាសធ្វើដំណើរទស្សនកិច្ចតាមរថភ្លើងថែមទៀត។ ការងារស្ម័គ្រចិត្តរយៈពេលបីខែនឹងជួយដល់យុវជន និងសិស្សនុសិស្ស ដែលសេសសល់ពេលវេលាពីការសិក្សាដើម្បីជួយដល់សង្គម និងចេះរកប្រាក់ផ្គត់ផ្គង់ការសិក្សាខ្លួនឯងផងដែរ។ មួយវិញទៀត ការបណ្តុះបណ្តាលយុវជនផ្ទាល់ដល់មូលដ្ឋាន គឺផ្តល់ភាពងាយស្រួលកាន់តែខ្លាំងដល់យុវជន។



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ចំនួន៨៣នាក់ ដើម្បីពង្រឹងសមត្ថភាពដល់យុវជននៅក្នុងការសម្ភាសន៍ ស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងប្រមូលព័ត៌មានទាក់ទងនឹងស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងពេលបច្ចុប្បន្ន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្ម

## រៀបចំវគ្គបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តជំនាន់ទី៨

**ឌី ស៊ីថា**



*នៅព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តជំនាន់ទី៨ វគ្គទី១ ចំនួន៦១ ក្នុងនោះមានស្រី៥៦នាក់ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បាន រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តជំនាន់ទី៨ វគ្គទី១ ចំនួន៦១ ក្នុងនោះមានស្រី៥៦នាក់ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ គោលបំណងនៃការរៀបចំវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីបង្កើនចំណេះដឹងផ្នែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្នែកសម្ភាសន៍ និងការងារសំខាន់ៗដែលអ្នកស្ម័គ្រចិត្តត្រូវធ្វើការជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមមូលដ្ឋានរបស់ខ្លួន។



នៅព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំកម្មវិធីបណ្ដុះបណ្ដាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តជំនាន់ទី៨ វគ្គទី១ ចំនួន៦១ ក្នុងនោះមានស្រី៥៦នាក់ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាកិច្ចចាប់ផ្ដើម លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើការណែនាំខ្លួនក្រុមការងារ និងសង្ខេបអំពីប្រវត្តិមជ្ឈមណ្ឌលឯកសារកោះថ្ម។ បន្ទាប់មក លោក ឡុង ដានី បានដឹកនាំអ្នកស្ម័គ្រចិត្តជំនាន់ទី៨ ទាំងអស់ដើរទស្សនាពិព័រណ៍រូបថត ដែលបានដាក់តាំងបង្ហាញនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលមាន១៣៣ រូបថត ៣៨រូបគំនូរ និងមានផែនទីចំនួន៦។ ដោយចាប់ផ្ដើមបង្ហាញពីបណ្ដុំរូបថតសង្គ្រាមនៅចុងទសវត្សរ៍ ឆ្នាំ (១៩៦០-១៩៧៥) បណ្ដុំរូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) បណ្ដុំរូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ បណ្ដុំរូបថតអំពីភស្តុតាងឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូប ចេញទៅប្រទេសវៀតណាមកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីវាយផ្ដួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជា។

ជាកិច្ចបន្ត លោក ឡុង ដានី បានធ្វើបទបង្ហាញប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដោយចាប់ផ្ដើមពីពាក្យថា ខ្មែរក្រហម និងការអនុវត្តគោលនយោបាយ៨ចំណុចរបស់ខ្មែរក្រហម ៖

១) ជម្លៀសប្រជាជនចេញពីទីក្រុង ភ្នំពេញ និងទីប្រជុំជន។ លោក ដានី បានពន្យល់បន្ថែមថា ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំមាន ៣ ដំណាក់កាលគឺ ៖

- ដំណាក់កាលទី១) ការជម្លៀសប្រជាជនដោយបង្ខំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
- ដំណាក់កាលទី២) គឺបន្ទាប់ពីជម្លៀសប្រជាជនលើកទី១ រំលងបាន ២ទៅ៣ខែ ការជម្លៀសប្រជាជនតាមរថភ្លើងលើកទីពីរ២ បានចាប់ផ្ដើមដោយចេញពីភូមិភាគនិរតី ភូមិភាគបស្ចិម ទៅកាន់ភូមិភាគពាយ័ព្យ រួមមាន៖ ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។



នៅព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំកម្មវិធីបណ្ដុះបណ្ដាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តជំនាន់ទី៨ វគ្គទី១ ចំនួន៦១ ក្នុងនោះមានស្រី៥៦នាក់ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







- ដំណាក់កាលទី៣) គឺការជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ាទៅកាន់ភូមិភាគពាយ័ព្យ ភូមិភាគកណ្ដាល និងភូមិភាគឧត្តរ។ ខ្មែរក្រហមបានចោទប្រកាន់ប្រជាជនភូមិភាគបូព៌ាថា ជាមនុស្សក្បាលយួនខ្លួនខ្មែរ ។

២) បំបាត់ផ្សារ និងរូបិយវត្ថុ
៣) កម្ទេចវត្តអារាម និងផ្សឹកព្រះសង្ឃ
៤) បិទសាលារៀន និងគ្រឹះស្ថានសិក្សា
៥) បង្កើតសហករណ៍
៦) ផ្ដាច់ទំនាក់ទំនង និងបំបែកបំបាក់ក្រុមគ្រួសារ
៧) សម្លាប់បញ្ញវន្តមន្ត្រីរាជការ និងប្រជាជនស្លូតត្រង់
៨) បណ្ដេញជនជាតិវៀតណាម និងធ្វើសង្គ្រាមជាមួយវៀតណាម

## មូលហេតុនៃការដួលរលំនៃរបបខ្មែរក្រហមមាន៖

១) ស្ថានភាពសុខភាពរបស់ប្រជាជនទ្រុឌទ្រោម
២) បន្សុទ្ធកម្ម (សម្លាប់រង្គាល)

៣) ការប៉ះទង្គិចជាមួយប្រទេសវៀតណាម

**ផលប៉ះពាល់ក្រោយរបបខ្មែរក្រហមមកលើសង្គមកម្ពុជា ៖**

១) បន្សល់ស្ត្រីមេម៉ាយ និងក្មេងកំព្រារាប់ពាន់នាក់

២) ប្រជាជនមានជំងឺបាក់ស្បាត ការចំណាកស្រុក និងជនភៀសខ្លួន

៣) បន្សល់ទុកគ្រាប់មីនរាប់លានគ្រាប់

៤) អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ

៥) សេដ្ឋកិច្ចធ្លាក់ដល់កម្រិតសូន្យ

៦) ពុំមានអ្នកចេះដឹងច្រើនសម្រាប់ជួយអភិវឌ្ឍន៍ប្រទេស

ជាកិច្ចបន្ទាប់ លោក ឈុំ វ៉ា ធ្វើបទបង្ហាញទៅកាន់អ្នកស្ម័គ្រចិត្តជំនាន់ទី៨ ស្តីអំពីគម្រោងមុនពេលចុះទៅសម្ភាសន៍ ដើម្បីឲ្យអ្នកស្ម័គ្រចិត្តត្រៀមខ្លួនមុនពេលចុះទៅជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងវិធីសាស្ត្រខ្លះៗដើម្បីដោះស្រាយបញ្ហាដែលជួបប្រទះពេលចុះទៅជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ គម្រោងដែលអ្នកស្ម័គ្រចិត្តត្រូវធ្វើមុនពេលចុះទៅសម្ភាសន៍រួមមាន៖

១) ទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន

២) គិតទុកមុនអំពីចំនួនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលត្រូវចុះជួបដែលមានអាយុចាប់ ពី៥៥ឆ្នាំ ឡើងទៅ

៣) មានឧបករណ៍ថតសំឡេង ប៊ិក សៀវភៅ និងតារាងស្នាបស្ទង់មតិ

៤) សំណួរចំនួន២ ដែលអ្នកស្ម័គ្រចិត្តចាំបាច់ត្រូវតែសួរគឺ ៖

- តើរឿងរ៉ាវអ្វីខ្លះដែល យាយ តា ពុក ម៉ែ អ៊ំ ពូមីង ចងចាំមិនភ្លេចក្នុងរបបខ្មែរក្រហម?
- តើស្ថានភាពសុខភាពរបស់យាយ តា ពុក ម៉ែ អ៊ំ ពូ មីង នាពេលបច្ចុប្បន្នដូចម្តេច?

៥) អ្នកស្ម័គ្រចិត្តត្រូវសួរនាំអំពីជីវប្រវត្តិរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបំបែកសំណួរទៅតាមអ្វីដែលខ្លួនចង់ដឹង

៦) បើជួបបញ្ហាត្រូវរកដំណោះស្រាយឲ្យបានចំនួន៣យ៉ាងតិច

៧) ការសង្កេតរបស់អ្នកស្ម័គ្រចិត្ត

ជាកិច្ចបន្តលោក ឈុំ វ៉ា បានបង្ហាញពីរបៀបបំពេញតារាងស្នាបស្ទង់មតិ ស្តីពីការយល់ឃើញរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអំពីផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ និងសុខភាពដែលក្នុងនោះមាន២៣សំណួរ និងរបៀបសង្ខេបសាច់រឿងខ្លះៗទៅដល់អ្នកស្ម័គ្រចិត្ត ដើម្បីឲ្យពួកគាត់បានដឹងខ្លះៗអំពីរបៀបសរសេររឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ជាចុងក្រោយលោក ឈុំ វ៉ា បានប្រាប់អ្នកស្ម័គ្រចិត្តថាយើងម្នាក់ៗត្រូវផ្ញើឯកសារអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលខ្លួនបានជួបសម្ភាសន៍មកក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្មដូចខាងក្រោម៖

១) តារាងស្នាបស្ទង់មតិដែលបានបំពេញរួចរាល់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

២) បទសម្ភាសន៍ជាសំឡេង របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

៣) រូបថតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

៤) វីដេអូរខ្លីៗទាក់ទងរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

នៅក្នុងឱកាសនោះ កញ្ញា ម៉ាប់ ស៊ីណា ក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្ម បានប្រាប់អ្នកស្ម័គ្រជំនាន់ទី៨ អំពីឯកសារដែលត្រូវផ្ញើមកកាន់ក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្មឲ្យបានគ្រប់លក្ខខណ្ឌ និងថ្ងៃដែលឈប់ទទួលឯកសារ។ ចុងក្រោយ កញ្ញា វន បុប្ផា ក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើបទបង្ហាញអំពីការថតចម្លងឯកសារតាមកម្មវិធី Camscanner ក្នុងទូរសព្ទ និងរបៀបបំពេញតារាងលទ្ធផលការងារប្រចាំសប្តាហ៍របស់អ្នកស្ម័គ្រចិត្តរួចផ្ញើមកក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្មតាមកម្មវិធី Onedrive ។

# មជ្ឈមណ្ឌលឯកសារខេត្តតាកែវ

## រៀបចំវគ្គបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តជំនាន់ទី៨

**ដោយ ពង្សរ៉ាស៊ី និង ចាន់ ឌីន**



ពីថ្ងៃទី៩ ដល់ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវរៀបចំវគ្គបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ចំនួន៥៣នាក់ មុនចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមមូលដ្ឋាននៃស្រុកព្រៃកប្បាស, ស្រុកបាទី, ស្រុកកោះអណ្តែត, ស្រុកបូរីជលសារ, ស្រុកត្រាំកក់, ស្រុកទ្រាំង និងក្រុងដូនកែវ នៃខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី៩ និងទី១០ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ចំនួន៥៣នាក់ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដើម្បីពង្រឹងសមត្ថភាព និងចំណេះដឹងទាក់ទងនឹងប្រវត្តិសាស្ត្រនៅមុនពេលចុះទៅអនុវត្តសកម្មភាពការងារ និងជួបសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតាមមូលដ្ឋាននៃស្រុកព្រៃកប្បាស, ស្រុកបាទី, ស្រុកកោះអណ្តែត, ស្រុកបូរីជលសារ, ស្រុកត្រាំកក់, ស្រុកទ្រាំង និងក្រុងដូនកែវ នៃខេត្តតាកែវ។ នៅអំឡុងពេលវគ្គបណ្តុះបណ្តាល អ្នកស្ម័គ្រចិត្តទាំងអស់ទទួលបានសំណុំឯកសារម្នាក់មួយកញ្ចប់ ដែលនៅក្នុងកញ្ចប់នោះមាន៖ កម្រងសំណួរសម្រាប់សម្ភាសន៍ចំនួន១ច្បាប់,

ទស្សនាវដ្ដីស្វែងរកការពិតចំនួន១ច្បាប់, មេរៀនស្ដីអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរក្រហមសង្ខេបចំនួន១ច្បាប់, តារាងលទ្ធផលការងារប្រចាំសប្ដាហ៍ចំនួន១៥ច្បាប់, អាវយឺតចំនួន១ និងមួកចំនួន១។

ជាកិច្ចចាប់ផ្ដើមនៃវគ្គបណ្ដុះបណ្ដាលនៅពេលព្រឹក លោកដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានផ្ដល់ឱកាសឲ្យអ្នកស្ម័គ្រចិត្តចូលរួមការពិភាក្សា និងលើកឡើងធ្វើបទបង្ហាញអំពី មាតិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយសង្ខេបដោយផ្ដោតសំខាន់លើព្រឹត្តិការណ៍ផ្លាស់ទីលំនៅរបស់ប្រជាជនកម្ពុជាដោយបង្ខំ, ការលុបបំបាត់រូបិយប័ណ្ណ សាសនា ទីផ្សារ និងការអប់រំ, ការបង្កើតសហករណ៍និងការដ្ឋានការងារ, ការកម្ចាត់សត្រូវវណ្ណៈ, ការបណ្ដេញជនជាតិវៀតណាម និងការបញ្ជូនកងទ័ពទៅតាមព្រំដែន ជាពិសេសព្រំដែនកម្ពុជា-វៀតណាម។ បន្ទាប់មក លោក ដេង ពង្សរ៉ាស៊ី បង្ហាញពីវិធីសាស្ត្រក្នុងការចុះទៅជួបអាជ្ញាធរមូលដ្ឋាន និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាគោលដៅក្នុងការធ្វើបទសម្ភាសន៍។

នៅពេលរសៀល គឺជាការបង្ហាញអំពីវិធីសាស្ត្រក្នុងការប្រមូលឯកសារ និងការបញ្ជូនឯកសារដែលជាលទ្ធផលការងាររបស់អ្នកស្ម័គ្រចិត្តម្នាក់ៗ ដែលបានសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងការអនុវត្តជាក់ស្ដែងពីវិធីប្រើប្រាស់បច្ចេកវិទ្យាសម្រាប់បញ្ជូនឯកសារពីចម្ងាយចូលទៅក្នុង «សំណុំឯកសារ» របស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ ចុងបញ្ចប់នៃវគ្គបណ្ដុះបណ្ដាលនេះ អ្នកស្ម័គ្រចិត្តទាំងអស់ បានបង្ហាញពីការទទួលបានចំណេះដឹងទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម, វិធីសាស្ត្រទំនាក់ទំនង, វិធីសាស្ត្រអនុវត្តសកម្មភាពការងារ, វិធីសាស្ត្រសម្ភាសន៍, ការប្រើប្រាស់កម្រងសំណួរនិងសំណួរស្រាវជ្រាវ ព្រមទាំងវិធីសាស្ត្របញ្ជូនឯកសារដោយមិនចាំបាច់យកឯកសារដែលជាលទ្ធផលការងាររបស់ខ្លួន ដូចជា កិច្ចសម្ភាសន៍ជាសំឡេង, រូបថត, និងសេចក្ដីសង្ខេប មកកាន់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវដោយផ្ទាល់ឡើយ។

ដើម្បីធ្វើកិច្ចការនេះបានជោគជ័យ ដំបូងបង្អស់ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានបង្កើតតំណភ្ជាប់ «សំណុំឯកសារ (Folder)» សម្រាប់អ្នកស្ម័គ្រចិត្តម្នាក់ៗ រួចផ្ញើ «សំណុំឯកសារ» នោះតាមប្រព័ន្ធតេឡេក្រាម ទៅកាន់អ្នកស្ម័គ្រចិត្តជាបុគ្គល ដើម្បីរក្សាទុកជា «សំណុំឯកសារ» ផ្ទាល់ខ្លួន។ បន្ទាប់មក អ្នកស្ម័គ្រចិត្តត្រូវបានបង្រៀនអំពីវិធីក្នុងការប្រើប្រាស់ «សំណុំឯកសារ» នោះ។ អ្នកស្ម័គ្រចិត្តក៏ត្រូវបានបង្រៀនផងដែរ អំពីវិធីបញ្ជូនឯកសារតាមប្រព័ន្ធអ៊ីនធើណែតតាមរយៈការប្រើប្រាស់កម្មវិធីក្នុងទូរសព្ទដៃមួយចំនួន ដូចជា កម្មវិធី Camscanner, Google Drive, និង Onedrive ។

អ្នកស្ម័គ្រចិត្តទាំងអស់ បានប្រាប់ថា ខ្លួនមានមូលដ្ឋានគ្រឹះក្នុងការចុះទៅអនុវត្តការងារ និងមានភាពជឿជាក់លើសមត្ថភាពរបស់ខ្លួន។

អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨របស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ភាគច្រើនជាក្រុមនិស្សិតដែលកំពុងសិក្សានៅវិទ្យាល័យ កំពុងបន្តការសិក្សាថ្នាក់សាកលវិទ្យាល័យ និងបានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យនានា ហើយសមត្ថភាពរបស់អ្នកទាំងនោះត្រូវបានមើលឃើញថា គ្រប់គ្រាន់ ក្នុងការចុះទៅធ្វើការងារជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម



ពីថ្ងៃទី៩ ដល់ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវរៀបចំវគ្គបណ្ដុះបណ្ដាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដល់អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ចំនួន៥៣នាក់ មុនចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមមូលដ្ឋាននៃស្រុកព្រៃកប្បាស, ស្រុកបាទី, ស្រុកកោះអណ្ដែត, ស្រុកបូរីជលសារ, ស្រុកត្រាំកក់, ស្រុកទ្រាំង និងក្រុងដូនកែវ នៃខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ពីថ្ងៃទី៩ ដល់ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវរៀបចំវគ្គបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដល់អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ចំនួន៥៣នាក់ មុនចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមមូលដ្ឋាននៃស្រុកព្រៃកប្បាស, ស្រុកបាទី, ស្រុកកោះអណ្តែត, ស្រុកបូរីជលសារ, ស្រុកត្រាំកក់, ស្រុកទ្រាំង និងក្រុងដូនកែវ នៃខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បានល្អប្រសើរ។ ម្យ៉ាងទៀត អ្នកស្ម័គ្រចិត្តទាំងនោះក៏មានចំណេះដឹងច្រើនទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យា និងកម្មវិធីទូរសព្ទ។

ខាងក្រោមគឺជាចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តជំនាន់ទី៨ នៅខេត្តតាកែវ បន្ទាប់ពីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ៖

ខ្ញុំឈ្មោះ **យូ សុភា** ភេទប្រុស អាយុ២៧ឆ្នាំ សព្វថ្ងៃខ្ញុំរស់នៅភូមិសម្តេចពាន់ ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំសប្បាយចិត្តដែលបានចូលរួមវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត ព្រោះបានដឹងពីកិច្ចការថ្មីៗ និងដឹងពីរបបខ្មែរក្រហមបានច្រើនជាងមុន បន្ទាប់ពីបានស្តាប់គ្រូខេមរេស្វើប ទបង្ហាញ។

នាងខ្ញុំឈ្មោះ **ងឹម ស្រីនិច** គឺជាអ្នកស្ម័គ្រចិត្តជំនាន់ទី៧ ដែលបានបន្តធ្វើអ្នកស្ម័គ្រចិត្តជំនាន់ទី៨ទៀត។ ខ្ញុំមានអាយុ២២ឆ្នាំ និងកំពុងសិក្សាជំនាញ អក្សរសាស្ត្រខ្មែរ-ប្រវត្តិ នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្នោរ ឃុំស្នោរ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ បន្ទាប់ពីខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តជំនាន់ទី៨ នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវរយៈពេលមួយថ្ងៃនេះ ខ្ញុំបានដឹងអំពីប្រវត្តិសាស្ត្រច្រើនបន្ទាប់ពីគ្រូខេមរេស្វបានបង្ហាញពីឯកសារ និងរៀបរាប់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំគឺជាក្មេងជំនាន់ក្រោយបានដឹងអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ទោះបីជាខ្ញុំមិនបានឆ្លងកាត់ក្នុងរបបនោះក៏ដោយ។ បន្ថែមលើនេះ ខ្ញុំទទួលបានចំណេះដឹងថ្មីៗដើម្បីធ្វើជាមូលដ្ឋានក្នុងការចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិ និងយល់ដឹងពីការរៀបឥរិយាបថនៅពេលចុះទៅសម្ភាសន៍។ ខ្ញុំសប្បាយរីករាយដែលបានចូលរួមវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តជំនាន់ទី៨។ ខ្ញុំទទួលបានទាំងចំណេះដឹង និងបទពិសោធន៍ការងារបន្ថែមទៀត។ នាងខ្ញុំចង់ឲ្យមានវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តលើកក្រោយទៀត ព្រោះពេលយើងចុះធ្វើការតាមមូលដ្ឋាន គឺទាមទារនូវបទពិសោធន៍ក្នុងការអនុវត្តការងារ។ ជាចុងក្រោយ ការចូលរួមវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តពេញមួយថ្ងៃនេះ គឺទី១) ទទួលចំណេះដឹងប្រវត្តិសាស្ត្រ, ទី២) ឥរិយាបថក្នុងការធ្វើការងារ និងទី៣) ទាក់ទឹងកម្រងសំណួរពាក់ព័ន្ធជាមួយនឹងការងារ។

នាងខ្ញុំឈ្មោះ **សាន ចរណ្ណាត** អាយុ១៩ឆ្នាំ គឺជានិស្សិតឆ្នាំទី២ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ

ឯកទេសគណិតវិទ្យា។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្នោរ ឃុំស្នោរ ស្រុកព្រែកប្រាស ខេត្តក្រចេះ។ ខ្ញុំមានអារម្មណ៍រំភើប និងសប្បាយរីករាយ ព្រោះខ្ញុំមិនធ្លាប់បានចូលរួមប្រជុំ ឬ ក៏ចូលរួមវគ្គសិក្សាណាមួយដូចថ្ងៃនេះឡើយ។ បន្ថែមលើនេះ ខ្ញុំបានទទួលបានចំណេះដឹងប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន ដឹងពីទុក្ខលំបាករបស់អ៊ំពូមីងដែលបានឆ្លងកាត់របបខ្មែរក្រហម។ ការងារស្ម័គ្រចិត្តពិតជាមានសារសំខាន់ ដែលធ្វើឲ្យខ្ញុំទទួលបាននូវបទពិសោធន៍ថ្មីៗ និងចំណេះដឹងក្នុងការទំនាក់ទំនង ចំណែកអ្នកភូមិទទួលបានអត្ថប្រយោជន៍ដូចគ្នា គឺគាត់ទទួលបានការពិនិត្យសុខភាព។

នាងខ្ញុំឈ្មោះ **ហ៊ុន ឃីនលី** អាយុ២២ឆ្នាំ គឺជានិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិទន្លេ ឃុំស្នោ ស្រុកព្រែកប្រាស ខេត្តក្រចេះ។ ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលក្នុងថ្ងៃនេះ នាងខ្ញុំទទួលបានកម្រងសំណួរទាំង១៩ ដើម្បីត្រៀមខ្លួនចុះទៅសម្ភាសន៍តាយាយ អ៊ំ ពូមីង ដែលរស់នៅភូមិឃុំរបស់ខ្ញុំ។ម្យ៉ាងទៀត វគ្គបណ្តុះបណ្តាលនេះធ្វើឲ្យខ្ញុំទទួលបានចំណេះដឹង ទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យា។ លោកគ្រូខ្មែស ក៏បានបង្ហាញអំពីអំពើប្រល័យពូជសាសន៍ដែលប្រជាជនកម្ពុជាធ្លាប់បានឆ្លងកាត់ ទើបធ្វើឲ្យខ្ញុំបានយល់ដឹងបន្ថែមអំពីរបបខ្មែរក្រហម។ វគ្គបណ្តុះបណ្តាលនេះពិតជាមានសារសំខាន់សម្រាប់ខ្ញុំ ព្រោះខ្ញុំបានដឹងកាន់តែច្បាស់អំពីរបបប្រល័យពូជសាសន៍ អំពើឃោរឃៅ ដែលធ្វើឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានការឈឺចាប់។ ខ្ញុំសប្បាយរីករាយដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះ និងចង់ឲ្យមានវគ្គបណ្តុះបណ្តាលនេះបន្តទៅថ្ងៃក្រោយទៀត ព្រោះធ្វើក្មេងៗជំនាន់ក្រោយចងចាំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតឡើងម្តងទៀត។

ខ្ញុំឈ្មោះ **គិន មករា** អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់។ បន្ទាប់ពីខ្ញុំបានចូលវគ្គបណ្តុះបណ្តាលជំនាន់ទី៨ នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ រយៈពេលមួយថ្ងៃនេះ ខ្ញុំទទួលបានចំណេះដឹងពីរបបខ្មែរក្រហម ការចុះទៅសម្ភាសន៍ និងឥរិយាបថនៃការចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅក្នុងភូមិឃុំរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍រំភើប និងសប្បាយចិត្តដែលបានចូលរួមវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត ព្រោះខ្ញុំទទួលបានមេរៀនថ្មីៗជាច្រើនក្នុងថ្ងៃនេះ។ ការចូលរួមវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តពេញមួយថ្ងៃនេះ ធ្វើឲ្យខ្ញុំទទួលបានបទពិសោធន៍ថ្មីៗ។ លើសពីនេះ វគ្គបណ្តាលក៏មានសារសំខាន់សម្រាប់ក្មេងជំនាន់ក្រោយ ព្រោះបានជួបសម្ភាសន៍ផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ខ្ញុំឈ្មោះ **ញ៉ុក សុខហេង** អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់។ ខ្ញុំទទួលបានបទពិសោធន៍ថ្មី, ទទួលចំណេះដឹងបន្ថែមទៀតពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដឹងពីរបៀបនៃការចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំសប្បាយចិត្តដែលបានសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ឬរបបខ្មែរក្រហម។ វគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តក្នុងថ្ងៃនេះមានសារសំខាន់ព្រោះធ្វើឲ្យក្មេងជំនាន់ក្រោយបានយល់ដឹងពីរបបខ្មែរក្រហមកាន់តែច្បាស់, ដឹងពីវិធីសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទទួលបានប្រាក់ឧបត្ថម្ភខ្លះៗសម្រាប់ការសិក្សារៀនសូត្រ។



ពីថ្ងៃទី៩ ដល់ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវរៀបចំវគ្គបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ចំនួន៥៣នាក់ មុនចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមមូលដ្ឋាននៃស្រុកព្រែកប្រាស, ស្រុកបាទី, ស្រុកកោះអណ្តែត, ស្រុកបូរីជលសារ, ស្រុកត្រាំកក់, ស្រុកទ្រាំង និងក្រុងដូនកែវ នៃខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្ដួលផ្សារ ចូលរួមវេទិកាថ្នាក់រៀនស្ដីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ»

ផ្សុង ជានី



នៅព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្ដីអំពី "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ" ដល់សិស្សានុសិស្សចំនួន៣១នាក់ ក្នុងនោះមានស្រី២៨នាក់ មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្ដួលផ្សារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀនស្ដីអំពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» ដែលផ្ដោតសំខាន់ទៅលើប្រធានបទការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅ ទួលពោធិ៍ជ្រៃ។ គោលបំណងនៃការរៀបចំវេទិកានេះ គឺចង់ឲ្យយុវជនរៀនសូត្របន្ថែមពីបរិបទប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងនិយមន័យការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងកត្តាគ្រោះថ្នាក់នានាដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍នាពេលអនាគត។ វេទិកានេះនឹងធ្វើឲ្យយុវជនអាចផ្លាស់



នៅព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី "ប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ" ដល់សិស្សានុសិស្សចំនួន ៣១នាក់ ក្នុងនោះមានស្រី២៨នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន គុលផ្សារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







ប្តូរការគិតពីការប្រព្រឹត្តអំពើហិង្សា មកជាការកសាងសន្តិភាព ក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។ វេទិកាថ្នាក់រៀននេះមានយុវជនចូលរួមចំនួន៣១នាក់ ក្នុងនោះស្រីមានចំនួន២៨នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន គុលផ្សារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ជាកិច្ចចាប់ផ្តើមលោក ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មបានដឹកនាំយុវជនដើរទស្សនាពិព័រណ៍រូបថត ស្តីពីសង្គ្រាមកាលពីចុងទសវត្សរ៍ឆ្នាំ១៩៦០ រូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ រូបថតភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សម្តេច

គេដោ ហ៊ុនសែន និងយុទ្ធមិត្ត៤រូបទៀត ទៅប្រទេសវៀតណាមនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) ដោយផ្តោតលើប្រធានបទការជម្លៀសប្រជាជនចេញពីទីក្រុង ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ លោក ឡុង ដានីបានលើកឡើងថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំមានបីដំណាក់កាល ៖

**ដំណាក់កាលទី១**) ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីក្រុងនានាចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

**ដំណាក់កាលទី២**) ការផ្លាស់ទីប្រជាជននៅតាមទីជនបទ ក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា (រួមបញ្ចូលទាំងការផ្លាស់ទីតាមរថភ្លើងពីភូមិភាគនិរតី និងភូមិភាគបស្ចិម ទៅកាន់ភូមិភាគពាយ័ព្យ) ចាប់តាំងពីចុងឆ្នាំ១៩៧៥។

**ដំណាក់កាលទី៣**) ការផ្លាស់ទីប្រជាជនចេញពីភូមិភាគបូព៌ានៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ លោកបានបញ្ជាក់បន្ថែមទៀតថា កាលពី៤៩ឆ្នាំមុន គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ។ នៅខណៈពេលខ្មែរក្រហមមកដល់ទីក្រុងភ្នំពេញបានរយៈពេលតែ២ទៅ៣ម៉ោង មេដឹកនាំខ្មែរក្រហមបានបញ្ជាឲ្យកងទ័ពរបស់ខ្លួនជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីក្រុងនានាទៅធ្វើការងារពលកម្មដ៏លំបាកវេទនានៅតាមវាលស្រែនៃតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។ កងទ័ពខ្មែរក្រហមបានយកលេសដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់នៅទីក្រុងភ្នំពេញ ប្រជាជនត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញតែរយៈពេល៣ថ្ងៃ នឹងបានវិលត្រឡប់មកផ្ទះវិញ ដូច្នេះប្រជាជនទាំងអស់មិនចាំបាច់យកទ្រព្យសម្បត្តិច្រើនទៅតាមខ្លួននិងចាក់សោផ្ទះទេ។ ប៉ុន្តែការពិត ខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនត្រឡប់មកផ្ទះវិញពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)។

បន្ទាប់ពីដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនជម្លៀសច្រើនលើសលប់បានស្លាប់ដោយសារការសម្លាប់ ធ្វើការងារហួសកម្លាំង និងអត់អាហារ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរកឃើញថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញយ៉ាងហោចណាស់ចំនួនប្រហែល២លាននាក់ រួមមាន៖ បុរស ស្ត្រី មនុស្សចាស់ ក្មេង ព្រះសង្ឃ វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា អ្នកជំងឺ អ្នករបួស ស្ត្រីទើបសម្រាលកូន។ ប្រជាជនទាំងនោះមិនត្រូវបានខ្មែរក្រហមផ្តល់កន្លែងស្នាក់នៅ និងស្បៀងអាហារហូបចុកគ្រប់គ្រាន់ ដែលជាហេតុនាំឲ្យមានការលំបាកវេទនា និងស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់។

តាមការប៉ាន់ប្រមាណ មានប្រជាជនចំនួនចន្លោះពី២ពាន់ ទៅ២ម៉ឺននាក់ បានស្លាប់បាត់បង់ជីវិតនៅអំឡុងពេលបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ និងការធ្វើដំណើរតាមផ្លូវទៅកាន់ទីជនបទនានា។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរួមមាន នួន ជា និង ខៀវ សំផន ត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជា ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ រួមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នួន ជា និង ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។

នៅក្នុងឱកាសនោះ សិស្សានុសិស្សនៃវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន គួលផ្សារ មានការយកចិត្តស្តាប់

រាល់ការធ្វើបទបង្ហាញរបស់ក្រុមការងាររមជ្ឈ-មណ្ឌលឯកសារកោះថ្ម រួមទាំងពិព័ររូបថត រូបគំនូរ រូបផែនទីនៅលើដញ្ហាំង និងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ សិស្សានុសិស្សបានកត់ត្រាចំណុចសំខាន់ៗ និងសួរសំណួរទៅកាន់លោកឡុង ដានី អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីបកស្រាយសំណួរចប់ដែលធ្វើឲ្យសិស្សានុសិស្សកាន់តែមានសកម្មភាពផុសផុល និងមានភាពស្និតស្នាល។ បន្ថែមពីលើនេះ សិស្សានុសិស្សក៏បង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

នាងខ្ញុំឈ្មោះ **ហុង ស្រីនុត** គឺជាសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលដង្ហាវ។ ក្នុងនាមខ្ញុំជាកូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយរូប បន្ទាប់ពីបានស្តាប់ លោកគ្រូឧទ្ទេស ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានធ្វើបទបង្ហាញរួចមក ខ្ញុំយល់ឃើញថា នៅសម័យកម្ពុជាប្រជាធិបតេយ្យពិតជាឃោរឃៅខ្លាំងណាស់ សម្រាប់ប្រជាជនស្លូតត្រង់ ប្រើឲ្យធ្វើការច្រើនម៉ោងក្នុងមួយថ្ងៃ បំបែកបំបាក់ក្រុមគ្រួសារ មិនឲ្យរស់នៅជួបជុំគ្នា មិនឲ្យហូបគ្រប់គ្រាន់ និងពេលឈឺគ្មានថ្នាំព្យាបាល។ របបខ្មែរក្រហមបន្សល់ទុកស្ត្រីមេម៉ាយ ជនពិការជាច្រើននាក់ ដែលធ្វើឲ្យប្រទេសកម្ពុជាធ្លាក់ក្នុងភាពក្រីក្រជាច្រើនឆ្នាំ។ ក្នុងនាមខ្ញុំជាក្មេងជំនាន់ក្រោយ ខ្ញុំត្រូវតែខិតខំសិក្សារៀនសូត្រឲ្យមានចំណេះដឹងទូលំទូលាយ ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ និងលុបបំបាត់នូវការរើសអើងផ្សេងៗ ជាពិសេស គឺការលុបបំបាត់អំពើហិង្សាគ្រប់ទម្រង់ទាំងអស់។ ជាចុងក្រោយ នាងខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានរៀបចំកម្មវិធីនេះឡើងដែលធ្វើឲ្យខ្ញុំយល់ដឹងច្រើនពីរបបកម្ពុជាប្រជាធិបតេយ្យ។

នាងខ្ញុំឈ្មោះ **លីន ស៊ីវម៉ី** ភេទស្រី គឺជាសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលដង្ហារ។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយខ្លាំងណាស់ដែលបានមកចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ នៅពេលដែលខ្ញុំមកដល់ ខ្ញុំបានឃើញរូបភាពពិព័រណ៌ជាច្រើន ហើយលោកគ្រូឧទ្ទេសបានណែនាំខ្ញុំជាក្មេងជំនាន់ក្រោយឲ្យបានដឹងអំពីរបបខ្មែរក្រហមដ៏ឃោរឃៅ។ ជាចុងក្រោយ ខ្ញុំចង់ឲ្យមជ្ឈមណ្ឌលឯកសារកោះថ្មរៀបចំកម្មវិធីវេទិកាថ្នាក់រៀនបន្តទៀត។



នៅព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈ-មណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ" ដល់សិស្សានុសិស្សចំនួន៣១នាក់ ក្នុងនោះមានស្រី២៨នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលដង្ហារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យមេសាង ចូលរួមបណ្តុះបណ្តាលកិច្ចការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)

## រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ផេង ពង្សរ៉ាស៊ី



នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង បានមកទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យមេសាង ស្រុកមេសាង ខេត្តព្រៃវែងបានមកទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅពេញមួយថ្ងៃជាមួយនឹងមាតិកាមួយចំនួនរួមមាន៖ ១) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ២) វិធីសាស្ត្រក្នុងការអនុវត្តកិច្ចការស្រាវជ្រាវ ៣) ការជ្រើសរើសប្រធានបទស្រាវជ្រាវ ៤) ការបែងចែកក្រុមស្រាវជ្រាវ ៥) ការកំណត់កាលវិភាគអនុវត្តកិច្ចការស្រាវជ្រាវ និង ៦) ការចុះទៅកាន់មូលដ្ឋានដើម្បីអនុវត្តសាកល្បងពីកិច្ចសម្ភាសន៍។

## ហេតុអ្វីបណ្តុះបណ្តាលកិច្ចការស្រាវជ្រាវ?

អត្ថបទ និងសំណេរស្រាវជ្រាវជាច្រើនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ធ្លាប់ត្រូវបានសរសេរដោយអ្នកស្រាវជ្រាវ, និស្សិតដែលនឹងត្រូវបញ្ចប់ការសិក្សា, បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ឬ មន្ត្រីរាជការនៅស្ថាប័នពាក់ព័ន្ធ។ ប៉ុន្តែយើងពុំទាន់ឃើញមានការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហមដោយក្មេងៗ ដែលជាសិស្សកម្រិតវិទ្យាល័យនៅឡើយទេ។ ម្យ៉ាងទៀត ការសិក្សានៅកម្រិតវិទ្យាល័យអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺនៅមានកម្រិតតិចតួច ហើយការយល់ដឹងអំពីប្រវត្តិសាស្ត្រនេះតាមរយៈគ្រូបង្រៀន គឺនៅពុំទាន់គ្រប់គ្រាន់ក្នុងការឈ្វេងយល់ស៊ីជម្រៅអំពីប្រវត្តិសាស្ត្រនេះទេ។ ក្មេងៗទាំងនោះ គួរតែឈ្វេងយល់ឲ្យស៊ីជម្រៅបន្ថែមទៀតតាមការសិក្សាស្រាវជ្រាវ និងការជួបសន្ទនាជាមួយចាស់ៗនៅក្នុងភូមិ ដែលត្រូវជាជីដូនជីតា និងសាច់ញាតិរបស់ខ្លួន។ ក្មេងៗមួយចំនួននៅមិនទាន់ជឿថា របបខ្មែរក្រហមបានកើតឡើង ហើយបានសម្លាប់មនុស្សអស់រាប់លាននាក់ទេ។ ស្របពេលជាមួយគ្នានេះ ជីដូនជីតា ឬចាស់ទុំក្នុងភូមិ កាន់តែលែងមានទំនុកចិត្តក្នុងការចែករំលែកបទពិសោធន៍របស់ខ្លួនប្រាប់ទៅក្មេងៗទៀត ព្រោះក្មេងៗទាំងនោះនៅមានភាពស្ទាក់ស្ទើរក្នុងការជឿថាមានរបបខ្មែរក្រហមកាលពីអតីតកាល។

ចំណោទបញ្ហាទាំងនេះ បានជំរុញឲ្យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង គិតគូរ និងជំរុញលើកទឹកចិត្តឲ្យក្មេងៗឈ្វេងយល់អំពីវិធីសាស្ត្រស្រាវជ្រាវ ដើម្បីធ្វើការស្រាវជ្រាវពីភាពពិតប្រាកដនៅក្នុងសង្គមកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០។ ម្យ៉ាងទៀត យើងជឿជាក់ថា ការសន្ទនា និងការផ្ទេរចំណេះដឹងដែលបានមកពីការស្រាវជ្រាវផ្ទាល់របស់អ្នកស្រាវជ្រាវវ័យក្មេង ទៅកាន់មិត្តភក្តិ មិត្តរួមថ្នាក់ និងអ្នកដែលមានវ័យស្របាលគ្នា គឺមានប្រសិទ្ធភាពបំផុត។ សិស្សានុសិស្សអាចធ្វើបទបង្ហាញពីកិច្ចការស្រាវជ្រាវរបស់ខ្លួននៅក្នុងថ្នាក់ ហើយធ្វើជាម្ចាស់លើសំណេរស្រាវជ្រាវរបស់ខ្លួន។

## គោលបំណងនៃវគ្គបណ្តុះបណ្តាលគឺៈ

១) លើកកម្ពស់ការយល់ដឹងពីមាតិកាប្រវត្តិសាស្ត្រកាន់តែស៊ីជម្រៅ។
២) លើកកម្ពស់ភាពជាអ្នកដឹកនាំក្នុងកិច្ចការស្រាវជ្រាវឲ្យកាន់តែប្រសើរឡើង។
៣) បង្កើនចំណេះដឹងពីកិច្ចការស្រាវជ្រាវនៅកម្រិតវិទ្យាល័យ។
៤) បង្កើនទំនាក់ទំនងនៅក្នុងសង្គម និងការសន្ទនាអន្តរជំនាន់រវាងក្មេងៗ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
៥) កសាងប្រវត្តិសាស្ត្រភូមិដោយខ្លួនឯងដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រ។

## កម្មវិធីបណ្តុះបណ្តាលនេះគឺៈ

### ពេលព្រឹក៖

- បទបង្ហាញពីមាតិកាប្រវត្តិសាស្ត្រ «ការជម្លៀសប្រជាជនដោយបង្ខំ» និងសំណួរ-ចម្លើយ។
- បទបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ (កម្រិតបឋម) និងដំណាក់កាលនៃការចុះអនុវត្តការស្រាវជ្រាវ។
- ការជ្រើសរើសប្រធានបទស្រាវជ្រាវ និងការពិភាក្សាពីប្រធានបទ (ដែលបានជ្រើសរើសរួចហើយ)។
- បង្កើតសំណួរស្រាវជ្រាវចេញពីប្រធានបទ។
- បង្កើតសំណួរគោលចេញពីសំណួរស្រាវជ្រាវ។
- បង្កើតកម្រងសំណួរសម្រាប់សម្ភាសន៍ ចេញពីសំណួរគោល។

### ពេលរសៀល៖

- ការបែងចែកក្រុមស្រាវជ្រាវ។
- ការសម្ភាសន៍សាកល្បងជាមួយសិស្សគ្នាឯង។
- ការបែងចែកកាលវិភាគសម្រាប់កិច្ចការស្រាវជ្រាវ។
- ការចុះទៅកាន់មូលដ្ឋានដើម្បីអនុវត្តការសម្ភាសន៍សាកល្បងជាមួយអ្នករស់រានមានជីវិត។

## សកម្មភាពបណ្តុះបណ្តាល

**បទបង្ហាញពីមាតិកាប្រវត្តិសាស្ត្រ «ការជម្លៀសប្រជាជនដោយបង្ខំ»៖**



នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង បានមកទទួលការបណ្ដុះបណ្ដាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោក ផេង ពង្សរ៉ាស៊ី គឺជានាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងជាគ្រូឧទ្ទេស បានណែនាំពីវគ្គបំណងនៅក្នុងថ្ងៃនេះ និងបានបង្ហាញពីមាតិកានៃវគ្គបណ្ដុះបណ្ដាលសម្រាប់រយៈពេលមួយថ្ងៃពេញ។ មុននឹងធ្វើបទបង្ហាញពីមាតិកាប្រវត្តិសាស្ត្រខ្មែរក្រហម លោក ផេង ពង្សរ៉ាស៊ី បានផ្ដល់អនុសាសន៍ខ្លះៗទៅកាន់អ្នកចូលរួមថា ការធ្វើកិច្ចការស្រាវជ្រាវ គឺជាការដោះស្រាយចម្ងល់របស់អ្នកស្រាវជ្រាវអំពីប្រធានបទអ្វីមួយ ហើយដំណោះស្រាយដែលបានមកពីការស្រាវជ្រាវ គឺជាមេរៀនដែលគួរឈ្វេងយល់។

លោក ផេង ពង្សរ៉ាស៊ី បានចំណាយពេលវេលាជាងកន្លះម៉ោង ដើម្បីធ្វើបទបង្ហាញអំពី «ការជម្លៀសប្រជាជនដោយបង្ខំ» របស់ខ្មែរក្រហម។ បទបង្ហាញនេះ បង្ហាញពីចេតនាច្បាស់លាស់មួយរបស់គ្រូឧទ្ទេស ដើម្បីឲ្យអ្នកស្រាវជ្រាវវ័យក្មេងទាំងអស់ឈ្វេងយល់ឲ្យកាន់តែច្បាស់អំពីព្រឹត្តិការណ៍នៃការជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហម ដែលបានកើតឡើងតាំងពីមុនការចូលកាន់កាប់ប្រទេសកម្ពុជារបស់ខ្លួន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បទបង្ហាញនេះ មានគោលបំណងចង់ឲ្យអ្នកស្រាវជ្រាវវ័យក្មេងផ្ដោតការយកចិត្តទុកដាក់ទៅលើព្រឹត្តិការណ៍នៃការជម្លៀស ហើយលើកជាសំណួរផ្សេងៗដែលអាចឈានដល់ការកំណត់ប្រធានបទក្នុងការស្រាវជ្រាវ។

## បទបង្ហាញអំពីវិធីសាស្ត្រស្រាវជ្រាវ (កម្រិតបឋម) និងដំណាក់កាលនៃការចុះអនុវត្តការស្រាវជ្រាវ

លោក ផេង ពង្សរ៉ាស៊ី ចាប់ផ្ដើមការធ្វើបទបង្ហាញរបស់ខ្លួនអំពីការបង្ហាញធាតុផ្សំសំខាន់ៗចំនួនបី ដែលចាំបាច់បំផុតក្នុងការសិក្សាស្រាវជ្រាវ។ ធាតុផ្សំទាំងនោះគឺ ឯកសារ ទីតាំង និងមនុស្សដែលជាគោលដៅក្នុងការសម្ភាសន៍។ បន្ទាប់មកលោក ផេង ពង្សរ៉ាស៊ី បានបន្តទៅចំណុចផ្សេងៗទៀត រួមមាន៖ ឥរិយាបទក្នុងពេលសម្ភាសន៍, សំណួរចាំបាច់ប្រើក្នុងពេលសម្ភាសន៍, ការរៀបចំកម្រងសំណួរ, ការជ្រើសរើសគោលដៅសម្ភាសន៍, ការប្រមូលទិន្នន័យកិច្ចសម្ភាសន៍, ការធ្វើប្រតិចារិកកិច្ចសម្ភាសន៍, ការរៀបចំអត្ថបទតាមកាលបរិច្ឆេទ, ការរៀបចំគម្រោងស្រាវជ្រាវ, ការរៀបចំគម្រោងសំណេរ និងការសរសេរ។

បន្ទាប់ពីបានបង្ហាញនិងពិភាក្សាគ្នាពីចំណុចខាងលើរួចមកលោក ផេង ពង្សរ៉ាស៊ី បានផ្ដល់




*នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង បានមកទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ពេលវេលាដល់អ្នកចូលរួមលើកពីចម្ងល់ផ្សេងៗ ទាក់ទងនឹងចំណេះដឹងពីការជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហម។ លោក ផេង ពង្សរ៉ាស៊ី បានលើកជាសំណួរទៅកាន់អ្នកចូលរួមថា «តើប្អូនមានចម្ងល់អ្វីខ្លះ ទាក់ទងនឹងការជម្លៀសដោយបង្ខំ?»។ លោក ផេង ពង្សរ៉ាស៊ី បានបន្ថែមថា «ចម្ងល់របស់ប្អូនគួរតែជាចម្ងល់ដែល ទាម ទារឲ្យប្អូនធ្វើការស្រាវជ្រាវទៅលើសំណួរជាមុនសិន ទើបអាចរកចម្លើយឃើញ»។ នេះមានន័យថា សំណួរដែលនឹងត្រូវលើកឡើង គឺជាសំណួរស្រាវជ្រាវដែលផ្តោតលើវិសាល-ភាព ហេតុផល និងវិធីដែលមានព្រឹត្តិការណ៍មួយបានកើតមានឡើង។ នៅទីបំផុតសំណួរស្រាវជ្រាវមួយត្រូវបានលើកយកមកពិភាក្សា ហើយអ្នកចូលរួមទាំងអស់បានឯកភាពគ្នាក្នុងការកំណត់ប្រធានបទស្រាវជ្រាវតូចមួយ ស្តីអំពីឥទ្ធិពលនៃការជម្លៀសប្រជាជនដោយបង្ខំនៅស្រុកមេសាង។

សិស្សានុសិស្សវ័យក្មេង បាននាំគ្នារិះគិតស៊ីជម្រៅពីប្រធានបទនេះ ដោយមានការផ្តល់យោបល់ពីគ្រូខទ្ទេស និងគ្រូជំនួយម្នាក់ទៀតឈ្មោះ ប៉ុត ម៉ាក់ ដែលជាគ្រូបង្រៀនប្រវត្តិវិទ្យា។ ដំបូង សិស្សនាំគ្នាពិភាក្សាអំពី«សំណួរស្រាវជ្រាវ»។ បន្ទាប់មកពិភាក្សាអំពី«សំណួរគោល» ចេញពីសំណួរស្រាវជ្រាវ ហើយចុងក្រោយ គឺជាការពិភាក្សាអំពី«សំណួរលម្អិតមួយចំនួនសម្រាប់ការចុះទៅសម្ភាសន៍» ដែលជាផ្នែកសំខាន់ៗនៃសំណួរគោលនីមួយៗ។

នៅពេលរសៀល សិស្សទាំងអស់ត្រូវបានបែងចែកជាក្រុមៗ ដើម្បីទទួលបន្ទុកធ្វើកិច្ចការផ្សារស្រាវជ្រាវតាមផ្នែកនីមួយៗដែលជាចំណងជើងរងនៃ«ឥទ្ធិពលនៃការជម្លៀសប្រជាជនដោយបង្ខំនៅឃុំស្វាយជ្រុំ ស្រុកមេសាង» ហើយការរៀបចំកាលវិភាគសម្រាប់កិច្ចការផ្សារនេះ ក៏ត្រូវបានធ្វើឡើងផងដែរ។ បន្ទាប់មក សិស្សតាមក្រុមនីមួយៗដែលបានបែងចែករួច បានអនុវត្តការសម្ភាសន៍សាកល្បងរបស់ខ្លួនជាមួយសមាជិកក្រុម និងមានឱកាសក្នុងការចុះទៅកាន់មូលដ្ឋានជួបសម្ភាសន៍សាកល្បងជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីពង្រឹងសមត្ថភាពសម្ភាសន៍របស់ខ្លួន។

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ គ្រូខទ្ទេសបានផ្តល់យោបល់បន្ថែម ទាក់ទងនឹងការសម្ភាសន៍ថា អ្នកស្រាវជ្រាវគួរតែមានភាពឆ្លាតវៃក្នុងការសួរ និងកត់ត្រានូវអ្វីដែលជាព្រឹត្តិការណ៍សំខាន់ៗដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាននិយាយប្រាប់។ លើសពីនេះទៀត គ្រូខទ្ទេសបានរំឭកឲ្យអ្នកស្រាវជ្រាវទាំងអស់អនុវត្តតាមកាលវិភាគ ដែលបានធ្វើរួចរាល់ ដើម្បីធានាថា កិច្ចការផ្សារស្រាវជ្រាវនឹងត្រូវបញ្ចប់ទាន់ពេលវេលា និងមានគុណភាព។

*ក្រោយពីចប់វគ្គបណ្តុះបណ្តាលសិស្សានុសិស្សបាន បង្ហាញនូវចំណាប់អារម្មណ៍ ដូចខាងក្រោម៖*

## ១) ញឹម ភារក្ស



ញឹម ភារក្ស ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាង រស់នៅភូមិដីដុច ឃុំដីដុច ស្រុកមេសាង ខេត្តព្រៃវែង រៀបរាប់ថា នៅថ្ងៃនេះ ខ្ញុំពិតជារំភើបខ្លាំងណាស់ ដែលបានមកសិក្សាពីប្រវត្តិសាស្ត្រដែលខ្ញុំមិនបានកើតទាន់ និងមិនបានឃើញផ្ទាល់ភ្នែក ប៉ុន្តែទិដ្ឋភាពដែលលោកគ្រូបានពន្យល់ណែនាំ ធ្វើឲ្យខ្ញុំឈឺចាប់ប្រៀបបានដូចជារូបខ្ញុំនៅក្នុងសម័យនោះដែរ។ លោកគ្រូរបស់ខ្ញុំ បាននាំរូបខ្ញុំមកសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ចំណែកលោកគ្រូ ផេង ពង្សរ៉ាស៊ី ដែលជាគ្រូឧទ្ទេស បាននិយាយអំពីរបបប្រល័យពូជសាសន៍ឆ្នាំ១៩៧៥-១៩៧៩ និងនិយាយពីការជម្លៀសប្រជាជនដោយបង្ខំ។ លោកគ្រូ ផេង ពង្សរ៉ាស៊ី បានដាក់ការងារស្រាវជ្រាវតាមភូមិឃុំ ដែលប្រធានបទនិយាយអំពីការជម្លៀសប្រជាជន ហើយសំណួរដែលក្រុមរបស់ខ្ញុំផ្តោតសំខាន់នោះគឺ «ទាក់ទងនឹងការឈឺចាប់ផ្លូវកាយរបស់ប្រជាជន»។ សម្រាប់ប្រធានបទនេះ ខ្ញុំគិតថាល្អខ្លាំងណាស់ ព្រោះបានបង្កើនចំណេះដឹង និងបានដឹងពីរឿងរ៉ាវរបស់ចាស់ៗនៅក្នុងភូមិ។ ក្នុងនាមខ្ញុំជាសិស្សថ្នាក់ទី១២ ខ្ញុំមានការតាំងចិត្តយ៉ាងមុតមាំក្នុងការស្រាវជ្រាវពីប្រវត្តិសាស្ត្រ តាមរយៈការសិក្សាស្រាវជ្រាវពីប្រជាជននៅតាមភូមិឃុំ ហើយក៏តាំងចិត្តធ្វើការងារនេះឲ្យល្អសម្រាប់អ្នកជំនាន់ក្រោយ។

## ២) ប៊ុនធឿន សារ៉ា



ប៊ុនធឿន សារ៉ា ភេទស្រី អាយុ១៦ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាង រស់នៅភូមិប្រហ៊ូត ឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង រៀបរាប់ថា នៅថ្ងៃនេះខ្ញុំពិតជាសប្បាយរីករាយ ព្រោះខ្ញុំបានទទួលចំណេះដឹងថ្មីៗប្លែកៗ និងរីករាយក្នុងការទទួលមេរៀនពីលោកគ្រូ។ ចំពោះមេរៀនថ្ងៃនេះលោកគ្រូបង្រៀនពីការជម្លៀសប្រជាជននៅក្នុងរបបខ្មែរក្រហម ក៏ដូចជាការរៀបចំកិច្ចការស្រាវជ្រាវ។ សម្រាប់កិច្ចការស្រាវជ្រាវដែលលោកគ្រូបានដាក់ គឺការជម្លៀសប្រជាជនដោយបង្ខំ ហើយប្រធានបទដែលក្រុមនាងខ្ញុំត្រូវស្រាវជ្រាវគឺ «ការប៉ះពាល់ទៅលើបញ្ហាស្មារតីប្រជាជន» ថា «តើនៅក្នុងរបបខ្មែរក្រហមមានផលប៉ះពាល់អ្វីខ្លះដល់ស្មារតីប្រជាជន?»។ ចំពោះប្រធានបទនេះគឺធ្វើឲ្យយើងចង់សិក្សាស្រាវជ្រាវពីផលប៉ះពាល់ទៅលើបញ្ហាស្មារតីរបស់ប្រជាជន បន្ទាប់ពីរបបខ្មែរក្រហមកើតឡើង ហើយខ្ញុំតាំងចិត្តថាធ្វើប្រធានបទនេះឲ្យល្អ ព្រោះលោកគ្រូបានពន្យល់ណែនាំខ្ញុំយ៉ាងច្រើនពីរបៀបធ្វើកិច្ចការស្រាវជ្រាវ។

## ៣) គង់ ចាន់ណា



គង់ ចាន់ណា ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាងរស់នៅភូមិពោធិតាមុំ ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង រៀបរាប់ថា ខ្ញុំពិតជាសប្បាយចិត្តដែលបានសិក្សាពីប្រវត្តិសាស្ត្រដ៏ជូរចត់របស់ខ្មែរ។ នៅក្នុងថ្ងៃនេះ ខ្ញុំទទួលបានចំណេះដឹងទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវ និងចងក្រងឯកសារ ហើយខ្ញុំនឹងចែករំលែកទៅមិត្តដទៃទៀត ដែលមិនបានចូលរៀនដូចខ្ញុំ។ បន្ថែមពីនេះទៀត ខ្ញុំបានដឹងថា របបកម្ពុជាប្រជាធិបតេយ្យគឺជារបបដែលគួរឲ្យខ្លាចបំផុត ព្រោះមេដឹកនាំមិនបានខ្វល់ពីប្រជាជន និងបណ្តោយឲ្យអ្នកក្រោមបង្គាប់ធ្វើបាបប្រជាជន គំរាមកំហែង វាយដំប្រជាជនយ៉ាងព្រៃផ្សៃ។ លើសពីនេះ ប្រជាជនដែល

រស់នៅក្នុងរបបនោះ ទទួលរងនូវវិប្បដិសារី និងរងនូវផលប៉ះពាល់មកលើរូបរាងកាយ ផ្លូវចិត្ត និងប៉ះពាល់មកដល់ជីវភាពរស់នៅ។ ថ្ងៃនេះ ក្រុមរបស់ខ្ញុំបានទទួលប្រធានបទស្រាវជ្រាវមួយដែលនិយាយអំពី ផលពិបាកផ្លូវចិត្តរបស់ប្រជាជនដែលត្រូវបានជម្លៀសដោយបង្ខំ។ ចំពោះប្រធានបទនេះខ្ញុំពិតជាពេញចិត្តខ្លាំងណាស់ ព្រោះនៅពេលដែលខ្ញុំសិក្សាស្រាវជ្រាវរួច ខ្ញុំនឹងបានដឹងអំពីទឹកចិត្តរបស់អ្នកដែលឆ្លងកាត់របបខ្មែរក្រហម តាមរយៈការរៀបរាប់របស់គាត់ និងដឹងពីផលលំបាករបស់គាត់ដែលរស់នៅក្នុងរបបដែលមានការគំរាមកំហែង បំបិទសិទ្ធិសេរីភាពមនុស្ស និងប្រព្រឹត្តលើមនុស្សដូចជាសត្វធាតុ។ ចំពោះប្រធានបទនេះ ខ្ញុំមានជំនឿចិត្តថា ខ្ញុំនឹងអាចធ្វើវាបានហើយ ខ្ញុំក៏បានគិតក្នុងចិត្តរួចហើយថា បន្ទាប់ពីបញ្ចប់វេទិកានេះ ខ្ញុំនឹងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមយ៉ាងហោចណាស់ឲ្យបាន១០នាក់។ មូលហេតុដែលខ្ញុំគិតថា សម្ភាសន៍ឲ្យបាន១០នាក់ ព្រោះខ្ញុំទទួលបានការណែនាំពីលោកគ្រូ ដេង ពង្សរ៉ាស៊ី ដែលបានពន្យល់យ៉ាងល្អអំពីវិធីសាស្ត្រស្រាវជ្រាវ និងសម្ភាសន៍។ ម្យ៉ាងទៀត ក្រុមរបស់ខ្ញុំមានគម្រោងបែងចែកសមាជិកក្រុមឲ្យទៅសម្ភាសន៍យាយតា និងសាច់ញាតិរបស់ខ្លួន ហើយខ្ញុំនឹងសម្ភាសន៍ អ៊ំរបស់ខ្ញុំឲ្យបាន៣នាក់ក្នុងរយៈពេល២សប្តាហ៍នេះ។

## ៤) ម៉េត មល់



ម៉េត មល់ ភេទប្រុស អាយុ ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី ១២F នៃវិទ្យាល័យមេសាង រស់នៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង រៀបរាប់ថា កម្មវិធីសិក្សាស្រាវជ្រាវ និងសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺល្អណាស់សម្រាប់សិស្សានុសិស្សដូចជាខ្ញុំ ព្រោះខ្ញុំបានដឹងអំពីប្រវត្តិ-សាស្ត្រ ប្រទេសរបស់ខ្លួន។ ចំណេះដឹងដែលខ្ញុំទទួលបាននៅក្នុងថ្ងៃនេះគឺ បទពិសោធន៍នៃការរស់នៅរបស់ប្រជាជនខ្មែរ ទាំងអស់ដែលបានឆ្លងកាត់ការលំបាកកន្លងមក។ មួយវិញទៀត ខ្ញុំបានដឹងអំពីវិធីសាស្ត្រស្រាវជ្រាវឯកសារ ចងក្រងឯកសារ ទុកឲ្យក្មេងជំនាន់ក្រោយទៀត។ ការចងក្រងឯកសារ គឺជាមេរៀនមួយដើម្បីឲ្យកូនចៅជំនាន់ក្រោយចេះការពារ និងបដិសេធការដឹកនាំដែលមិនល្អ និងគាំទ្រទៅលើថ្នាក់ដឹកនាំដែលចេះគិតគូរពីប្រជាជន។ ចំពោះមេរៀនទាក់ទងរបបខ្មែរក្រហម ខ្ញុំទទួលបានចំណេះដឹងទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងទីប្រជុំជនឲ្យទៅធ្វើស្រែចម្ការ លើកទំនប់ ជីកប្រឡាយ។ ការជម្លៀសប្រជាជនធ្វើឡើងដោយការគំរាមកំហែង និងការបាញ់សម្លាប់ប្រជាជន។ ចំពោះប្រធានបទដែលខ្ញុំទទួលបានក្នុងថ្ងៃនេះ គឺ ការជម្លៀសប្រជាជនចេញពីទីក្រុងទៅជនបទ។ ខ្ញុំយល់ថា ប្រធានបទនេះល្អខ្លាំងណាស់សម្រាប់ក្រុមខ្ញុំដើម្បីយកទៅសិក្សាស្រាវជ្រាវ និងចងក្រងឯកសារដាក់ចូលក្នុងកម្មវិធីសិក្សាបន្តទៅទៀត។ នៅថ្ងៃអនាគតខ្ញុំចង់ធ្វើជាអ្នកដឹកនាំនយោបាយមួយរូប ដើម្បីលុបបំបាត់អំពើពុករលួយនៅក្នុងប្រទេសកម្ពុជា។

## ៥) សុខ រីយា



សុង រីយា ភេទស្រី មានអាយុ១៦ឆ្នាំ រៀននៅថ្នាក់ ១២D នៃវិទ្យាល័យមេសាង រៀបរាប់ថា វគ្គបណ្តុះបណ្តាលនេះធ្វើឲ្យខ្ញុំបានដឹងច្រើនជាងមុនពីរបបខ្មែរក្រហម។ ម្យ៉ាងទៀត ខ្ញុំទទួលបាននូវបទពិសោធន៍ថ្មីជាច្រើន ជាពិសេស គឺរបៀបនៃការចុះសិក្សាស្រាវជ្រាវទាក់ទងប្រធានបទដែលលោកគ្រូបានដាក់ឲ្យធ្វើ ដែលប្រធានបទនោះនិយាយអំពីឥទ្ធិពល ឬផលប៉ះពាល់នៃការជម្លៀសប្រជាជនដោយបង្ខំ។ ខ្ញុំមានការពេញចិត្តចំពោះប្រធានបទដែលលោកគ្រូដាក់ឲ្យធ្វើ ក៏ព្រោះតែប្រធានបទនេះមិនលំបាកពេក ហើយក៏មិនស្រួលពេកដែរសម្រាប់ខ្ញុំ។ ប៉ុន្តែទោះបីជាយ៉ាងណា

ខ្ញុំមានការប្តេជ្ញាចិត្តខ្ពស់រហូតដល់ទៅ៨០ភាគរយក្នុងការបំពេញកិច្ចការនេះឲ្យបានជោគជ័យ និងទាន់ពេលវេលាក្នុងរយៈពេល៣ខែ។ ខ្ញុំសន្យាថា នឹងខិតខំប្រឹងប្រែងធ្វើកិច្ចការនេះឲ្យបានល្អ។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់លោកគ្រូ ដែលបានបង្រៀនសិស្សទាំងអស់អំពីរបៀបស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហម។

## ៦) ហាន នីហ័រ



ហាន នីហ័រ ភេទស្រី មានអាយុ ១៥ឆ្នាំ រៀននៅថ្នាក់ទី១២F នៃវិទ្យាល័យមេសាង រៀបរាប់ថា ខ្ញុំចង់មករៀននៅទីនេះ គឺខ្ញុំចង់ដឹងអំពីការស្រាវជ្រាវ និងហេតុការណ៍ផ្សេងៗដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងចង់ស្រាវជ្រាវឲ្យកាន់តែច្បាស់អំពីព្រឹត្តិការណ៍ផ្សេងៗដែលបានកើតឡើងពីដំណាក់កាលមួយទៅដំណាក់កាលមួយ និងហេតុការណ៍កើតឡើងនៅក្នុងរបបនីមួយៗ ថារបបនេះមានអ្វីខ្លះបានកើតឡើង ជាពិសេស របបខ្មែរក្រហមបានធ្វើអ្វីខ្លះមកលើយាយតាយើង។ តាមរយៈការសិក្សារៀនសូត្រ និងតាមរយៈតាយាយដែលធ្លាប់បាននិយាយប្រាប់ខ្ញុំកន្លងមក ខ្ញុំគិតថាពួកគាត់ជួបទុក្ខលំបាកជាច្រើន ហើយគាត់ក៏មានសំណាងដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហម។ យាយតារបស់ខ្ញុំធ្លាប់បាននិយាយប្រាប់ខ្ញុំថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏របប ប៉ុល ពត គាត់បានជួបទុក្ខលំបាកជាច្រើនដោយសារការបង្អត់អាហារ ការចាប់គូឲ្យរៀបការដោយមិនបានស្រឡាញ់គ្នា ការធ្វើការងាររហូតសកម្លាំង និងមិនបានសម្រាកគ្រប់គ្រាន់ ជាពិសេសមិនបានហូបអាហារដែលយើងចង់ហូប។ ពេលយើងធ្វើអ្វីមួយត្រូវធ្វើដោយលួចលាក់ ព្រោះយើងស្ថិតនៅក្រោមការតាមដានរបស់អង្គការ។ ក្រៅពីនេះ ក្រុមគ្រួសាររស់នៅដោយមិនទុកចិត្តគ្នា។ ចំពោះការស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំមានការជឿជាក់ថា ខ្ញុំអាចធ្វើបានចំពោះប្រធានបទដែលលោកគ្រូបានដាក់ឲ្យក្រុមរបស់ខ្ញុំសិក្សាស្រាវជ្រាវ អំពី៖ តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការជម្លៀសប្រជាជនទាំងបង្ខំបានផ្តល់ផលប៉ះពាល់អ្វីខ្លះមកលើរាងកាយប្រជាជនកម្ពុជា។ ខ្ញុំតាំងចិត្តថាខ្ញុំនឹងធ្វើកិច្ចការនេះឲ្យបានល្អ ព្រោះខ្ញុំចង់បានស្នាដៃមួយដែលជារបស់ខ្លួនជាពិសេសខ្ញុំចង់ពង្រឹងភាពក្លាហានរបស់ខ្ញុំនៅក្នុងការជួបសំណេះសំណាលជាមួយតាយាយនៅក្នុងភូមិ។ រហូតមកដល់សម័យនេះ ការរស់នៅមានភាពងាយស្រួល ដូច្នេះយើងគប្បីខិតខំសិក្សារៀនសូត្រ ជាពិសេស ខិតខំស្រាវជ្រាវអំពីប្រវត្តិសាស្ត្ររបស់ប្រទេសយើងឲ្យបានច្រើន។





នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង បានមកទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកស្រីសន្ធរ និងស្រុកជើងព្រៃ

***សាំង ចាន់ធូ***

*នៅអំឡុងខែមករា ២០២៤ អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម ចុះជួប, សម្ភាសន៍ និងចងក្រងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅស្រុកកោះសូទិន ស្រុកស្រីសន្ធរ និងស្រុកជើងព្រៃ។ ការចុះជួបផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនេះ គឺធ្វើឡើងបន្ទាប់ពីអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចុះស្រាវជ្រាវ និងចងក្រងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» រៀបចំដោយមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម កាលពីថ្ងៃទី៦ និងទី៧ ខែមករា កន្លងមក។*

*ខាងក្រោមនេះ គឺជារឿងរ៉ាវសង្ខេបរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម បានសរសេរ និងផ្ញើមកកាន់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ៖*

## ១) ញ៉ា ហ៊ុច



ខ្ញុំឈ្មោះ ញ៉ា ហ៊ុច អាយុ៦០ឆ្នាំ កើតនៅភូមិ៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិទី៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម នេះតែម្តង។ ខ្ញុំរៀបការប្តីឈ្មោះ ហូ ស៊ុងហ៊ាត និងមានកូនចំនួន៣នាក់។ កូនទី១) ឈ្មោះ ហ៊ាន សុខា កូនទី២) ឈ្មោះ ហ៊ាន សុធារ៉ា និងកូនទី៣) ឈ្មោះ ហ៊ាន សុធារី។ ខ្ញុំមានឪពុកឈ្មោះ លី ញ៉ា និងម្តាយឈ្មោះ អ៊ុក ញ៉េប។ ខ្ញុំមានបងប្អូនសរុបចំនួន៦នាក់។

កាលពីក្មេង ខ្ញុំចូលរៀននៅសាលាបឋមសិក្សាកណ្តាលកោះត្បូង រហូតដល់ថ្នាក់ទី៣សង្គមចាស់។ នៅពេលដែលទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម វាយប្រយុទ្ធគ្នា ខ្ញុំក៏ឈប់រៀន។ ក្រោយពេលឈប់រៀន ខ្ញុំជួយធ្វើស្រែចម្ការឪពុកម្តាយ។

ខ្ញុំរស់នៅភូមិទី៥ រហូតដល់ចុងឆ្នាំ១៩៧០ ទើបសម្រេចចិត្តរត់ភៀសខ្លួនទៅរកកន្លែងសុវត្ថិភាពនៅខាងកោះប៉ែន ពីព្រោះមានការទម្លាក់គ្រាប់បែកនៅក្នុងភូមិរបស់ខ្ញុំ។ រាល់ពេលយន្តហោះទម្លាក់គ្រាប់បែកមកម្តងៗ ខ្ញុំមានការភិតភ័យខ្លាំងណាស់ ហើយក៏បានរត់ចូលរណ្តៅត្រង់សេ។ ការទម្លាក់គ្រាប់បែកមិនបានធ្វើឲ្យបាត់បង់ជីវិតមនុស្ស ឬទ្រព្យសម្បត្តិប្រជាជនក្នុងភូមិឡើយ កាលពីចន្លោះឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣។ ពេលនោះ ខ្ញុំនៅជាកុមារនៅឡើយ។ ខ្ញុំមិនសូវចងចាំរឿងរ៉ាវច្រើនពីរបបខ្មែរក្រហមទេ។ ខ្ញុំត្រូវបានប្រធានកងចាត់តាំងឲ្យទៅឃ្វាលគោ និងប្រមូលអាចម៍គោ ព្រោះពេលនោះខ្ញុំមានអាយុប្រមាណតែ១១ឆ្នាំតែប៉ុណ្ណោះ។ ខ្ញុំធ្វើការនៅកងកុមារនៅស្រុកកោះសូទិន។ ខ្ញុំគឺជាកុមារមូលដ្ឋានចាស់។ ខ្ញុំនិងកុមារផ្សេងទៀតត្រូវក្រោកពីព្រលឹមដើរប្រមូលអាចម៍គោ ហើយពេលថ្ងៃ

ខ្ញុំត្រូវទៅឃ្វាលគោ និងកាត់ទន្ទ្រានខែត្រដើម្បីយកមកលាយជាមួយអាចម៍គោធ្វើជីដាក់ស្រែ។ ខ្ញុំត្រូវទៅឃ្វាលគោ និងប្រមូលអាចម៍គោគ្មានពេលសម្រាកឡើយ។ ហេតុការណ៍ដែលខ្ញុំចងចាំមិនបំភ្លេចអំឡុងរបបខ្មែរក្រហមគឺខ្ញុំឃើញខ្មែរក្រហមបណ្តើរមនុស្សយកទៅសម្លាប់ចោល ប៉ុន្តែខ្ញុំមិនបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែកទេ។ ពេលនោះខ្ញុំភ័យខ្លាចខ្លាំងណាស់។

នៅពេលដែលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំរួចផុតពីការធ្វើការងារធ្ងន់ធ្ងរ និងការធ្វើការងារគ្មានពេលសម្រាកគ្រប់គ្រាន់ដែលបណ្តាលឲ្យប៉ះពាល់ដល់សុខភាព។ ជាចុងក្រោយ ខ្ញុំសូមផ្តាំផ្ញើដល់កូនចៅជំនាន់ក្រោយឲ្យខិតខំសិក្សាឈ្វេងយល់ពីរបបខ្មែរក្រហម កុំឲ្យប្រទេសជាតិធ្លាក់ចូលក្នុងរបបនេះម្តងទៀត។

*សម្ភាសន៍ និងសង្ខេបរឿងរ៉ាវដោយ៖ ហ៊ាន សុធារី អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថត៖ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ២) ទួន សម្បត្តិ



ខ្ញុំឈ្មោះ ទួន សម្បត្តិ អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិតាមល់ ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ កាលពីមុនខ្ញុំគឺជាជាងគំនូរចំណានម្នាក់ ប៉ុន្តែដោយសារធ្លាក់ខ្លួនឈឺ ខ្ញុំក៏ចូលរកព្រះធម៌ក្នុងព្រះពុទ្ធសាសនា ហើយត្រូវប្រជាជនអញ្ជើញធ្វើជាអាចារ្យតាមពិធីបុណ្យផ្សេងៗ។ ខ្ញុំមានប្រពន្ធឈ្មោះ អ៊ុន សុខឃីម អាយុ៦១ឆ្នាំ សព្វថ្ងៃគឺជាមេផ្ទះ។ ខ្ញុំមានឪពុក ឈ្មោះ ឃួន ឃឿន និងម្តាយឈ្មោះ ទេស យឿង ដែលសុទ្ធតែធ្លាប់បានឆ្លងកាត់របប ប៉ុល ពត។ ខ្ញុំមានបងប្អូនប្រុសស្រីចំនួន៦នាក់ ក្នុងចំណោមនោះបានស្លាប់អស់ម្នាក់។

ក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុប្រហែល១៣ឆ្នាំ និងជាសមាជិកកងកុមារមូលដ្ឋានចាស់នៅក្នុងភូមិតាមល់។ ម្តាយរបស់ខ្ញុំគឺជាចុងភៅចម្អិនអាហារសម្រាប់ប្រជាជននៅតាមក្រុម និងកង ហើយឪពុកខ្ញុំទៅកាប់ឆ្ការព្រៃនៅបារាយណ៍ ចំណែកប្អូនៗតូចៗរបស់ខ្ញុំទុកឲ្យយាយតាខ្ញុំគឺជាអ្នកមើលថែទាំ ព្រោះយាយតាខ្ញុំចាស់ៗ ដូច្នេះអង្គការឲ្យគាត់នៅមើលថែក្មេងៗ។ ពេលនោះ អង្គការបានចាត់ឲ្យខ្ញុំ និងក្មេងៗដទៃទៀតទៅឃ្វាលគោ និងលើកភ្លឺស្រែនៅភូមិជន្ទាស់ដៃ។ ក្មេងៗក៏ដូចជាប្រជាជនដទៃទៀត ត្រូវបានអង្គការចាត់តាំងឲ្យមកធ្វើការនៅជន្ទាស់ដៃមួយអាទិត្យ ឬមួយខែទើបត្រឡប់ទៅផ្ទះជុំគ្រួសារវិញ។ ពេលនោះបងប្រុសច្បងរបស់ខ្ញុំឈ្មោះ គឹម ឃឿន ក៏ទៅរែកដីនៅការដ្ឋានជន្ទាស់ដៃនោះដែរ ចំណែកប្អូនទី៣របស់ខ្ញុំ អង្គការឲ្យឃ្វាលគោនៅមិនឆ្ងាយពីផ្ទះប៉ុន្មានទេព្រោះវានៅតូចនៅឡើយ។

ក្រោយមក នៅពេលដែលខ្ញុំធំពេញវ័យ អង្គការបានបញ្ចូលខ្ញុំក្នុងកងយុវជន ហើយបានចាត់ខ្ញុំឲ្យទៅលើកទំនប់នៅបឹងវៀម ស្ថិតនៅព្រំប្រទល់រវាងបារាយណ៍ និងព្រែកដំបូក។ ពេលដែលធ្វើការនៅបឹងវៀមរួចរាល់ ខ្ញុំនិងយុវជនដទៃទៀតក៏ត្រឡប់មកធ្វើការនៅភូមិតាមល់វិញ។ មិនយូរប៉ុន្មាន អង្គការក៏ចាត់ខ្ញុំ និងប្រជាជនដទៃទៀតទៅជាន់រហាត់ទឹកបញ្ចូលស្រែប្រាំងនៅព្រៃ ស្ថិតនៅក្រោយភូមិអំពិល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ថ្ងៃមួយពេលខ្ញុំដើរតាមផ្លូវ ក៏ឃើញមានប្រជាជនជម្លៀសពីភូមិបារាយណ៍មកជាច្រើនគ្រួសារ ហើយត្រូវបានអង្គការសម្លាប់នៅវត្តប្រាសាទវង្គី ហៅ វត្តត្បូង ស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស៊ីធរកណ្តាល ខេត្តកំពង់ចាម។ ពេលខ្ញុំឃើញហេតុការណ៍នោះ ខ្ញុំព្រួយបារម្ភពីជីវិតក្រុមគ្រួសារ និងជីវិតខ្លួនឯងយ៉ាងខ្លាំង ព្រោះមិនដឹងថាអង្គការយកទៅសម្លាប់នៅពេលណានោះទេ។ ចំណែករបបអាហារគឺមានតែពីរពេលប៉ុណ្ណោះគឺពេលថ្ងៃ និងពេលល្ងាច ដែលខាងចុងភៅចែកចេញជា២រដូវគឺ ៦ខែហូបបាយ និង៦ខែហូបបបរ។

ពេលដល់ខែហូបបបរម្តងៗ ប្រជាជនទាំងអស់ពិបាកខ្លាំងណាស់ ព្រោះប្រជាជនត្រូវធ្វើការងារធ្ងន់ធ្ងរ ហើយ ហូបបបរបានតែបន្តិចបន្តួចប៉ុណ្ណោះ។ ខ្ញុំពិបាកក្នុងការធ្វើការងារខ្លាំងណាស់ព្រោះត្រូវដើរឆ្ងាយ ហើយ ហូបមិនគ្រប់គ្រាន់ ដូច្នេះខ្ញុំគ្មាន

កម្លាំងធ្វើការឡើយ។ ប៉ុន្តែប្រសិនបើខ្ញុំហ៊ានរអ៊ូ ឬឈប់ធ្វើការ នោះខ្ញុំនឹងត្រូវទទួលទោសកាន់តែធ្ងន់។ ចំណែកឯការសិក្សារៀនសូត្រ កាលពីសង្គមខ្ញុំបានរៀនធម៌វិន័យនៅវត្តបានខ្លះៗ ហើយក្រោយមកអង្គការក៏ឲ្យចូលរៀននៅក្នុងភូមិ។ ពេលនោះក្មេងៗត្រូវបានអង្គការឲ្យចូលរៀនត្រឹមថ្នាក់ទី៤ ហើយក៏បញ្ជូលទៅកងយុវជន។ បន្ទាប់ពីខ្ញុំចូលរៀនបានរយៈពេល២ខែ ប្រទេសកម្ពុជាត្រូវបានរំដោះពីរបបខ្មែរក្រហម ហើយប្រជាជនទាំងអស់សម្តែងការសប្បាយរីករាយយ៉ាងខ្លាំង រហូតដល់ស្រក់ទឹកភ្នែក និងអរគុណដល់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលរំដោះប្រជាជន ក៏ដូចជាប្រទេសកម្ពុជាឲ្យរួចផុតពីរបបខ្មែរក្រហម។ បន្ទាប់មក ខ្ញុំនិងបងប្រុសរបស់ខ្ញុំបានចូលរៀនបន្តចំណែកប្អូនប្រុសរបស់ខ្ញុំម្នាក់បានទៅរៀននៅបារាំងហើយក៏បានក្លាយជាពេទ្យព្យាបាលជំងឺនៅព្រែកពោធិ៍។ ចំណែក ខ្ញុំនិងបងប្រុសដោយសារស្រឡាញ់ និងចង់បន្តវេនពីឪពុកផងក៏ចាប់អាជីពជាជាងគំនូរទាំងពីរនាក់។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ អាជ្ញាធរ និងប្រជាជន នាំគ្នាជីករណ្តៅនៅឯវត្តប្រាសាទវង្គី ហៅ វត្តត្បូង គឺជាកន្លែងដែលអង្គការបានយកប្រជាជនមកសម្លាប់នៅក្នុងរណ្តៅ១ស្ថិតនៅក្បែរចេតិយ។ ខ្ញុំបានទៅមើលការជីកនោះឃើញសាកសពរបស់ប្រជាជនទាំងចាស់ទាំងក្មេងដែលសល់តែគ្រោងឆ្អឹង ធ្វើឲ្យខ្ញុំនៅតែចងចាំមិនភ្លេចនូវទិដ្ឋភាពដ៏ឈឺចាប់នោះ។

សម្ភាសន៍និងសង្ខេបរឿងរ៉ាវដោយៈ ផុល ម៉ូលីការ អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថតៈ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ៣) ទេស យឿង



ខ្ញុំឈ្មោះ ទេស យឿង ភេទស្រី អាយុ៨៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិតាមល់ ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំបានរៀបការជាមួយឈ្មោះ ឃួន យឿន គឺជាជាងគំនូរ (បច្ចុប្បន្នស្លាប់) និងមានកូនប្រុសស្រីចំនួន៦នាក់ គឺប្រុស៣នាក់ និងស្រី៣នាក់។ ខ្ញុំគឺជាអតីតចុងភៅនៅភូមិតាមល់ នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានឪពុកឈ្មោះ ទេស ទួន គឺជាកសិករ និងម្តាយឈ្មោះ កៀកគួ គឺជាកសិករដូចគ្នា។ ឪពុកម្តាយខ្ញុំបានរួចផុតពីការសម្លាប់របស់ខ្មែរក្រហម។

កាលពីរបបខ្មែរក្រហម ខ្ញុំមានអាយុ៣៤ឆ្នាំ ចំណែកប្តីរបស់ខ្ញុំមានអាយុ៤២ឆ្នាំ។ ខ្ញុំនិងប្តី គឺជាប្រជាជនចាស់រស់នៅក្នុងភូមតាមល់។ នៅពេលនោះខ្ញុំបានរស់នៅជុំគ្នាជាមួយឪពុកម្តាយ និងកូនៗរបស់ខ្ញុំ។ ចាប់តាំងពីព្រឹកដល់ល្ងាច ខ្ញុំធ្វើម្ហូបអាហារឲ្យប្រជាជននៅក្នុងភូមិ ដោយពុំទទួលបានប្រាក់កម្រៃអ្វីឡើយ ព្រោះចាត់ទុកថាជាការងារស្ម័គ្រចិត្ត។ ខ្ញុំមិនបានចេញទៅធ្វើការតាមការដ្ឋាន ឬនៅព្រៃទេ ទើបខ្មែរក្រហមឲ្យខ្ញុំធ្វើការខាងចុងភៅក្នុងភូមិ។ ការហូបចុកគឺដូចៗគ្នា ដោយខ្មែរក្រហមកំណត់២ពេល គឺពេលថ្ងៃ និងពេលល្ងាច។ ខ្មែរក្រហមចាត់ប្រជាជនឲ្យហូបរួមដោយបែងចែកជាក្រុមៗ ដោយមួយក្រុមមាន៣០គ្រួសារ ហើយត្រូវមកហូបជុំគ្នានៅរោងបាយរួម។ ខ្មែរក្រហមក៏បែងចែករបបអាហារសម្រាប់ប្រជាជនជាពីររដូវកាលក្នុងមួយឆ្នាំដែរ គឺ៦ខែហូបបាយ និង៦ខែហូបបបរ។ ខ្មែរក្រហមឲ្យខ្ញុំដាំបាយសម្លដូចជា សម្លម្ជូរ សម្លកកូរ ទៅតាមថ្ងៃដែលប្រជាជនរក ត្រី សាច់ យកមកឲ្យខ្ញុំធ្វើ បណ្តាលឲ្យប្រជាជនពុំសូវមានអាហារ និងមានកម្លាំងធ្វើការទេ។ ប្រជាជនហូបចុកបានបន្តិចបន្តួច ចំណែកបបរដាក់អង្ករតែបន្តិចបន្តួចតែប៉ុណ្ណោះ។ ទោះបីខ្ញុំជាចុងភៅក៏ដោយក៏ខ្ញុំបានហូបចុកតិចតួចដូចប្រជាជនដទៃទៀតដែរ។ ប្តីរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅកាប់ឆ្ការព្រៃ និងក្រង់ស្បូវនៅភូមិបន្ទាយ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ឯកូនប្រុសខ្ញុំ២នាក់ទៀតខ្មែរក្រហមចាត់តាំងឲ្យទៅឃ្វាលគោ និងរែកដីនៅឯស្ពាយត្បូងរាប់ថ្ងៃខែទើបត្រឡប់មកផ្ទះវិញ។ ចំណែកកូនស្រីខ្ញុំនៅតូចពេក ដូច្នេះខ្មែរក្រហមទុកឲ្យឪពុកម្តាយខ្ញុំមើលថែទាំនៅផ្ទះ។ ពេលនោះ ម្តាយឪពុកខ្ញុំចាស់ៗ ទើបខ្មែរក្រហមចាត់ឲ្យពួកគាត់មើលក្មេងៗនៅផ្ទះនៅពេលដែលឪពុកម្តាយរបស់ក្មេងៗទាំងនោះចេញទៅធ្វើការអស់។

នៅសម័យនោះ ដំណាំផ្លែផ្កានៅជុំវិញផ្ទះ ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនហូបទេ។ ប្រសិនបើប្រជាជនបេះហូប នឹងត្រូវទទួលទោសដល់ស្លាប់ក៏មាន។ គ្រួសារខ្ញុំមិនហ៊ានធ្វើខុសទៅនឹងវិន័យខ្មែរក្រហម នឹងប្រុងប្រយ័ត្នជានិច្ច ទើបគ្រួសាររបស់ខ្ញុំពុំមានអ្នកស្លាប់។ រាល់យប់ ខ្ញុំមិនដែលដេកដោយស្ងប់សុខឡើយ ព្រោះដក់ជាប់ដោយអារម្មណ៍ភ័យខ្លាចគ្រប់ពេលវេលា។ ខ្ញុំនិងគ្រួសារបានតស៊ូអត់ទ្រាំរហូតដល់មានការរំដោះប្រទេសកម្ពុជាឲ្យរួចផុតពីរបបឃោរឃៅខ្មែរក្រហម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ពេលនោះ ខ្ញុំនិងគ្រួសារព្រមទាំងប្រជាជនកម្ពុជារួចផុតពីនរក និងមានជីវិតសាជាថ្មី។ បន្ទាប់មកខ្ញុំនៅមើលថែកូន និងផ្ទះសម្បែង ចំណែកឯប្ដីរបស់ខ្ញុំក៏បន្តធ្វើការងារជាជាងគំនូរដើម្បីចិញ្ចឹមគ្រួសារ។ ចំណែកកូនប្រុសស្រីរបស់ខ្ញុំក៏បានចូលរៀន និងមានចំណេះដឹង ហើយបានធ្វើការងារល្អៗ។

ចុងក្រោយ ខ្ញុំសូមអរគុណអ្នកដឹកនាំដែលនាំមកនូវភាពសន្តិសុខដល់ប្រទេស ហើយធ្វើឲ្យប្រជាជនគ្រប់រូបរស់នៅដោយភាពសុខសប្បាយគ្មានការភ័យខ្លាច សង្គ្រាម និងការគាបសង្កត់។

*សម្ភាសន៍និងសង្ខេបរឿងរ៉ាវដោយ៖ ថុល ម៉ូលីការ អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថត៖ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ៨) ឡាង ខន



«ខ្ញុំមានអារម្មណ៍រន្ធត់ស្ទើរតែបាត់បង់ស្មារតីពេលពួកអង្គការមកនាំយកឪពុករបស់ខ្ញុំ និងអ៊ំប្រុសរបស់ខ្ញុំពីរនាក់ទៀតទៅកាន់វត្តប្រាសាទវង្ស ហៅ វត្តត្បូង»។

ខ្ញុំឈ្មោះ ឡាង ខន ភេទស្រី អាយុ៥៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិតាមល់ ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូនប្រុសស្រីចំនួន៧នាក់ ក្នុងនោះស្លាប់អស់២នាក់។ ខ្ញុំមានឪពុកឈ្មោះ អ៊ឹម និងម្ដាយឈ្មោះ ណន។ ឪពុកម្ដាយខ្ញុំបានស្លាប់អស់ហើយ។ ខ្ញុំពុំមានប្ដីទេ គឺខ្ញុំរស់នៅជាមួយប្អូនស្រីដែលមានប្ដី និងមានកូន៥នាក់។ ខ្ញុំត្រូវធ្វើការដើម្បីចិញ្ចឹមជីវិតខ្លួនឯង។

កាលពីរបបខ្មែរក្រហម ខ្ញុំមានអាយុប្រហែល១០ឆ្នាំ ខ្ញុំត្រូវបានអង្គការប្រើឲ្យទៅធ្វើការដូចជា ជាន់អង្គរ ឃ្វាលគោនៅលើកោះដែលស្ថិតនៅមិនឆ្ងាយពីផ្ទះប៉ុន្មានទេ។ ចំណែកបងប្អូនខ្ញុំ២នាក់ទៀត ប្រធានកងប្រើឲ្យរែកដី។ ថ្ងៃខ្លះបងខ្ញុំវិលត្រឡប់មកផ្ទះវិញពេលល្ងាចឬយប់ ហើយពេលខ្លះបងខ្ញុំស្នាក់នៅការដ្ឋានការងាររាប់ខែក៏មាន។ ចំពោះខ្ញុំដែលធ្វើការនៅជិតផ្ទះ ដូច្នេះ ពេលល្ងាចខ្ញុំត្រឡប់មកផ្ទះវិញ ឯប្អូនៗរបស់ខ្ញុំនៅតូចៗដែលមានអាយុប្រមាណ២ ទៅ៣ឆ្នាំ ដូច្នេះខ្មែរក្រហមឲ្យនៅផ្ទះដើម្បីឲ្យចាស់ៗដែលមិនអាចធ្វើការធ្ងន់មើលថែទាំ។

កាលនោះ ខ្មែរក្រហមមានមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺនៅព្រែកពោធិ៍។ ខ្មែរក្រហមអនុញ្ញាតឲ្យប្រជាជនដែលមានជំងឺទៅព្យាបាលនៅមន្ទីរពេទ្យនោះ។ ការហូបចុករបស់ប្រជាជនក្នុងរបបខ្មែរក្រហម គឺពិបាកខ្លាំងណាស់ ហើយខ្ញុំមិនដែលបានហូបគ្រប់គ្រាន់ទេ។ ខ្ញុំសឹងតែគ្មានកម្លាំងឈរ ដោយសារតែឃ្លានខ្លាំងពេក ម្យ៉ាងទៀតខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើងទៅធ្វើការទៀត។ ប្រជាជនម្នាក់ៗសុទ្ធតែបាក់កម្លាំងទោះបីចង់រអ៊ូក៏មិនហ៊ានដែរ។

មានពេលមួយអង្គការបានកោះហៅអ៊ំរបស់ខ្ញុំឈ្មោះ វុធ ដោយមិនដឹងពីមូលហេតុ ព្រោះខ្ញុំនៅក្មេង។ ពេលនោះ អ៊ំរបស់ខ្ញុំ គឺជាប្រធានក្រុម ហើយគាត់ដឹងខ្លួនថា ពេលខ្មែរក្រហមហៅគាត់ទៅ នឹងយកទៅសម្លាប់មិនខាន ដូច្នេះគាត់ក៏រត់គេចខ្លួនស្រាប់តែអង្គការចោទឪពុករបស់ខ្ញុំ និងអ៊ំៗរបស់ខ្ញុំ៣នាក់ផ្សេងទៀតថា លាក់អ៊ំវុធ ហើយក៏ហៅពួកគាត់ទាំង៣ទៅសួរនាំ។ ឪពុករបស់ខ្ញុំដឹងថានឹងត្រូវស្លាប់ ដូច្នេះគាត់បានផ្ដែផ្ដាំកូនៗ និងម្ដាយរបស់ខ្ញុំទាំងទឹកភ្នែក។ ពេលនោះ គឺជាពេលដ៏សោកសៅបំផុតក្នុងជីវិតខ្ញុំ និងម្ដាយខ្ញុំ។ ពេលយប់ឡើងខ្មែរក្រហមចាក់មេក្រូ គឺបញ្ជាក់ថាជាពេលសម្លាប់មនុស្សនៅវត្តប្រាសាទវង្ស ហៅ វត្តត្បូង។ ខ្ញុំនិងគ្រួសារឈឺចាប់ខ្លាំងណាស់ ប៉ុន្តែមិនអាចជួយឪពុករបស់ខ្ញុំបាន ហើយសូម្បីយំក៏មិនហ៊ានឲ្យខ្មែរក្រហមឮដែរ ព្រោះខ្លាចទទួលទោស។ នៅពេលយប់ស្ងាត់ យើងពិតជាឯកោខ្លាំងណាស់។

ក្រោយមក ខ្ញុំទទួលដំណឹងថាប្រជាជនកម្ពុជាត្រូវបានរំដោះពីរបបពីរបបខ្មែរក្រហម ទើបខ្ញុំក៏ដូចជាអ្នកភូមិរំភើបត្រេកអរយ៉ាងខ្លាំង ព្រោះបានរួចផុតពីរបបព្រៃផ្សៃខ្មែរក្រហម។ ខ្ញុំនៅតែចងចាំក្នុងចិត្ត និងឈឺចាប់ដែលបាត់បង់ឪពុកជាទីស្រឡាញ់ និងអ៊ំៗ។ បន្ទាប់ពីប្រទេសត្រូវបានរំដោះ ខ្ញុំធ្វើស្រែចម្ការនៅភូមិកំណើត ហើយទោះបីជាជីវភាពលំបាកបន្តិចពិតមែន ប៉ុន្តែខ្ញុំមិនខ្លាចបាត់បង់ជីវិតដូចក្នុងរបបខ្មែរក្រហមឡើយ។

*សម្ភាសន៍និងសង្ខេបរឿងរ៉ាវដោយៈ ថុល ម៉ូលីការ អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថតៈ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ៥) ឌុច ហួន



ខ្ញុំឈ្មោះ ឌុច ហួន អាយុ៥៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិចុងបឹងក្រៅ ឃុំផ្ទះកណ្ដាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំបានរៀបការជាមួយប្រពន្ធឈ្មោះ គង់ ដានី និងមានកូនប្រុសស្រី២នាក់ គឺ កូនទី១) ឈ្មោះ ឌុច នីតា (ស្រី) កូនទី២) ឈ្មោះ ឌុច សុធារិទ្ធិ (ប្រុស)។ ខ្ញុំកើតនៅភូមិចុងកោះ ឃុំកោះអណ្ដែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ឌុច វង់ និងម្ដាយឈ្មោះ គឹម ហេង ព្រមទាំងមានបងប្អូនបង្កើតចំនួន៤នាក់ គឺបងទី១) ឈ្មោះ ឌុច ហន (ស្រី) បងទី២) ឈ្មោះ ឌុច ហាន (ស្រី) ទី៣) ខ្ញុំ (ឌុច ហួន) និងប្អូនទី៤) ឈ្មោះ ឌុច ហួរ (ប្រុស)។

អំឡុងពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ឆ្នាំ១៩៧០ ខ្ញុំនៅជាកុមារ និងមានអាយុ៥ឆ្នាំប៉ុណ្ណោះ។ ខ្ញុំចាំថា ឪពុកម្ដាយរបស់ខ្ញុំគឺជាកសិករ ហើយពេលនោះ ស្រុកកើតមានសង្គ្រាម និងមានការទម្លាក់គ្រាប់បែកនៅភូមិចុងកោះ ឃុំកោះអណ្ដែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ប៉ុន្តែមិនបណ្ដាលឲ្យសមាជិកគ្រួសារខ្ញុំរងរបួស ស្លាប់ និងបាត់បង់ទ្រព្យសម្បត្តិឡើយ។ នៅពេលខ្មែរក្រហមឡើងកាន់កាប់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំត្រូវបានចាត់ចូលជាប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំចូលរៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យបុស្សស្រុក រហូតដល់ថ្នាក់ទី៩។ ក្រោយពីឈប់រៀនខ្ញុំបានចូលបម្រើកងទ័ព។

ដោយសារក្នុងរបបខ្មែរក្រហមខ្ញុំនៅវ័យក្មេង ដូច្នេះខ្ញុំមិនសូវចងចាំច្បាស់លាស់ទេ ហើយខ្ញុំក៏មិនបានឃើញការសម្លាប់មនុស្សដោយផ្ទាល់ភ្នែកដែរ ប៉ុន្តែខ្ញុំចង់ឲ្យក្មេងជំនាន់ក្រោយបានដឹង និងចងចាំអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម។

*សម្ភាសន៍ និងសង្ខេបរឿងរ៉ាវដោយ ៖ សេង រដ្ឋា អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថតៈ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ៦) ស៊ុយ សំអុន



ខ្ញុំឈ្មោះ ស៊ុយ សំអុន ភេទស្រី អាយុ៦៦ឆ្នាំ រស់នៅភូមិចុងបឹងក្រៅ ឃុំផ្ទះកណ្ដាល ស្រុកស្រីសន្ធរ ខេត្តកំពង់-ចាម។ ខ្ញុំកើតនៅភូមិឃុំដដែល។ ខ្ញុំរៀបការជាមួយប្ដីឈ្មោះ ចាន់ សុផល និងមានកូនស្រី៤នាក់ គឺ កូនទី១) ឈ្មោះ ពិន ម៉ាលីស កូនទី២) ឈ្មោះ ពិន ដាន់ណែត កូនទី៣) ឈ្មោះ ពិន ដានី និងកូនទី៤) ឈ្មោះ ពិន ដាន់ម៉ែ។ ខ្ញុំមានឪពុកឈ្មោះ ស៊ុយ សាក់ គឺជាកសិករ ចំណែកម្ដាយឈ្មោះ ឯក សំអាត គឺជាមេផ្ទះ និងមានបងប្អូន៨នាក់ គឺបងទី១) ឈ្មោះ ស៊ុយ សំអាត (ស្រី) បងទី២) ឈ្មោះ សាក់ សុធឿន (ប្រុស ស្លាប់) ទី៣) ខ្ញុំ (ស៊ុយ សំអុន) ប្អូនទី៤) ឈ្មោះ ស៊ុយ សំអ៊ុល (ស្រី) ប្អូនទី៥) ឈ្មោះ ស៊ុយ ចាន់នី (ស្រី) ប្អូនទី៦) ឈ្មោះ ស៊ុយ សុធា (ប្រុស) ប្អូនទី៧) ឈ្មោះ ស៊ុយ សុម៉ាលី (ស្រី) និងប្អូនទី៨) ឈ្មោះ ស៊ុយ ពៅ ដានី (ស្រី)។

កាលពីកុមារ ខ្ញុំរៀននៅសាលាវត្តបុទុមសាគរដល់ថ្នាក់ទី២។ បន្ទាប់ពីឈប់រៀនខ្ញុំធ្វើការជាកសិករ។ នៅចុងឆ្នាំ១៩៦០ និងដើមឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែកធុនសាំង (ណាប៉ាល់) នៅភូមិចុងបឹងក្រៅ ពេលនោះយើងនាំគ្នារត់ចូលព្រៃ ចំណែកទ្រព្យសម្បត្តិខ្ញុំ មិនមានបាត់បង់អ្វីទេ ដោយសារគ្រួសារខ្ញុំមានជីវភាពក្រីក្រ។ នៅចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ខ្ញុំរស់នៅជាប្រជាជនធម្មតា ហើយពេលនោះខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅលើកទំនប់ និងដកស្ទូងនៅបារាយណ៍។ បន្ទាប់មក ខ្ញុំទៅច្រាំយ៉ាម ទំនប់បឹងវៀម ទួលសម្បូរ និងទៅស្វាយពោធិ ដើម្បីជីកប្រព័ន្ធប្រឡាយ លើកទំនប់ វែកដី និងធ្វើស្រែរួម។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៧ឆ្នាំ។ ខ្ញុំរស់នៅភូមិចុងបឹងក្រៅដដែល ប៉ុន្តែក្រោយមកខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅភ្នំកន្ទាយបានកន្លះខែទើបត្រឡប់មកភូមិវិញ។ ពេលនៅភ្នំកន្ទាយ ខ្ញុំបានធ្វើការប្រូតស្រូវជាមួយប្រជាជននៅទីនោះ ដោយខ្ញុំគឺជាប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ ប៉ុន្តែទោះបីជាយ៉ាងណាខ្មែរក្រហមបម្រុងដឹកខ្ញុំតាមឡានទ្រុងយកទៅវាយសម្លាប់ចោល ប៉ុន្តែផែនការនេះមិនបានសម្រេច ព្រោះខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩។ ខ្ញុំដកស្ទូងនៅភូមិចុងបឹងក្រៅ ឃុំ ផ្ទះកណ្ដាល ស្រុកស្រីសន្ធរ ដដែល ចំណែកប្រជាជនបានវិលត្រឡប់មកភូមិឃុំរបស់ខ្លួនឯងវិញ ហើយប្រជាជនខ្លះទៀតក៏បន្តរស់នៅកន្លែងដែលខ្មែរក្រហមបានជម្លៀសទៅ។ ខ្ញុំនៅចងចាំនូវរឿងរ៉ាវដ៏ឈឺចាប់ដែលខ្មែរក្រហមប្រើឲ្យវែកដីឲ្យហូបបបរលាយពោតឲ្យដេករួម ធ្វើការងាររួម បំបិទសេរីភាពក្នុងការរស់នៅ និងគ្មានសិទ្ធិសម្រេចកិច្ចការខ្លួនឯង គឺបានត្រឹមធ្វើតាមបញ្ជាថ្នាក់លើប៉ុណ្ណោះ។ ខ្ញុំចង់ឲ្យក្មេងជំនាន់ក្រោយដឹងថា នៅក្នុងរបបខ្មែរក្រហម ប្រជាជនលំបាកវេទនា។ ពេលខ្លះខ្ញុំប្រាប់ក្មេងៗ ប៉ុន្តែក្មេងមួយចំនួនមិនជឿរឿងរ៉ាវដែលខ្ញុំនិយាយរៀបរាប់ឡើយ។ ទោះបីយ៉ាងណា ក្មេងនឹងយល់នៅពេលបានសិក្សារៀនសូត្រ និងឈ្វេងយល់អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដោយខ្លួនឯង។

សម្ភាសន៍ និងសង្ខេបរឿងរ៉ាវដោយ ៖ សេង រដ្ឋា អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថត៖ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៧) អ៊ុង ស៊ីនឿន



ខ្ញុំឈ្មោះ អ៊ុង ស៊ីនឿន ភេទស្រី អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិចុងបឹងក្រៅ ឃុំផ្ទះកណ្ដាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំបានរៀបការជាមួយប្ដីឈ្មោះ គួ រឿន និងមានកូនប្រុសស្រីចំនួន៣នាក់ គឺទី១) ឈ្មោះ គួ សុវណ្ណារ៉ា (ប្រុស) កូនទី២) ឈ្មោះ គួសុវណ្ណារុំ (ប្រុស) និងកូនទី៣) ឈ្មោះ គួ ដានី (ស្រី)។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិចុងបឹងក្រៅ ឃុំផ្ទះកណ្ដាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ អ៊ុង នាង គឺជាកសិករ និងម្ដាយឈ្មោះ ជា ណោន គឺជាមេផ្ទះ។ ខ្ញុំមានបងប្អូន៤នាក់ គឺបងទី១) ឈ្មោះ អ៊ុង ស៊ុណុន (ស្រី) ទី២) ខ្ញុំ (អ៊ុង ស៊ីនឿន) ប្អូនទី៣) ឈ្មោះ អ៊ុង ស៊ីណា (ស្រី) ប្អូនទី៤) ឈ្មោះ អ៊ុង ស៊ីណាន (ស្រី)។

កាលនៅកុមារ ខ្ញុំចូលរៀននៅសាលាវត្តបុទុមសាគរ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី២ ក៏កើតមានរដ្ឋប្រហារឆ្នាំ១៩៧០។ ពេលនោះគ្រួសារខ្ញុំគឺជាកសិករ ចំណែកភូមិស្រុកខ្ញុំពេលនោះប្រជាជននាំគ្នាធ្វើបាតុកម្ម នៅរវាងពីចុងឆ្នាំ១៩៦០ និងដើមឆ្នាំ១៩៧០ ព្រមទាំងមានសង្គ្រាម ការបាញ់ផ្លោង ការទម្លាក់គ្រាប់បែកនៅភូមិចុងបឹងក្រៅ និងភូមិត្រើយបឹង។ ខ្ញុំបានរត់ទៅពួននៅត្រង់សេ។ ពេលនោះមានគ្រាប់ផ្លោងចេញពីម៉ារីនចតនៅទន្លេមេគង្គបណ្ដាលឲ្យស្លាប់ និងរបួសគ្រួសារខ្ញុំ ប៉ុន្តែមិនបណ្ដាលឲ្យខូចខាតទ្រព្យសម្បត្តិទេ ព្រោះគ្រួសារខ្ញុំគ្មានទ្រព្យឡើយ។ ពេលខ្មែរក្រហមចូលមកគ្រប់គ្រងភូមិចុងបឹងក្រៅលើកដំបូង ខ្មែរក្រហមប្រើខ្ញុំឲ្យទៅវែកដីនៅស្វាយទាប ព្រៃដើមស្នឹង និងដកស្ទូងនៅស្វាយពោធិ។ បន្ទាប់មក ខ្ញុំទៅទួលបុង និងទួលមេប៉ា ដើម្បីវែកដី និងដកស្ទូងសំណាបបន្តទៀត។ នៅពេលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ

១៩៧៥ ខ្មែរក្រហមជម្លៀសខ្ញុំទៅនៅពាមជីកង ដោយខ្ញុំត្រូវឡើងទៅដេកចាំនៅតាមចិញ្ចើមថ្នល់ បន្ទាប់មកប្រធានកងហៅខ្ញុំឲ្យឡើងឡាននៅចុងភូមិ នៅពេលយប់។ ប្រធានកងនាំខ្ញុំទៅដកសំណាប និងបោកបែនស្រូវ។ តមក ខ្ញុំបានទៅភូមិផ្ទះកណ្ដាលត្រៀមខ្លួនទៅសែងអ្នករបួសដែលវាយគ្នានៅវិហារសួគ៌ ហើយក្រោយពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ ១៩៧៩ ខ្ញុំនៅធ្វើស្រែចម្ការនៅភូមិចុងបឹងក្រោ ឃុំផ្ទះកណ្ដាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដដែល។

រឿងរ៉ាវដែលខ្ញុំចងចាំមិនភ្លេចក្នុងរបបខ្មែរក្រហម គឺការរស់នៅវេទនា មិនមានកន្លែងស្នាក់នៅសមរម្យ ការហូបចុកខ្វះខាត។ ប្រសិនបើខ្ញុំលួចលាក់ហូប ហើយខ្មែរក្រហមដឹង នឹងយកខ្ញុំទៅសម្លាប់ចោលមិនខាន។ ពេលដែលវាយដួង ខ្ញុំត្រូវកាន់ចានចូលរកពាងបបរនៅរោងបាយរួម បើនរណាទៅក្រោយគេ នឹងគ្មានបបរហូបឡើយ។ ពេលខ្លះចុងភៅបបរលាយពោត ពេលខ្លះហូបស្ងោរក្តិបឪឡឹកជាមួយត្រីប្រឡាក់។ ក្មេងជំនាន់ក្រោយ នឹងបានដឹងនៅពេលរៀនសូត្រពីរបបខ្មែរក្រហម។

> សម្ភាសន៍ និងសង្ខេបរឿងរ៉ាវដោយ៖ សេង វឌ្ឍនា អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថត៖ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៨) ឈឿន អេង



ខ្ញុំឈ្មោះ ឈឿន អេង អាយុ ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំកើតនៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាមនេះតែម្តង។ ខ្ញុំមានប្តីឈ្មោះ ពិល ឆុំ និងមានចំនួនកូន១១នាក់ ក្នុងនោះស្រី២នាក់ និងប្រុស៩នាក់។ ខ្ញុំមានឪពុកឈ្មោះ ឈឿន និងម្តាយឈ្មោះ សៀត។

កាលនៅវ័យកុមារ ខ្ញុំមិនបានរៀនច្រើនទេ លុះដល់វ័យចំណាស់បន្តិចទើបបានចូលរៀនអក្ខរកម្ម (ប្រកបពាក្យអាន និងសរសេរអក្សរ) នៅពេលយប់ នៅតាមផ្ទះអ្នកភូមិស្រុកខ្ញុំ។ កាលជំនាន់ដើមខ្ញុំបានរៀនត្រឹមថ្នាក់ទី២ ក៏ឈប់រៀនអំឡុងឆ្នាំ១៩៦៥ និងឆ្នាំ១៩៦៦ ដោយសារម្តាយរបស់ខ្ញុំមានកូនច្រើន ហើយគាត់រវល់ដកស្ទូង ដែលតម្រូវឲ្យខ្ញុំជាកូនច្បងនៅផ្ទះមើលថែប្អូនៗជំនួសម្តាយ។ ក្រៅពីមើលថែប្អូនៗ ខ្ញុំបានជួយធ្វើការងារស្រែចម្ការ ដកស្ទូង និងដាំដុះដំណាំផ្សេងៗ។

អំឡុងពេលរដ្ឋប្រហារឆ្នាំ១៩៧០ ខ្ញុំបានរៀបការជាមួយប្តី និងទៅរស់នៅស្រុកខាងប្តីអស់មួយរយៈ ទើបត្រឡប់មករស់នៅស្រុកកំណើតវិញ។ នៅពេលដែលមានសង្គ្រាម មានការបាញ់ផ្លោង ការទម្លាក់គ្រាប់បែក នៅដើមឆ្នាំ១៩៧០ ខ្ញុំនិងក្រុមគ្រួសារបាននាំគ្នារត់ទៅពួននៅក្នុងត្រង់សេដែលបានជីកទុកជាមុន។ នៅពេលដែលយន្តហោះទម្លាក់គ្រាប់ចេញទៅបាត់អស់ យើងក៏នាំគ្នាចេញមកក្រៅវិញ។ ទោះបីយ៉ាងណា ពុំមានការទម្លាក់គ្រាប់បែកត្រូវចំប្រជាជននៅក្នុងភូមិព្រែកដំបូកណាម្នាក់ឡើយ ថែមទាំងមិនមានការខូចខាតទ្រព្យសម្បត្តិទៀតផង ព្រោះពេលនោះមានការទម្លាក់គ្រាប់តែនៅខាងភូមិតាម៉ឺនប៉ុណ្ណោះ។ ទោះបីយ៉ាងណាខាងភូមិព្រែកដំបូកក្រោម មានយន្តហោះ ហោះក្រឡឹង និងឃ្លាំមើលជារឿយៗ។

នៅដើមឆ្នាំ១៩៧៥ ខ្ញុំចូលធ្វើការងារវែកដីនៅកងចល័ត។ ខ្ញុំត្រូវងើបពីម៉ោង៤ទៀបភ្លឺ តម្រង់ជួរទៅធ្វើការ ដោយក្រុមប្រុសៗលីចបជីកដី ឯក្រុមស្រីៗកាន់បង្គី ក្នុងមួយក្រុមមានសមាជិក១០នាក់។ ប្រជាជនខ្លះត្រូវបានខ្មែរក្រហមចាត់ឲ្យធ្វើជាចុងភៅ ឬអ្នកចាត់ចែងម្ហូបអាហារ នៅក្នុងរោងបាយ ដែលភាគច្រើនមានតែបបរលាយពោតក្រហម វាល់ចែកគ្នាហូបម្នាក់បន្តិចៗ។

នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំធ្វើការងារនៅភូមិព្រែកដំបូកក្រោមដដែល ព្រោះខ្ញុំគឺជាប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់។ ខ្ញុំធ្វើការងារដកស្ទូងនៅវាលស្រែ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ នៅដើមឆ្នាំ ១៩៧៩ ខ្ញុំប្រកបរបរធ្វើស្រែនៅភូមិកំណើតដដែល។ រឿងរ៉ាវដែលខ្ញុំបានចងចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហមគឺហូបមិនបានគ្រប់គ្រាន់ ដោយរបបបបរវាល់វែកចែកគ្នា។ លើកលែងនៅពេលមានកម្មវិធីជួបជុំ

ជប់លៀង គឺមានបង្អែមនំបាញ់ចានឿកៗ ខ្ញុំគឺជាប្រជាជនទទួលបានចំណែកនំម្នាក់មួយចានប៉ុណ្ណោះ ដូច្នេះខ្ញុំហូបមិនឆ្អែតទេ។ ខ្ញុំក៏ខសប្បាយហ៍បាននិយាយរឿងរ៉ាវទាំងនេះប្រាប់ចៅខ្លះៗដែរ ដើម្បីឲ្យកូនចៅចងចាំ និងដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

> *សម្ភាសន៍ និងសង្ខេបរឿងរ៉ាវដោយ ៖ ហាក់ គឹមលីង អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថត៖ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ៩) តន់ គីមសាន



ខ្ញុំឈ្មោះ តន់គីមសាន (ហៅកាន) អាយុ៥៦ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំកើតនៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម តែម្ដង។ ខ្ញុំមានប្ដីឈ្មោះ ស្តើង ស្រ៊ាន និងមានកូន៤នាក់ ក្នុងនោះ ស្រី២នាក់ និងប្រុស២នាក់។ ខ្ញុំមានឪពុកឈ្មោះ តន់ និងម្ដាយឈ្មោះ ជន និងមានបងប្អូន២នាក់ ប្រុសម្នាក់ និងស្រីម្នាក់។

កាលនៅវ័យកុមារ ខ្ញុំបានចូលរៀននៅសាលាបាក់បែកមួយនៅក្នុងភូមិ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី២ក៏ឈប់រៀន ព្រោះត្រូវមើលថែម្ដាយឈឺនៅឯផ្ទះ។ ពេលដែលមានសង្គ្រាម បាញ់ផ្លោង និងទម្លាក់គ្រាប់បែកនៅដើមឆ្នាំ១៩៧០ ខ្ញុំនៅតែក្នុងរណ្ដៅ ព្រោះមានការទម្លាក់គ្រាប់បែកនៅវត្តប្រាសាទវង្គី (វត្តត្បូង)។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំរស់នៅ និងធ្វើស្រែនៅភូមិព្រែកដំបូកក្រោម។ នៅពេលដែលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំគឺជាកសិករ និងមានជីវភាពលំបាក។ ខ្ញុំដើរស្ទូងដករកត្រីក្ដាម លក់យកលុយទិញអង្ករហូប។ ក្រៅពីនោះ ខ្ញុំស៊ីឈ្នួលរែកទឹកឲ្យអ្នកភូមិ ហើយពេលខ្លះអ្នកភូមិឲ្យត្រប់យកដុតហូបជំនួសបាយ មិនមែនស្រួលដូចសព្វថ្ងៃទេ។ រឿងរ៉ាវដែលខ្ញុំនៅចាំមិនភ្លេចមកដល់បច្ចុប្បន្ននេះគឺខ្ញុំមិនមានអង្ករដាំបាយហូបនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំចង់ឲ្យក្មេងៗចងចាំ និងដឹងពីរបបខ្មែរក្រហម និងឲ្យក្មេងៗធ្វើតែអំពើល្អ។

> *សម្ភាសន៍ និងសង្ខេបរឿងរ៉ាវដោយ ៖ ហាក់ គឹមលីង អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថត៖ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ១០) ស្តើង ស្រ៊ាន



ខ្ញុំឈ្មោះ ស្តើង ស្រ៊ាន អាយុ៥៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំកើតនៅភូមិទួលស្រឹង ឃុំញ្ញោ ទី១ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។ ខ្ញុំមានប្រពន្ធឈ្មោះ តន់ គីមសាន និងមានកូន៤នាក់ ក្នុងនោះ ស្រី២នាក់ និងប្រុស២នាក់។ ខ្ញុំមានឪពុកឈ្មោះ ស្តើង និងម្ដាយឈ្មោះ វុន និងមានបងប្អូន៥នាក់ គឺស្រី២នាក់ និងប្រុស៣នាក់។

នៅឆ្នាំ១៩៧០ ខ្ញុំបានចូលរៀននៅសាលានៅឯខេត្តព្រៃវែង។ ខ្ញុំរៀនដល់ថ្នាក់ទី៤ ក៏ឈប់រៀន។ បន្ទាប់មក ខ្ញុំជួយធ្វើស្រែចម្ការឪពុកម្ដាយ។ ពេលមានសង្គ្រាមបាញ់ផ្លោង និងទម្លាក់គ្រាប់បែក នៅដើមឆ្នាំ១៩៧០ ខ្ញុំរត់ចូលលាក់ខ្លួនក្នុងព្រៃ។ ខ្ញុំស្ពាយអង្ករមួយទៃទៅតាមខ្លួន។ ជួនកាលខ្ញុំកំពុងដាំបាយ ក៏ឮអ្នកភូមិស្រែកប្រាប់ថា គ្រាប់បែកទម្លាក់មកទៀតហើយ ខ្ញុំក៏ទុកឆ្នាំងចោល។

ពេលខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំរស់នៅ និងធ្វើការនៅព្រៃវែង។ ខ្ញុំធ្វើការងារស្រែចម្ការនៅកងចល័ត និងបររទេះគោក្របីដឹកអីវ៉ាន់ ដោយក្នុងមួយក្រុមមានសមាជិក១០នាក់។ ខ្ញុំគឺជាសមាជិកកង ដូច្នេះត្រូវទៅធ្វើការនៅម៉ោង៧ព្រឹក ហើយសម្រាកម៉ោង១១ថ្ងៃដើម្បីហូបបបរ។ លុះដល់ម៉ោង១រសៀល ខ្ញុំត្រូវចេញទៅធ្វើការ ហើយឈប់សម្រាកនៅម៉ោង៥ល្ងាច។ នៅក្នុងរបបខ្មែរក្រហម មានអ្នកស្លាប់ច្រើនណាស់ ដោយសារអត់អាហារ និងធ្វើការហួសកម្លាំង។

ក្រោយពេលរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ខ្ញុំនៅធ្វើការងារស្រែចម្ការដដែលៗ រឿងរ៉ាវដែលខ្ញុំចងចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហម គឺខ្មែរក្រហមយកបងប្រុស និងឪពុកខ្ញុំទៅសម្លាប់។ ខ្ញុំតែងនិយាយប្រាប់កូនចៅជំនាន់ក្រោយឲ្យចងចាំ និងដឹងអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមថា «ជំនាន់នោះ ហូបតែបបរមួយវែក ប៉ុន្តែសម័យនេះ ហូបចុកឆ្ងាញ់ៗណាស់»។

> *សម្ភាសន៍និងសង្ខេបរឿងរ៉ាវដោយ៖ ហាក់គីមលីង អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថត៖ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ១១) ជា សែ



ខ្ញុំឈ្មោះ ជា សែ មានអាយុ ៧៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិ៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំកើតនៅភូមិឃុំនេះតែម្តង។ ខ្ញុំមានប្តីឈ្មោះ ហុង និងមានកូន៨នាក់។ ម្តាយរបស់ខ្ញុំបានស្លាប់ចោលខ្ញុំតាំងពីគាត់អាយុ៣៧ឆ្នាំ។ ខ្ញុំមិនបងចាំរឿងរ៉ាវទាក់ទងនឹងម្តាយរបស់ខ្ញុំច្រើនទេ ព្រោះយូរហើយ។ ខ្ញុំចាំត្រឹមឈ្មោះគាត់តែប៉ុណ្ណោះ ដោយម្តាយខ្ញុំឈ្មោះ ដុល ចំណែកឪពុកឈ្មោះ ឡុង។

ខ្ញុំរៀនត្រឹមថ្នាក់ទី២ក៏ឈប់រៀន ហើយមកប្រកបរបរធ្វើចម្ការវិញ។ នៅឆ្នាំ១៩៧០ ពេលរដ្ឋប្រហារខ្ញុំរស់នៅភ្នំពេញ។ ក្រោយមកខ្ញុំក៏រត់ភៀសខ្លួនមកនៅដីហែបានមួយរយៈ ក៏មករស់នៅចុងកោះជាមួយ ចិត្តា ប្រធានភូមិ៦សព្វថ្ងៃ។ នៅពេលនោះក៏មានការទម្លាក់គ្រាប់បែកដែរ ដូច្នេះខ្ញុំត្រូវរត់ចូលលាក់ខ្លួនក្នុងត្រង់សេ។ ក្រៅពីនោះ ក៏មានការបាញ់ផ្លោងពីក្រុងកំពង់ចាមមកដីហែដែរ។ ការទម្លាក់គ្រាប់បែកនិងការបាញ់ផ្លោងមិនបានធ្វើឲ្យខូចខាតទ្រព្យសម្បត្តិរងរបួស និងស្លាប់ប្រជាជនឡើយ។

នៅពេលខ្មែរក្រហមឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាត់ខ្ញុំឲ្យលើកទំនប់នៅភូមិចុងកោះយ៉ាងលំបាកវេទនា។ ពេលខ្លះខ្ញុំលួចយំ ព្រោះការងារលំបាកវេទនាខ្លាំងពេក។

ពេលនោះ ឈ្មោះ សុរុនភី គឺជាអ្នកគ្រប់គ្រងដឹកនាំខ្ញុំឲ្យវែកដី។ ក្នុងរបបខ្មែរក្រហម ប្អូនខ្ញុំឈ្មោះ ម៉េង និង ម៉ុង ត្រូវបានខ្មែរក្រហមយកទៅវាយសម្លាប់ចោលនៅក្បាលកោះ។ ពេលចប់របបខ្មែរក្រហម ខ្ញុំមករស់នៅភូមិ៥វិញ។ ខ្ញុំតែងតែនិយាយប្រាប់កូនចៅ នូវរឿងរ៉ាវក្នុងរបបខ្មែរក្រហមដែលលំបាកវេទនាណាស់ មិនដូចឥឡូវទេ ហើយក៏មិនចង់ឲ្យកើតរបបនេះម្តងទៀតដែរ។

> *សម្ភាសន៍និងសង្ខេបរឿងរ៉ាវដោយ៖ ហ៊ាន សុធារី អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ នៅខេត្តកំពង់ចាម។ (រូបថត៖ សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ១២) កេត សុខឃី



ខ្ញុំឈ្មោះ កេត សុខឃី អាយុ ៦៥ឆ្នាំ បច្ចុប្បន្នខ្ញុំរស់នៅ ភូមិត្នោតលើ ឃុំប៉ុសរ្សី ស្រុកស្រុកស្រីសន្ធរ ខេត្តកំពង់-ចាម។ ខ្ញុំមានបងប្អូន៦នាក់ និងមានប្តីឈ្មោះ ទូច គួង (ស្លាប់) ព្រមទាំងមានកូនចំនួន៤នាក់។

នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលមកដល់ភូមិ ខ្មែរក្រហមចាប់ផ្តើមឲ្យប្រជាជនហូបរួមធ្វើការងាររួម ចំណែករបបអាហារមានតែបបរមួយមុខប៉ុណ្ណោះ។ ពេលនោះ ខ្ញុំនៅកងចល័ត ហើយខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅវែកដី នៅស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលមានរយៈពេលបីខែ ជាមួយសមាជិក៣០០នាក់។ ប៉ុន្តែ អំឡុងពេលលើកទំនប់ខ្ញុំមុតជើងធ្វើការមិនកើត ទើបខ្មែរក្រហមបញ្ជូនខ្ញុំមកស្រុកកំណើតវិញ។ នៅពេលដែលជើងខ្ញុំជាសះស្បើយ ខ្មែរក្រហមតម្រូវឲ្យខ្ញុំទៅសែងកងទ័ពដែលត្រូវរបួសយកមកព្យាបាលនៅមន្ទីរពេទ្យ។ អ្នករងរបួសទាំងអស់នោះត្រូវបានសែងមកពីស្រុកកងមាស និងកោះដាច់ យកមកទុកត្រឹមមាត់ទន្លេមេគង្គ។ ខ្មែរក្រហមបានឲ្យខ្ញុំទៅសែងអ្នករបួសពី

មាត់ទន្លេមេគង្គ យកមកព្យាបាលនៅភូមិត្នោតលើ ឃុំបុស្សឫស្សី ស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ មួយរយៈក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅធ្វើជាចុងភៅនៅឃុំស្វា ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ប៉ុន្តែខ្មែរក្រហមមិនបានឲ្យខ្ញុំដាំស្ល ទេ បែរជាឲ្យខ្ញុំទៅលាងពាងចំនួន៣៥ពាង សម្រាប់ដាក់បបរឲ្យប្រជាជនទៅវិញ។ ក្រោយមកទៀត ខ្មែរក្រហមបានឲ្យខ្ញុំមកធ្វើជាអ្នកចែកថ្នាំពេទ្យឲ្យអ្នកជំងឺ គឺមានថ្នាំបេអង និងថ្នាំអាចម៍ទន្សាយ។

ខ្ញុំបានរៀបការនៅរបបខ្មែរក្រហម ដែលពេលរៀបការម្តងៗមានចំនួន៦០គូ។ ពេលដែលរៀបការរួចហើយ ខ្មែរក្រហមបានចែកសម្លៀកបំពាក់ខោអាវខ្មៅម្នាក់មួយសម្រាប់។ ខ្ញុំរៀបការបានរយៈពេល២០ថ្ងៃ ប្រទេសកម្ពុជាក៏ត្រូវបានរំដោះពីរបបខ្មែរក្រហម។ ក្រោយពីប្រទេសបានរំដោះ ខ្ញុំបានរស់នៅភូមិត្នោតលើ ឃុំបុស្សឫស្សី ស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាមដដែល។ គ្រួសាររបស់ខ្ញុំបានប្រកបរបរដាំដំណាំ និងស៊ីឈ្នួលដាំដំណាំដើម្បីចិញ្ចឹមជីវិតរហូតមកដល់សព្វថ្ងៃ។

*សម្ភាសន៍ និងសង្ខេបរឿងរ៉ាវដោយ៖ សាំង ចាន់ធូ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (រូបថត៖ លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ចុះសួរសុខទុក្ខ និងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកស្រីសន្ធរ និងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ (សាំង ចាន់ធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វគ្គណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨

## ប្រចាំខេត្តកំពង់ចាម ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ការចុះស្រាវជ្រាវ និងការចងក្រងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*សាំង ចាន់ធូ*



អ្នកស្ម័គ្រជំនាន់ទី៨របស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តកំពង់ចាម ចូលរួមវគ្គណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចុះស្រាវជ្រាវ និងចងក្រងសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៧ ខែមករា ឆ្នាំ២០២៤ គឺជាខួបលើកទី៤៥ឆ្នាំ ដែលប្រជាជនកម្ពុជាត្រូវបានសង្គ្រោះ និងរំដោះចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តកម្ពុជា ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ការចុះស្រាវជ្រាវ និងការចងក្រងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។ សិក្ខាកាមជាអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តកំពង់ចាម សរុបចំនួន១៥៦នាក់ ត្រូវបានជ្រើសរើសមកពីស្រុកកំពង់សៀម, ស្រុកកោះសូទិន, ស្រុកស្រីសន្ធរ និងស្រុកជើងព្រៃ។ សិក្ខាសាលានេះត្រូវបានចែកចេញជាពីរក្រុម ដោយក្រុមទីមួយមានការចូលរួមពីយុវជនមកពីស្រុកស្រីសន្ធរ ដែលបានធ្វើឡើងនៅថ្ងៃទី៦ ខែមករា និងក្រុមយុវជនមកពីស្រុក

កំពង់សៀម, កោះសូទិន និងស្រុកជើងព្រៃ បានចូលរួមកម្មវិធីនៅក្នុងថ្ងៃទី៧ ខែមករា ឆ្នាំ២០២៤។ វគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងពីរថ្ងៃនេះមានគោលបំណងដូចតទៅ ៖

១) បង្កើនចំណេះដឹងប្រវត្តិសាស្ត្រខ្មែរក្រហម
២) ពង្រឹងសមត្ថភាព និងការត្រៀមលក្ខណៈរួចរាល់ក្នុងការចុះជួប និងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
៣) ផ្តល់ចំណេះដឹងអំពីការសរសេររឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
៤) ពិភាក្សាទៅប្រធានបទស្រាវជ្រាវ និងការចូលរួមដំណើរទស្សនកិច្ចតាមរថភ្លើង ក្រោមប្រធានបទ៖ «ការជម្លៀសដោយបង្ខំ»
៥) ស្តាប់បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

នៅក្នុងឱកាសនោះ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ធ្វើបង្ហាញ និងពន្យល់អ្នកស្ម័គ្រចិត្តទាំងអស់ឲ្យឈ្វេងយល់ពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានផ្តោតសំខាន់ទៅលើ៖ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំ, ទុក្ខវេទនា និងការកាប់សម្លាប់ទៅលើប្រជាជន, ការធ្វើឲ្យសុខភាពរបស់ប្រជាជនចុះទ្រុឌទ្រោម, វិសុទ្ធកម្មទៅលើកម្មាភិបាល និងប្រជាជននៅភូមិភាគបូព៌ា និងការដួលរំលំរបបខ្មែរក្រហម។

បន្ទាប់ពីបទបង្ហាញទាក់ទងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ លោក សាំង ចាន់ធូ ប្រធានក្រុមការងារអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តកំពង់ចាម ធ្វើបទបង្ហាញអំពីការពង្រឹងសមត្ថភាព និងការត្រៀមលក្ខណៈរួចរាល់ក្នុងការចុះជួប និងស្តាប់រឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លោក សាំង ចាន់ធូ គូសបញ្ជាក់អំពីការយល់ដឹងជាមុនអំពីរឿងរ៉ាវប្រវត្តិសាស្ត្រ, ការយកសៀវភៅកត់ត្រាខណៈពេលស្តាប់ និងកត់ត្រាការនិយាយប្រាប់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ឧបករណ៍សម្រាប់ថតសំឡេង និងរូបភាព, និងការរក្សាទុកឯកសារយ៉ាងមានសុវត្ថិភាព និងត្រឹមត្រូវ។ បន្ថែមលើនេះទៀត លោក សាំង ចាន់ធូ ក៏ប្រាប់អំពីវិធីសាស្ត្រនៃការសរសេររឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដោយបានបង្ហាញអត្ថបទចំនួន៦ចេញពីបទសម្ភាសន៍របស់ក្រុមការងារនាពេលកន្លងមក។

ជាកិច្ចបន្ត លោក ស៊ាង ចិន្តា ដឹកនាំកិច្ចពិភាក្សាទៅលើការជ្រើសប្រធានបទស្រាវជ្រាវ និងដំណើរទស្សនកិច្ចតាមរថភ្លើង។ លោក ស៊ាង ចិន្តា បានបង្ហាញដល់អ្នកស្ម័គ្រចិត្តអំពីកម្មវិធីស្រាវជ្រាវ ដែលត្រូវបានរៀបចំឡើង និងបណ្តុះបណ្តាលយុវជន-យុវនារីជំនាន់ថ្មី ក្នុងផ្នែកស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហម។ អ្នកស្ម័គ្រចិត្តនឹងត្រូវបែងចែកជាក្រុមស្រាវជ្រាវ និងកំណត់យកប្រធានបទ។ បន្ទាប់មកសមាជិកក្រុមនីមួយៗជ្រើសរើសយកសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលទាក់ទងប្រធានបទខ្លួនដើម្បីធ្វើការសរសេរ ខណៈចុះជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានរបស់ខ្លួន។ បន្ទាប់ពីផ្ញើសំណេរជ្រាវស្រាវព្រាងលើកទី១របស់ខ្លួនតាមក្រុមនីមួយៗ ក្រុមការងារនឹងធ្វើការពិនិត្យដើម្បីកំណត់ថា ក្រុមស្រាវជ្រាវដែលមានប្រធានបទទាក់ទងនឹងដំណើរទស្សនកិច្ចតាមរថភ្លើង គឺត្រូវបានជ្រើសរើសចូលរួមដំណើរទស្សន-កិច្ចនាពេលខាងមុខនេះ។



អ្នកស្ម័គ្រជំនាន់ទី៨របស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចុះស្រាវជ្រាវ និងចងក្រងសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការស្តាប់ និងសួរនាំអំពីបទពិសោធន៍ផ្ទាល់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាផ្នែកមួយដ៏សំខាន់ក្នុងការបំពាក់បំប៉នវិធីសាស្ត្រ និងបណ្តុះទំនុកចិត្តក្នុងការចុះសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អ្នកស្ម័គ្រចិត្តទទួលបានឱកាសជួបសន្ទនា និងសួរនាំផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣រូបគឺយាយ សៀង ហេន និង យាយ កែវ ម៉ុន ដែលជាអតីតអ្នកធ្វើការងារនៅកងចល័តខ្មែរក្រហម និងលោក តុង សុភា គឺជាតំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣រូបសប្បាយចិត្តជាខ្លាំងដែលមានឱកាសនិយាយប្រាប់បទពិសោធន៍ និងការចងចាំទុក្ខវេទនារបស់ខ្លួនទៅកាន់ក្មេងៗជំនាន់ក្រោយ និងបានបញ្ជាក់ថា ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាថ្ងៃកំណើតទី២របស់គាត់។ យាយ សៀង ហេន និងយាយ កែវ ម៉ុន បាននិយាយប្រាប់អំពីបទពិសោធន៍ធ្វើការងារហួសកម្លាំង ហូបចុកមិនគ្រប់គ្រាន់ និងការស្លាប់ប្រជាជននៅពេលនោះ។ ចំណែកឯលោក តុង សុភា រំឭកអំពីការបាត់បង់ឪពុកដោយការចាប់យកទៅសម្លាប់ចោលរបស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី។ បន្ទាប់ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣រូបបានបញ្ចប់ការរៀបរាប់រឿងរ៉ាវរបស់ខ្លួន អ្នកស្ម័គ្រចិត្តចោទសួរសំណួរជាច្រើន ដែលអូសបន្លាយរយៈពេលជិត១ម៉ោង។ កិច្ចសន្ទនាអន្តរជំនាន់នេះមានសារសំខាន់ក្នុងការកសាងទំនុកចិត្តប្រាស្រ័យទាក់ទងរបស់អ្នកស្ម័គ្រចិត្ត ដែលជាយុវជនយុវនារីជំនាន់ក្រោយ ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។










អ្នកស្ម័គ្រជំនាន់ទី៨របស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តកំពង់ចាម ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ការចុះស្រាវជ្រាវ និងការចងក្រងសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!















# វេទិកាផ្សព្វផ្សាយអប់រំពីការថែទាំសុខភាពឱ្យប្រសើរឡើងជាងមុនដល់ជនពិការក្នុងស្រុកអន្លង់វែង

**មេក វិន**







នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និង មជ្ឈមណ្ឌលឯកសារកម្ពុជា រួមទាំងនិស្សិតស្ម័គ្រចិត្តផ្នែកសុខភាពសាធារណៈ បានរៀបចំវេទិកាផ្សព្វផ្សាយ និង អប់រំពីការថែទាំសុខភាពឲ្យប្រសើរឡើងជាងមុន ដល់ប្រជាជនពិការភាព ចំនួន៦២នាក់ ក្នុងនោះមានស្រីចំនួន ២២នាក់ នៅភូមិអូរក្រញូង ភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រួមទាំងនិស្សិតស្ម័គ្រចិត្តផ្នែកសុខភាពសាធារណៈ ទូទៅ បានរៀបចំវេទិកាផ្សព្វផ្សាយ និងអប់រំពីការថែទាំសុខភាពឲ្យប្រសើរឡើងជាងមុនដល់ជនពិការ ចំនួន៦២នាក់ ក្នុងនោះមានស្រីចំនួន២២នាក់ នៅភូមិអូរក្រញូង ភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

អន្លង់វែង គឺជាតំបន់ចុងក្រោយនៃការបញ្ចប់សង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ អន្លង់វែង បានបន្សល់ទុកនូវជនពិការជាច្រើនរួមមាន ពិការជើង ពិការដៃ ពិការភ្នែក ពិការបង្កេះ និងស៊ិតដៃជើង ដោយសារប្រតិកម្មថ្នាំនៅអំឡុងពេលសង្គ្រាម។

ការរៀបចំវេទិកាផ្សព្វផ្សាយ និង អប់រំអំពីការថែទាំសុខភាពឲ្យប្រសើរឡើងជាងមុនដល់ជនពិការនេះ គឺជាលើកទីពីរក្នុងតំបន់អន្លង់វែង បន្ទាប់ពីយុវជនស្ម័គ្រចិត្តកម្ពុជា បានចុះសួរសំណួរស្ទាបស្ទង់មតិអំពីបញ្ហាសុខភាព រួមទាំងបញ្ហាប្រឈមផ្សេងៗ ដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានជួបប្រទះកន្លងមក។ វេទិកានេះត្រូវបានធ្វើឡើងនៅក្នុងបរិវេណវត្តស្រះឈូក ដែលជាទីតាំងចេតិយ តាម៉ុក មេដឹកនាំដ៏មានឥទ្ធិពលនៅក្នុងតំបន់អន្លង់វែង។ តាម៉ុក បានស្លាប់ដោយសារជំងឺរបេងកាលពីឆ្នាំ២០០៦

បន្ទាប់ពីបញ្ជូនទៅកាន់មន្ទីរពេទ្យកេតុមាលា ក្នុងទីក្រុងភ្នំពេញ។ កាលនៅរស់ តាម៉ុក បានដឹកនាំចលនាខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩៨ ខណៈដែលកងកម្លាំងខ្មែរក្រហមនៅសេសសល់ទាំងអស់បានផ្តាច់ខ្លួនចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា។

ជាកិច្ចចាប់ផ្តើមដំបូងនៃវេទិកា អ្នកស្រី គីម សុវណ្ណដានី អ្នកសម្របសម្រួលគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ចាប់ផ្តើមប្រកាសបើកកម្មវិធីដោយការណែនាំខ្លួន និងក្រុមការងារដល់អ្នកចូលរួម។ អ្នកស្រី គីម សុវណ្ណដានី ក៏បានលើកយករឿងរ៉ាវប្រវត្តិសាស្ត្រនៅជំនាន់ខ្មែរក្រហមមកពិភាក្សាមុននឹងចូលដល់ការពិភាក្សាអំពីសុខភាព។ ជាការពិតណាស់ប្រជាជនដែលធ្លាប់ជាអតីតកងទ័ពខ្មែរក្រហម ក៏ត្រូវបានចាត់ទុកថាជាជនរងគ្រោះដែលបានរស់រានមានជីវិតពីសម័យខ្មែរក្រហមដែរ។

បន្ទាប់មកវាគ្មិនចំនួន៣នាក់ គឺជានិស្សិតស្ម័គ្រចិត្តផ្នែកសុខភាពសាធារណៈ ឡើងធ្វើបទបង្ហាញ និងផ្លាស់ប្តូរមតិយោបល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអំពីរបៀបរស់នៅ និងការថែទាំសុខភាពប្រចាំថ្ងៃឲ្យកាន់តែប្រសើរឡើង។ ការពិភាក្សាមានបីដំណាក់កាល គឺ៖

**១) កញ្ញា ចន្ថា សិលារត្ន** គឺជានិស្សិតស្ម័គ្រចិត្តផ្នែកជំងឺទូទៅ បានលើកអំពីជំងឺសម្ពាធឈាម មកពិភាក្សា។ ជំងឺសម្ពាធឈាម មិនមែនមានន័យថា ឈាមលើសនោះទេ គឺមានន័យថា វាមានការស្ទះនៅត្រង់កន្លែងណាមួយនៅក្នុងរាងកាយមនុស្ស ដើម្បីធ្វើឲ្យប្រសើរឡើងវិញចំពោះបញ្ហានេះ គឺត្រូវតបរបបអាហារមួយចំនួន ដូចជា ឈប់ហូបអាហារមានជាតិហឹរ អាហារផ្អាប់ អាហារប្រៃ ជាពិសេសត្រូវកាត់បន្ថយការដឹកស្រា និងជក់បារី។ បន្ថែមពីនេះទៀត ត្រូវសម្រាកឲ្យបានគ្រប់គ្រាន់ និងហូបផ្លែឈើ អាហារបៃតង ខ្ទឹមស ចេក និងសាច់ត្រីឲ្យបានច្រើន។

**២) កញ្ញា គីម សុខសុធី** គឺជានិស្សិតស្ម័គ្រចិត្តផ្នែកជំងឺទូទៅ បាននិយាយអំពីការឆ្លងមេរោគផ្លូវបង្ហូរនោម និងជំងឺក្រពេញប្រូស្តាត។ ជំងឺទាំងពីរនេះបណ្តាលឲ្យពិបាកនោម និងឈឺចាប់ ដែលជាបញ្ហាប្រឈមសម្រាប់ជនពិការមួយចំនួន លំបាកក្នុងការចូលបន្ទប់អនាម័យ ដូច្នេះហើយបានជាងាយឆ្លងមេរោគ និងបង្កជាការឆ្លងមេរោគលើផ្លូវទឹកនោម។ ចំពោះជំងឺក្រពេញប្រូស្តាតកើតឡើងតែចំពោះបុរសវ័យចំណាស់។ ជំងឺទាំងពីរនេះអាចព្យាបាលបាន តាមរយៈវិធីសាស្ត្រ ដូចជា ការធ្វើលំហាត់ប្រាណ ឈប់ជក់បារី កាត់បន្ថយការសេពគ្រឿងស្រវឹង ផឹកទឹកឲ្យបានគ្រប់គ្រាន់ ហូបអាហារដែលមានវីតាមីន និងមានអនាម័យ។

**៣) កញ្ញា ម៉ាន់ សុឃីម** គឺជានិស្សិតស្ម័គ្រចិត្តផ្នែកជំងឺទូទៅបានលើកយកជំងឺសន្លាក់ និងជំងឺទឹកនោមផ្អែមប្រភេទទី២។ ជំងឺនេះភាគច្រើនកើតលើមនុស្សស្រី ហើយជំងឺនេះប៉ះពាល់ដល់បេះដូង ក្រពះ ខួរក្បាល ភ្នែក ដែរ។ ចំណែកជំងឺរលាកសន្លាក់ គឺជាចំណុចប្រសព្វគ្នារវាងឆ្អឹង ដែលនៅក្នុងឆ្អឹងនោះមានទឹកសន្លាក់ដែលបង្កើតឡើងលើមនុស្សចាស់ ព្រោះនៅពេលមនុស្សចូលដល់វ័យចាស់ ទឹកសន្លាក់បានបាត់បង់បន្តិចម្តងៗ ដែលបង្កឲ្យឈឺចុកចាប់ក្នុងរាងកាយ។ ចំពោះវិធីសាស្ត្រកាត់បន្ថយការឈឺសន្លាក់ ត្រូវធ្វើលំហាត់ប្រាណ បរិភោគប្រេងសណ្តែក ប្រេងល្ង ដែលមានសារធាតុជួយសម្រួលដល់ការឈឺសន្លាក់ និងការបរិភោគអាហារដែលមានអនាម័យល្អ។

ចុងបញ្ចប់នៃវេទិកាអ្នកស្រី គីម សុវណ្ណដានី បាននិយាយណែនាំដល់ប្រជាជនដែលបានចូលរួមក្នុងវេទិកា ដូចជា ត្រូវខិតខំប្រឹងធ្វើលំហាត់ប្រាណ ពិសាអាហារឲ្យបានត្រឹមត្រូវរស់នៅស្អាត និងត្រូវមានអនាម័យល្អក្នុងការរស់នៅប្រចាំថ្ងៃ ព្រមទាំងសម្រាន្តឲ្យបានគ្រប់គ្រាន់ជាពិសេស ត្រូវទៅពិនិត្យសុខភាពឲ្យបានមួយដងក្នុងមួយឆ្នាំ។ បន្ទាប់ពីវាគ្មិនធ្វើការណែនាំពីរបៀបការថែទាំសុខភាពរួចមក អ៊ំពូមីងដែលបានចូលរួមបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖



នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងមជ្ឈមណ្ឌលឯកសារកម្ពុជា រួមទាំងនិស្សិតស្ម័គ្រចិត្តផ្នែកសុខភាពសាធារណៈ បានរៀបចំវេទិកាផ្សព្វផ្សាយ និង អប់រំពីការថែទាំសុខភាពឲ្យប្រសើរឡើងជាងមុន ដល់ប្រជាជនពិការភាព ចំនួន៦២នាក់ ក្នុងនោះមានស្រីចំនួន២២នាក់ នៅភូមិអូរក្រញូង ភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**សួរ មុំ** ភេទប្រុស អាយុ៧៦ឆ្នាំ រស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង រៀបរាប់ថា វេទិកានេះល្អណាស់ដើម្បីការពារ និងថែទាំសុខភាពរបស់ខ្ញុំឲ្យបានប្រសើរឡើងជាងមុនៗ លើសពីនេះទៅទៀត ខ្ញុំទទួលបាននូវចំណេះដឹងក្នុងការការពារសុខភាពបានកាន់តែច្រើនឡើងៗ ថ្ងៃនេះខ្ញុំទទួលបានចំណេះដឹងអំពីវិធីសាស្ត្រទប់ស្កាត់កុំឲ្យសុខភាពទ្រុឌទ្រោមៗ បច្ចុប្បន្ន ខ្ញុំមានបញ្ហាព្រិលភ្នែក ចុករោយសន្លាក់ ស្ពឹកស្រពន់ រាងកាយជាប្រចាំៗ រោគសញ្ញាជំងឺប្រចាំកាយរបស់ខ្ញុំពាក់ព័ន្ធទម្លាប់មិនល្អៗ ខ្ញុំសប្បាយចិត្តពេលបានដឹងអំពីដំណោះស្រាយការពារ និងប្រុងប្រយ័ត្ន កែប្រែទម្លាប់មិនល្អទាំងនេះចោលៗ បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីនេះ ខ្ញុំនឹងពន្យល់ណែនាំទៅដល់បងប្អូនកូនចៅរបស់ខ្ញុំ រួមទាំងអ្នកជិតខាងរបស់ខ្ញុំ ឲ្យដឹងអំពីវិធីសាស្ត្រក៏ដូចជារបៀបរបបការហូបអាហារឲ្យមានសុខភាពល្អៗ ជាចុងក្រោយ ខ្ញុំសូមធ្វើការសំណូមពរទៅដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងអង្គភាពផ្សេងៗទៀត សូមឲ្យជួយផ្តល់សេវាកម្មពិនិត្យសុខភាពដល់ខ្ញុំ និងប្រជាជនដែលរស់នៅក្នុងភូមិជើងភ្នំបន្តទៀតៗ

**ធូច នឹម** ភេទប្រុស អាយុ៧៣ឆ្នាំ រស់នៅភូមិជើងភ្នំ មានប្រសាសន៍ថា ការអប់រំអំពីការថែរក្សាសុខភាពជូនដល់ប្រជាជននៅតាមទីជនបទជាការល្អខ្លាំងណាស់ៗ ជាក់ស្តែង ខ្ញុំបានចូលរួមក្នុងកម្មវិធីនេះ ធ្វើឲ្យខ្ញុំយល់ដឹងពីរបៀបរបបក្នុងការថែរក្សាសុខភាព ធ្វើឲ្យខ្ញុំយល់ដឹងពីវិធីសាស្ត្រការពារខ្លួនឯងពីជំងឺប្រចាំកាយ និងទទួលបាននូវចំណេះដឹងថ្មីៗដើម្បីថែទាំសុខភាពរបស់ខ្ញុំៗ ខ្ញុំក៏មានទម្លាប់មិនល្អ មិនចេះថែរក្សាអនាម័យ ហើយការរស់នៅតាមបែបបុរាណ បណ្តាលឲ្យខ្ញុំមានបញ្ហាសុខភាពជាច្រើន ដូចជា រលាកថ្លើម រលាកតម្រងនោម លើសឈាម និងឈឺក្រពះពោះវៀនៗ ប៉ុន្តែបន្ទាប់ពីខ្ញុំបានចូលរួមស្តាប់ការអប់រំណែនាំពីរបៀបថែទាំសុខភាពនៅថ្ងៃនេះរួចមក ខ្ញុំគិតថាខ្ញុំអាចកែប្រែទម្លាប់អាក្រក់មួយចំនួនរបស់ខ្ញុំប្តូររបៀបរបបរស់នៅដែលមានអនាម័យ ផឹកទឹកស្អាត និងហូបអាហារល្អមានអនាម័យៗ

ជាចុងក្រោយ ខ្ញុំពិតជាមានភាពសប្បាយរីករាយ និងមានអារម្មណ៍ជ្រះថ្លាជាខ្លាំង។

**សយ សាយ** ភេទប្រុស អាយុ៧០ឆ្នាំ រស់នៅភូមិដើងភ្នំ លើកឡើងថា ខ្ញុំពិតជាមានសេចក្តីត្រេកអរជាខ្លាំងដែលបានគ្រូពេទ្យមកជួយពន្យល់ណែនាំពីវិធីសាស្រ្តធ្វើលំហាត់ប្រាណដើម្បីសុខភាព។ ការធ្វើបែបនេះ ធ្វើឲ្យខ្ញុំយល់ដឹងបានមួយកម្រិតទៀតទាក់ទងទៅនឹងរោគសញ្ញាផ្សេងៗ និងប្រភេទជំងឺនីមួយៗ ដែលងាយស្រួលក្នុងការទៅរកពេទ្យពិនិត្យសុខភាពឲ្យបានត្រឹមត្រូវ។ ខ្ញុំមានទម្លាប់មិនល្អមួយចំនួនដែលធ្វើឲ្យប៉ះពាល់ដល់សុខភាព ដូចជា ការផឹកស្រា ជក់បារី និងការសម្រាកមិនគ្រប់គ្រាន់។ បន្ទាប់ពីស្តាប់ការណែនាំរបស់គ្រូពេទ្យរួចហើយ ខ្ញុំនឹងអនុវត្តតាមគ្រូពេទ្យ ដូចជា កាត់បន្ថយការជក់បារី និងការផឹកស្រាជាដើម។ ចំណែករបបអាហារផ្សេងៗខ្ញុំត្រូវកាត់បន្ថយការហូបអាហារប្រៃ។ ខ្ញុំនឹងចែករំលែកការយល់ដឹងរបស់ខ្ញុំទៅអ្នកដទៃទាក់ទងទៅនឹងរបបអាហារថាតើអាហារមួយណាដែលត្រូវហូប និងអាហារមួយណាមិនត្រូវហូប និងប្រាប់ឲ្យពួកគេកាត់បន្ថយនូវការពិសារគ្រឿងកំប៉ុងជាដើម។ ជាចុងក្រោយ ខ្ញុំចង់បានការពិនិត្យសុខភាពដល់ប្រជាជនក្នុងមូលដ្ឋានស្រុកអន្លង់វែងនេះជាបន្តទៀត។

**នាង មាន** ភេទស្រី អាយុ៦៨ឆ្នាំ រស់នៅភូមិដើងភ្នំ រៀបរាប់ថា ជំងឺដែលប្រជាជនប្រឈមនៅពេលបច្ចុប្បន្នគឺ ជំងឺលើសឈាម និងជំងឺទឹកនោមផ្អែម។ ចំពោះសុខភាពខ្ញុំនាពេលនេះគឺមិនមានបញ្ហាប្រឈមអ្វីឡើយ ដោយសារខ្ញុំធ្វើពលកម្មច្រើនរួមជាមួយនឹងការហូបចុកមានរបៀបរបប ហើយខ្ញុំមិនហូបរបបអាហារណាតាមតែចិត្តខ្ញុំឃ្លានឡើយ។ ទោះបីជាសុខភាពខ្ញុំល្អប្រសើរយ៉ាងណាក៏ដោយ ខ្ញុំក៏នៅមានទម្លាប់មិនល្អមួយចំនួនដែលអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់ខ្ញុំដែរ គឺការធ្វើការងារហួសកម្លាំង។ ក្រោយស្តាប់ការពន្យល់ពីក្រុមគ្រូពេទ្យរួចខ្ញុំអាចការពារខ្លួនឯងបានច្រើនជាងមុន និងអាចធ្វើលំហាត់ប្រាណនៅផ្ទះបាន។ ការដែលបង្កើតក្រុមគ្រូពេទ្យចុះមកពិនិត្យសុខភាពផ្ទាល់បែបនេះ ខ្ញុំគិតថាជាការល្អប្រសើរ ពីព្រោះប្រជាជននៅក្នុងភូមិភាគច្រើនមិនសូវបានយល់ដឹងពីបញ្ហាសុខភាពនោះទេ។ ជាចុងក្រោយនេះ ខ្ញុំសូមសំណូមពរដល់ក្រុមការងារចុះមកធ្វើការអប់រំអំពីសុខភាពឲ្យបានច្រើនជាងនេះ ពីព្រោះចាស់ៗមានបញ្ហាសុខភាពច្រើន។





នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងមជ្ឈមណ្ឌលឯកសារកម្ពុជា រួមទាំងនិស្សិតស្ម័គ្រចិត្តផ្នែកសុខភាពសាធារណៈ បានរៀបចំវេទិកាផ្សព្វផ្សាយ និង អប់រំពីការថែទាំសុខភាពឲ្យប្រសើរឡើងជាងមុន ដល់ប្រជាជនពិការភាព ចំនួន៦២នាក់ ក្នុងនោះមានស្រីចំនួន២២នាក់ នៅភូមិអូរគ្រញ៉ូង ភូមិដើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

## រៀបចំវេទិកាអប់រំសហគមន៍ស្ដីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សវិទ្យាល័យព្រែកដំបូក និងដឹកនាំសិស្សទស្សនកិច្ចទំនប់ក្នុងរបបខ្មែរក្រហម

**ទូច វណ្ណាត**







*នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្ដីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សវិទ្យាល័យព្រែកដំបូកចំនួន៥០នាក់ និងដឹកនាំសិស្សទស្សនកិច្ចទំនប់ក្នុងរបបខ្មែរក្រហម។ (លី ដេវីត/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២ មកពីវិទ្យាល័យព្រែកដំបូកសរុបចំនួន៥០នាក់ ចូលរួមវេទិកាអប់រំសហគមន៍ស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ«សុខភាពទ្រុឌទ្រោមរបស់ប្រជាជនក្នុងរបបខ្មែរក្រហម» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងបានចុះទស្សនកិច្ចផ្ទាល់ទៅកាន់ទំនប់ដែលត្រូវបានកសាងនៅក្នុងរបបខ្មែរក្រហម រួមមាន ទំនប់តាកុដ ស្ថិតនៅឃុំមៀន ស្រុកព្រៃឈរ (ជាប់ព្រំប្រទល់នឹងស្រុកកងមាស) និងទំនប់ក្បាលទឹកឆា ស្ថិតនៅក្នុងឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ជាកិច្ចចាប់ផ្ដើមលោក ស៊ាង ចិន្ដា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបានឡើងស្វាគមន៍ និងប្រកាសបើកវេទិកាថ្នាក់រៀន។ បន្ទាប់មក លោក ស៊ាង ចិន្ដា ធ្វើបទបង្ហាញយ៉ាងខ្លីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រជាជនកម្ពុជាឆ្លងកាត់រាល់ទុក្ខវេទនា ការបែកបាក់

គ្រួសារ និងការបាត់បង់ជីវិត។ លោក ស៊ាង ចិន្តា បានបង្កើតកិច្ចពិភាក្សាទៅលើប្រធានបទ «សុខភាពទ្រុឌទ្រោមរបស់ប្រជាជនក្នុងរបបខ្មែរក្រហម» ដោយផ្តោតទៅលើផែនការ៤ឆ្នាំរបស់ខ្មែរក្រហម ដែលចាប់ផ្តើមពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៨០។ ផែនការ៤ឆ្នាំ ត្រូវបានដាក់ចេញជាផែនការសំខាន់ ដែលផ្តោតទៅលើវិស័យកសិកម្ម ដូចជា ការបង្កើនទិន្នផលស្រូវ និងការកសាងទំនប់ជាដើម។

បន្ទាប់ពីបទបង្ហាញ និងការពិភាក្សាបានបញ្ចប់ សិស្សានុសិស្សបានជួប និងស្តាប់ការចែករំលែកបទពិសោធន៍ផ្ទាល់ របស់អ្នករស់មានជីវិតពីរបបខ្មែរក្រហមចំនួន២រូប ដូចខាងក្រោម ៖

**ហែម ច័ន** អាយុ៧៦ឆ្នាំ អតីតកងចល័តខ្មែរក្រហម រស់នៅក្នុងភូមិក្រូចសើច ឃុំកោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម និយាយរៀបរាប់ប្រាប់សិស្សានុសិស្សចូលរួមអំពីសាវតា និងបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមដូចខាងក្រោម ៖

«ខ្ញុំកើតនៅភូមិស្មៀរគ្គី ឃុំញ្ញោ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនសរុបចំនួន៣នាក់ គឺប្រុស១នាក់ និងស្រី២នាក់។ កាលនៅវ័យក្មេង ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាវត្តសំពៅដុល និងទៅរៀនបន្តនៅវត្តមួយទៀតឈ្មោះសាលាបឋមសិក្សាជ្រៃក្រាំង ស្ថិតក្នុងស្រុកពារាំង ខេត្តព្រៃវែង។ ខ្ញុំឈប់រៀនត្រឹមថ្នាក់ទី១០ចាស់ ដោយសារតែកម្រិតជីវភាពគ្រួសារក្រីក្រ និងកំព្រាឪពុក។ ខ្ញុំជួយម្តាយខ្ញុំភ្ជួរស្រែ។

ក្រោយមកទៀត ខ្ញុំបួសជាព្រះសង្ឃបាន២ព្រះវស្សា គឺចាប់ពីឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៦៤។ បន្ទាប់ពីលាចាកសិក្ខាបទ ខ្ញុំរៀបការប្រពន្ធ និងមករស់នៅខាងគ្រួសារប្រពន្ធនៅស្រុកស្រីសន្ធរ នៅឆ្នាំ១៩៦៩។ ខ្ញុំបានដឹងថាមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ពីសេនាប្រមុខ លន់ នល់ នៅឆ្នាំ១៩៧០។ នៅចុងឆ្នាំ១៩៧០ អ្នកភូមិចាប់ផ្តើមរត់ចូលព្រៃម៉ាគីដើម្បីប្រឆាំងនឹងរបបលន់នល់។ ខ្ញុំមិនបានរត់ទៅជាមួយអ្នកភូមិទាំងនោះទេ ពីព្រោះខ្ញុំមានប្រពន្ធ និងកូនស្រីម្នាក់។

ចន្លោះពីឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ កងទ័ពរំដោះខ្មែរក្រហមបានបញ្ជូនកងទ័ពមកឈរជើង និងរំដោះភូមិសាស្ត្រជាច្រើននៅក្នុងស្រុកស្រីសន្ធរ គឺរួមទាំងមូលដ្ឋានដែលខ្ញុំរស់នៅដែរ។ ទាហាន លន់នល់ និងកងទ័ពរំដោះខ្មែរក្រហម ប្រយុទ្ធគ្នានៅសមរភូមិជាច្រើនទាំងផ្លូវគោក និងផ្លូវទឹក ខណៈពេលខ្លះ ទាហាន លន់ នល់ បើកការវាយប្រហារពីអាកាសដោយការបាញ់រះ ឬការទម្លាក់គ្រាប់បែកពីយន្តហោះ។ ខ្ញុំធ្លាប់ឃើញយន្តហោះ ទាហាន លន់ នល់ ដូចជាអាស្ទាបកាត់ អាម៉ិច និងអាទ្រងជ្រូក។ រាល់ពេលដែលមានការទម្លាក់គ្រាប់បែកម្តងៗ ខ្ញុំនាំប្រពន្ធកូនរត់ចូលក្នុងរណ្តៅត្រង់សេ។ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះកាន់តែខ្លាំងឡើង ដែលភាគច្រើនកើតឡើងនៅតាមដងទន្លេមេគង្គ និងការបន្តទម្លាក់គ្រាប់បែកពីអាកាស។ កងទ័ពរំដោះខ្មែរក្រហម អាចត្រឹមបណ្តែតដើមគរ ឬដើមចេកបង្កៃគ្រាប់បែកពាសពេញទន្លេ នៅពេលដែលមានក្បួនធ្វើដំណើររបស់នាវា ទាហានម៉ារីន លន់ នល់។

បន្ទាប់ពីកងទ័ពរំដោះខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង ខ្ញុំឃើញមានប្រជាជន ១៧ មេសា បានមកដល់ភូមិនេះដែរ។ ក្រោយមកទៀត ប្រជាជន ១៧ មេសា ត្រូវបានជម្លៀសបន្តទៀត។ នៅឆ្នាំ១៩៧៦ សហករណ៍ត្រូវបានបង្កើត។ ខ្ញុំត្រូវបានចាត់តាំងធ្វើជាប្រធានកងរោងបាយរួម ចំណែកឯប្រពន្ធខ្ញុំទៅធ្វើការនៅកងចល័តវ័យកណ្តាល។ រោងបាយរួមរបស់ខ្ញុំទទួលត្រីពីកងនេសាទ និងស្រូវអង្ករពីឃ្លាំងសហករណ៍ដើម្បីដាំបបរ និងធ្វើម្ហូបសម្រាប់មនុស្ស១០០នាក់។ ខ្ញុំមើលការខុសត្រូវនៅរោងបាយ ចំណែកឯអនុប្រធានចាត់ចែងរបបអាហារនៅតាមការដ្ឋាន។ នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីមកគ្រប់គ្រង និងចាប់ផ្តើមចាប់មនុស្សយកទៅសម្លាប់។ ខ្មែរក្រហមមកពីភូមិភាគនិរតីចាប់ចង និងបណ្តើរមនុស្សយកទៅសម្លាប់ចោលនៅវត្តជ្រៃ។ ខ្ញុំឃើញបុគ្គលិកពេទ្យជាច្រើនត្រូវបានចាប់បណ្តើរយកទៅសម្លាប់នៅវត្តជ្រៃផងដែរ។ នៅខែវស្សាក្នុងឆ្នាំ១៩៧៨ ក្នុងកងរោងបាយរួមក៏មានការស្រាវជ្រាវអ្នកមកពីខាងមេមត់ដងដែរ ប៉ុន្តែខ្ញុំបានលាក់អត្តសញ្ញាណពួកគេ និងមិនមាននរណាម្នាក់នៅក្នុងកងខ្ញុំត្រូវបានចាប់យកទៅសម្លាប់នោះទេ។ ខ្ញុំបានជួយ

មិត្តឈ្មោះ នេន, មិត្ត វុធថា និងសុខៗ នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ ចូលមករំដោះប្រជាជនចេញពីការកាប់សម្លាប់ពីសំណាក់ខ្មែរក្រហមៗ ខ្ញុំនិងគ្រួសាររួចផុតពីសេចក្តីស្លាប់នៅពេលនោះ និងបន្តរស់នៅក្នុងភូមិនេះរហូតមកដល់បច្ចុប្បន្ន»ៗ

**ភេគ សុខឃី** មានអាយុ៦៥ឆ្នាំ រស់នៅភូមិត្នោតលើ ឃុំបុស្សឫស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម បានរំឭកអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមជាលើកដំបូងទៅកាន់សិស្សានុសិស្សខាងក្រោម៖

«កាលនៅពីកុមារភាព ខ្ញុំរៀនសូត្របានត្រឹមថ្នាក់ទី២ៗ ពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥ ខ្ញុំរស់នៅភូមិត្នោតលើ ឃុំបុស្សឫស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាមដោយមិនបានរត់គេចខ្លួនទៅកន្លែងណាទេ ខណៈដែលតំបន់នេះទទួលរងការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងៗ នៅពេលនោះ ខ្ញុំក៏ឃើញយន្តហោះមកពីទិសខាងលិចទម្លាក់គ្រាប់បែកៗ នៅឆ្នាំ១៩៧៦ សហករណ៍ត្រូវបានបង្កើតឡើង ដែលជាការចាប់ផ្តើមរបស់ប្រជាជនត្រូវតែហូបបាយរួមៗ

គិតត្រឹមឆ្នាំ១៩៧៦ ខ្ញុំមានអាយុ១៧ឆ្នាំ ត្រូវចូលធ្វើការក្នុងកងចល័តៗ នៅក្នុងកងចល័តខ្មែរក្រហមមានគ្នាប្រហែល៣០០នាក់ ដែលត្រូវធ្វើការងារជីកដី រែកដីនៅស្រុកស្វាយទាប ខេត្តស្វាយរៀង អស់រយៈពេល៣ខែៗ ក្នុងអំឡុងពេលលើកទំនប់ ខ្ញុំមុតជើងហើយធ្វើការងារមិនកើត ទើបខ្មែរក្រហមបញ្ជូនខ្ញុំមកស្រុកកំណើតវិញៗ បន្ទាប់ពីខ្ញុំព្យាបាលជើងជាសះស្បើយ ខ្មែរក្រហមចាត់តាំងខ្ញុំទៅសែងទ័ពដែលរងរបួសយកមកព្យាបាលៗ អ្នករងរបួសទាំងអស់នោះត្រូវបានសែងមកពីស្រុកកងមាស និងកោះដាច់ៗ អ្នករងរបួសត្រូវបានយកមកទុកនៅមាត់ទន្លេមេគង្គៗ ក្រោយមកទៀត ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅធ្វើជាចុងភៅ នៅឃុំស្វា ស្រុកស្រីសន្ធរ ប៉ុន្តែខ្មែរក្រហមមិនឲ្យខ្ញុំដាំស្លរអ្វីទេ បែរជាឲ្យខ្ញុំទៅលាងពាងចំនួន៣៥ពាងសម្រាប់ដាក់បបរៗ ក្រោយមកទៀត ខ្មែរក្រហមបានឲ្យខ្ញុំមកធ្វើជាអ្នកចែកថ្នាំពេទ្យឲ្យអ្នកជំងឺៗ ថ្នាំព្យាបាលនៅពេលនោះ គឺថ្នាំបេអង និងថ្នាំអាចម៍ទន្សាយៗ ខ្ញុំរៀបការនៅសម័យខ្មែរក្រហមកាលនោះអ្នករៀបការមានចំនួន៦០គូរៗ បន្ទាប់ពីរៀបការរួចរាល់ ខ្ញុំទទួលបានសម្លៀកបំពាក់ខោអាវខ្មៅម្នាក់មួយសម្រាប់ៗ ខ្ញុំរៀបការបានតែ២០ថ្ងៃប៉ុណ្ណោះ ប្រទេសកម្ពុជាត្រូវបានរំដោះពីខ្មែរក្រហមៗ ក្រោយមក ខ្ញុំវិលត្រឡប់មករស់នៅភូមិត្នោតលើ ឃុំបុស្សឫស្រុកវិញៗ ខ្ញុំ និងគ្រួសារ ប្រកបរបរដាំដំណាំ និងស៊ីឈ្នួលដាំដំណាំឲ្យគេរហូតដល់សព្វថ្ងៃ» ៗ

បន្ទាប់ពីស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតរបបខ្មែរក្រហមទាំង២រូបខាងលើ សិស្សានុសិស្សត្រូវបានបែងចែកជាក្រុមពិភាក្សា ដែលក្រុមនីមួយៗទទួលបានប្រធានបទពិភាក្សារៀងៗខ្លួន និងមានរយៈពេល៣០នាទីដើម្បីពិភាក្សាៗ បន្ទាប់មក សិស្សា-នុសិស្សទាំងអស់ត្រូវទៅទស្សនកិច្ចទីតាំងទំនប់ខ្មែរក្រហម គឺទំនប់តាកុង ស្ថិតនៅឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដើម្បីពិនិត្យមើលទិដ្ឋភាពទំនប់ផ្ទាល់ៗ





នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សវិទ្យាល័យព្រែកដំបូកចំនួន៥០នាក់ និងដឹកនាំសិស្សទស្សនកិច្ចទំនប់ក្នុងរបបខ្មែរក្រហមដោយផ្ទាល់ៗ
( លី ដេវីត/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

# កម្មវិធីពិនិត្យ និងអប់រំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកត្រពាំងប្រាសាទ

សួត វិចិត្រ







អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២១០នាក់ មកពីឃុំទំនប់ដាច់ ឃុំបាក់អន្លង់ ឃុំអូរស្វាយ ឃុំព្រះប្រឡាយ និង ឃុំត្រពាំងប្រាសាទ ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ទទួលសេវាពិនិត្យសុខភាពដោយឥតគិតថ្លៃពីក្រុមគ្រូពេទ្យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងចាប់ពីថ្ងៃទី២៨ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ២១០នាក់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ បានទទួលសេវាពិនិត្យសុខភាពដោយឥតគិតថ្លៃ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ វេទិកាសុខភាពនេះរៀបចំនៅវត្តប្រាសាទសន្តិភាព ឬ ហៅវត្តទំនប់ដាច់ (អតីតទីតាំងនៃការធ្វើសមាហរណកម្មរវាងកងទ័ពខ្មែរក្រហម និងរាជរដ្ឋាភិបាលកម្ពុជានៅកំឡុងឆ្នាំ១៩៩៩) ចាប់ពីថ្ងៃទី២៨ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤។ កម្មវិធីនេះមានការចូលរួមពីប្រជាជនមកពី៥ឃុំ ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ រួមមាន៖ ឃុំទំនប់ដាច់ ឃុំបាក់អន្លង់ ឃុំអូរស្វាយ ឃុំព្រះប្រឡាយ និងឃុំត្រពាំងប្រាសាទ ដែលក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាធ្លាប់ជួបសួរសុខទុក្ខ និងធ្លាប់ស្ដាប់រឿងរ៉ាវជីវិតពីរបបខ្មែរក្រហម ព្រមទាំងធ្លាប់បានផ្ដល់ព័ត៌មានអំពីស្ថានភាពសុខភាព។ គម្រោងនេះ មានគោលបំណងជំរុញការយល់ដឹងពីការថែទាំសុខភាពទៅកាន់ប្រជាជនគ្រប់រូប ជាពិសេសអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីឲ្យដឹងថាការពិនិត្យសុខភាពគឺមានសារសំខាន់ខ្លាំងណាស់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ត្រូវបានចាត់ទុកថា ជាក្រុមមនុស្សដែលងាយរងគ្រោះបំផុតដោយសារស្ថានភាពសុខភាព ពិការភាព ស្ថានភាពសេដ្ឋកិច្ចនៅមានកម្រិត និងកម្រិតនៃការអប់រំ។ ការពិនិត្យសុខភាព



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២១០នាក់ មកពីឃុំទំនប់ដាច់ ឃុំបាក់អន្លូង ឃុំអូរស្វាយ ឃុំព្រះប្រឡាយ និង ឃុំត្រពាំងប្រាសាទ ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ទទួលសេវាពិនិត្យសុខភាពដោយឥតគិតថ្លៃ ក្រុមគ្រូពេទ្យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងចាប់ពីថ្ងៃទី២៤ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នឹងជួយកាត់បន្ថយហានិភ័យទៅលើផ្នែកសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានមួយកម្រិត និងព្យាបាលទាន់ពេលវេលា។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានលើកឡើងនៅក្នុងឱកាសពិនិត្យសុខភាពនេះថា ដំណើរការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ និងឱកាសទទួលបានការពិនិត្យសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើការចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនពីរបបខ្មែរក្រហម និងការខិតខំប្រឹងប្រែងចុះជួប និងប្រមែប្រមូលទិន្នន័យរបស់អ្នកស្ម័គ្រចិត្តកម្ពុជា។

គិតត្រឹមឆ្នាំ២០២៣ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥៥ឆ្នាំឡើងទៅ ប្រមាណ៤៤១នាក់នៅក្នុងខេត្តឧត្តរមានជ័យ ក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាង៣២.000នាក់នៅទូទាំងប្រទេសកម្ពុជា ត្រូវបានអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តឧត្តរមានជ័យ ចុះសួរសុខទុក្ខ និងស្តាប់រឿងរ៉ាវរបស់ពួកគាត់ចាប់តាំងពីការរាតត្បាតជំងឺកូវីដ-១៩។ គិតត្រឹមពេលនេះ អ្នកស្ម័គ្រចិត្តកម្ពុជានៅខេត្តឧត្តរមានជ័យប្រមាណ ១00នាក់ កំពុងធ្វើកិច្ចការសុខភាពជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

នៅអំឡុងពេលពិនិត្យសុខភាព ក្រុមគ្រូពេទ្យជំនាញបានផ្តល់សារដាស់តឿនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមកចូលរួម។ ជាទូទៅមានជំងឺ១០មុខភាគច្រើនកើតមានលើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមមាន៖ ជំងឺលើសឈាម, ជំងឺក្រពះពោះវៀន, ជំងឺគ្រុនចាញ់, ជំងឺផ្លូវចិត្ត, ជំងឺបេះដូង, ជំងឺរលាកសន្លាក់, ជំងឺហឺតរ៉ាំរ៉ៃ, ជំងឺទឹកនោមផ្អែម, ជំងឺរបេង និងជំងឺស្ពឹកជ្រុក ។ នៅក្នុងឱកាសនោះ ក្រុមគ្រូពេទ្យជំនាញក៏បានសង្កត់ធ្ងន់ដែរថា បើទោះបីជាជំងឺមួយចំនួនមិនមានការឆ្លងពីមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ក៏ដោយ ក៏ការផ្លាស់ប្តូររបបអាហារ និងទម្លាប់រស់នៅរបស់ក្រុមគ្រួសារនីមួយៗ គឺជារឿងសំខាន់ ដោយសារវាមានទំនាក់ទំនងនឹងការទទួលទានរបបអាហារ និងអនាម័យក្នុងការរស់នៅប្រចាំថ្ងៃ។





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២១០នាក់ មកពីឃុំទំនប់ដាច់ ឃុំបាក់អន្លូង ឃុំអូរស្វាយ ឃុំព្រះប្រឡាយ និង ឃុំត្រពាំងប្រាសាទ ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ទទួលសេវាពិនិត្យសុខភាពដោយឥតគិតថ្លៃពីក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ចាប់ពីថ្ងៃទី២៤ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីកម្មវិធីពិនិត្យសុខភាព ក៏មានការចែកសៀវភៅ «ព័ត៌មានថែទាំសុខភាព» ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ។

ខាងក្រោមនេះ គឺជាការយល់ឃើញរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលចូលរួមក្នុងកម្មវិធីពិនិត្យ និងអប់រំសុខភាព៖

**យ៉ង់ យឹន** ភេទប្រុស អាយុ៧៩ឆ្នាំ មានប្រសាសន៍ថា «ខ្ញុំបានយល់ដឹងពីសារសំខាន់នៃការថែទាំសុខភាព ព្រមទាំងទទួលបានសៀវភៅអប់រំសុខភាព»។ ពាក្យមួយម៉ាត់ថា សុខភាព គឺជ្រៅជ្រះណាស់ ដោយមួយតួអង្គរបស់មនុស្សយើងម្នាក់ៗ គឺអាស្រ័យទៅលើសុខភាព។ យើងអាចធ្វើដំណើរទៅណាមកណាបាន ក៏អាស្រ័យទៅលើសុខភាព។ ដើម្បីឲ្យសុខភាពយើងប្រសើរឡើង គឺយើងត្រូវលះបង់ចោលទម្លាប់មិនល្អ ហើយងាកចាប់យកទម្លាប់ល្អ ដូចជាការយកចិត្តទុកដាក់ទៅលើផ្នែកអនាម័យ និងមិនត្រូវហូបអាហារតាមចិត្តចង់នោះទេ។ យើងត្រូវហូបអាហារណាដែលសមស្របតាមសុខភាពរបស់យើងម្នាក់ៗ។ ចុងក្រោយ ខ្ញុំក៏គ្រេកអរចំពោះការទទួលបានសៀវភៅ ទាក់ទងការថែទាំសុខភាពដែលមានតម្លៃសម្រាប់ខ្ញុំ»។

**សុត ខួន** ភេទស្រី អាយុ៧០ឆ្នាំ រៀបរាប់ថា «ខ្ញុំអរគុណសម្រាប់ការផ្តល់ឱកាសឲ្យខ្ញុំបានពិនិត្យសុខភាព។ ខ្ញុំគិតត្រឡប់ទៅវិញថា ប្រសិនបើជំនាន់ប៉ុល ពត យើងចាំតែស្លាប់ទេ ដោយសារគ្មានថ្នាំព្យាបាល និងហូបចុកមិនឆ្អែត។ ខ្ញុំធ្លាប់លួចកាកបបរដែលកំពុងក្តៅមកហូបនៅក្នុងសហករណ៍ ដោយសារស្រេកឃ្លានខ្លាំងពេក ដែលបណ្តាលឲ្យខ្ញុំរលាកក្រពះមកដល់ពេលបច្ចុប្បន្ន។ តាមរយៈការអប់រំសុខភាពនេះ ខ្ញុំនឹងប្រាប់បន្តទៅកាន់អ្នកភូមិផ្សេងទៀតដែលមិនបានចូលរួមឲ្យបានដឹងអំពីការថែទាំសុខភាព»។

**អ៊ូច គឿន** ភេទស្រី អាយុ៧០ឆ្នាំ លើកឡើងថា «ខ្ញុំសប្បាយចិត្តដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះមកពិនិត្យសុខភាពដល់មូលដ្ឋានប្រជាពលរដ្ឋ។ ការពិនិត្យសុខភាពនេះ គឺធ្វើឲ្យយើងងាយស្រួលព្យាបាលនៅពេលបានដឹងពីជំងឺណាមួយ និងទិញថ្នាំលេបបានត្រឹមត្រូវ។ ខ្ញុំមើលឃើញថា ទម្លាប់មិនល្អដែលធ្វើឲ្យប៉ះពាល់ដល់សុខភាព គឺផ្នែកអនាម័យ។ មនុស្សយើងម្នាក់ៗសុខភាពល្អឬមិនល្អ គឺអាស្រ័យលើការហូបចុក និងរស់នៅប្រចាំថ្ងៃ។ ខ្ញុំបានយកចិត្តទុកដាក់ទៅលើផ្នែកអនាម័យ ដោយសារជីវភាពរបស់ខ្ញុំក្រលំបាក ដូចនេះប្រសិនបើមានបញ្ហាសុខភាពណាមួយ ខ្ញុំគ្មានថវិកាសម្រាប់ព្យាបាលទេ»។

**ឃុត សឹម** ភេទប្រុស អាយុ៨១ឆ្នាំ ឲ្យដឹងថា «បន្ទាប់ពីបានចូលរួមក្នុងវេទិកាពិនិត្យសុខភាព ខ្ញុំបានពិនិត្យ និងពិគ្រោះយោបល់ជាមួយគ្រូពេទ្យ គឺធ្វើឲ្យខ្ញុំសប្បាយចិត្តដោយសារបានដឹងពីសុខភាពផ្ទាល់ខ្លួន។ ខ្ញុំបានប្រឈមនឹងជំងឺលើសសម្ពាធឈាម។ បន្ទាប់ពីខ្ញុំបានស្តាប់ការណែនាំពីគ្រូពេទ្យ ខ្ញុំសម្រេចចិត្តថា ខ្ញុំត្រូវ

តែទៅមន្ទីរពេទ្យដើម្បីព្យាបាលដោយផ្ទាល់»។

**ឡឹក មុំ** ភេទស្រី អាយុ៦៣ឆ្នាំ «បន្ទាប់ពីខ្ញុំបានចូលរួមនៅក្នុងវេទិកាពិនិត្យសុខភាពនេះហើយ ខ្ញុំយល់ឃើញថាល្អ ដោយសារក្រុមគ្រូពេទ្យបានពិនិត្យសុខភាពដោយផ្ទាល់ជូនខ្ញុំដើម្បីបានដឹងពីស្ថានភាពជំងឺ។ ខ្ញុំបានប្រឈមនឹងការលើសជាតិស្ករ និងជំងឺសម្ពាធឈាមឡើងខ្ពស់។ បន្ទាប់ពីខ្ញុំបានដឹងពីបញ្ហាសុខភាពរបស់ខ្លួនរួចហើយ គឺខ្ញុំត្រូវតែទៅមន្ទីរពេទ្យរៀងរាល់មួយសប្តាហ៍ម្តង ហើយលេបថ្នាំឲ្យបានទៀងទាត់ ព្រមទាំងតមចំណីអាហារមួយចំនួនផង។

**ណេត ទ៉ុន** ភេទស្រី អាយុ៦៤ឆ្នាំ រៀបរាប់ថា «បន្ទាប់ពីខ្ញុំបានចូលរួមក្នុងវេទិកាពិនិត្យសុខភាពនេះរួច ខ្ញុំបានដឹងពីស្ថានភាពជំងឺនៅក្នុងខ្លួនរបស់ខ្ញុំ។ ខ្ញុំប្រឈមនឹងជំងឺឈឺក្រពះពោះវៀនរ៉ាំរ៉ៃ ដែលលទ្ធផលនេះនឹងជំរុញឲ្យខ្ញុំត្រូវតែទៅទិញថ្នាំដើម្បីព្យាបាលដើម្បីទទួលបានសុខភាពល្អ។ ជាចុងក្រោយខ្ញុំពិតជាសប្បាយចិត្តដោយសារទទួលបានការពិនិត្យសុខភាព និងពិសាអាហារជុំគ្នា»។

**វេន រី** ភេទស្រី អាយុ៧៣ឆ្នាំ លើកឡើងថា «បន្ទាប់ពីខ្ញុំទទួលបានការពិនិត្យ និងពិគ្រោះយោបល់អំពីសុខភាពរួចមក ខ្ញុំមានអារម្មណ៍សប្បាយចិត្ត និងបានដឹងពីប្រភេទថ្នាំដើម្បីព្យាបាលជំងឺនោះផងដែរ។ អ្វីដែលសំខាន់ ខ្ញុំចង់ចាំថា ដើម្បីថែរក្សាសុខភាពឲ្យបានល្អ គឺយើងត្រូវចេះរក្សាអនាម័យ និងសម្អាតរាងកាយ។ ក្រុមគ្រូពេទ្យបានពិនិត្យឃើញថា ខ្ញុំមានជំងឺលើសសម្ពាធឈាម, ឈឺក្បាលជន្លង់ និងចុករោយនៅតាមសន្លាក់ដៃជើងដែរ។ ខ្ញុំត្រូវតែទៅរកថ្នាំលេបឲ្យបានទៀងទាត់ ដើម្បីកុំឲ្យជំងឺរើឡើង។ ជាចុងក្រោយ ខ្ញុំពិតជាមានអារម្មណ៍ល្អ ដោយសារទទួលបានទាំងការពិនិត្យសុខភាព និងពិសាអាហារជុំគ្នាដែរ»។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២១០នាក់ មកពីឃុំទំនប់ដាច់ ឃុំបាក់អន្លង់ ឃុំអូរស្វាយ ឃុំព្រះប្រឡាយ និង ឃុំត្រពាំងប្រាសាទ ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ទទួលសេវាពិនិត្យសុខភាពដោយឥតគិតថ្លៃ ពីក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ចាប់ពីថ្ងៃទី២៤ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

***លី ដេវីត***



នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើប្រធានបទ៖ «សុខភាពទ្រុឌទ្រោមរបស់ប្រជាជន និងការដួលរលំរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប សរុបចំនួន៥០នាក់។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើប្រធានបទ៖ «សុខភាពទ្រុឌទ្រោមរបស់ប្រជាជន និងការដួលរលំរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សថ្នាក់ទី១២ នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប សរុបចំនួន៥០នាក់។ គោលបំណងនៃការរៀបចំវេទិកាថ្នាក់រៀននេះឡើង គឺដើម្បីផ្តល់ចំណេះដឹងដល់យុវសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការចុះផ្ទាល់ទៅកាន់ទំនប់ដែលត្រូវបានកសាងនៅក្នុងរបបខ្មែរក្រហម គឺទំនប់ក្បាលទឹក ស្ថិតនៅក្នុងឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ចាប់ផ្តើមកម្មវិធីលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ឡើងធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយនិយាយផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារសម្តេចព្រះ នរោត្តម សីហនុ ពីសេនាប្រមុខ លន់ នល់ នៅឆ្នាំ១៩៧០, សង្គ្រាមជិត៥ឆ្នាំ រវាងទាហាន



នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើប្រធានបទ៖ «សុខភាពទុក្ខទោមរបស់ប្រជាជន និងការដួលរលំរបបខ្មែរក្រហម» ដោយមានការចូលរួមដោយសិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប សរុបចំនួន៥០នាក់។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជនទៅកាន់ជនបទ, ការបង្ខំប្រជាជនឲ្យធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ និងការកាប់សម្លាប់ទៅលើប្រជាជន។ លោក ស៊ាង ចិន្តា បន្តថា ការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហមមានពដំណាក់កាលធំៗ៖

- ដំណាក់កាលទី១៖ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមកជនបទនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥
- ដំណាក់កាលទី២ ៖ ការជម្លៀសប្រជាជនដែលនៅសេសសល់នៅក្នុងទីក្រុងភ្នំពេញតាមរថភ្លើងដែលមាន២ខ្សែ រួមមាន ខ្សែទី១ គឺពីភ្នំពេញទៅខេត្តតាកែវ និងកំពត និងខ្សែទី២ គឺពីភ្នំពេញទៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ។
- ដំណាក់កាលទី៣ ៖ ការជម្លៀសប្រជាជនភូមិភាគបូព៌ាទៅខេត្តពោធិ៍សាត់ និងបាត់ដំបង នៅចន្លោះឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨។ ការបង្ខំប្រជាជនឲ្យធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ គឺផ្នែកមួយដែលធ្វើឲ្យប្រជាជនកម្ពុជាទទួលរងបញ្ហាសុខភាពទុក្ខទោម បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានដួលរលំ។ ការបង្កើតផែនការ៤ឆ្នាំ (១៩៧៧-១៩៨០) របស់ខ្មែរក្រហម ដែលផ្តោតសំខាន់ទៅលើវិស័យកសិកម្ម បង្កើនទិន្នផលស្រូវ។ ដើម្បីសម្រេចបានជោគជ័យ ខ្មែរក្រហមបានផ្តោតការយកចិត្តទុកដាក់ទៅលើការកសាងប្រព័ន្ធធារាសាស្ត្រ ដោយបានប្រមូលផ្តុំ និងបង្ខំប្រជាជនឲ្យធ្វើការកសាងទំនប់ស្តុកទឹក។ ប្រជាជនទទួលរងការបង្ខំឲ្យធ្វើការងារគ្មានពេលសម្រាក, ការបង្អត់អាហារ, ការធ្លាក់ខ្លួនឈឺគ្មានថ្នាំព្យាបាល និងការកាប់សម្លាប់ ដែលបណ្តាលឲ្យប្រជាជនស្លាប់បាត់បង់ជីវិតយ៉ាងច្រើន។

ជាកិច្ចបន្តលោក ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំ សិស្សចូលរួមដើរទស្សនាពិព័រណ៍ចំនួន១០ផ្ទាំង ដែលបង្ហាញអំពី

ឈ្មោះ តួនាទី និង ប្រវត្តិរូប មេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន រូបភាពធ្វើការងារក្នុងការដ្ឋាន ទំនប់ និងការវិលត្រឡប់មកស្រុកកំណើតវិញរបស់ប្រជាជនកម្ពុជា បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម នៅដើមឆ្នាំ១៩៧៩។ លោក ទូច វណ្ណេត ក៏ពន្យល់អំពីនិមិត្តសញ្ញារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលតំណាងឲ្យបេសកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការស្វែងរកការពិត ដើម្បីឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលបានយុត្តិធម៌ និងការចងចាំដែលមិនត្រូវបានបំភ្លេចនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ បន្ទាប់មក សិស្សចូលទស្សនាពិព័រណ៍ព្រះឆាយាលក្ខណ៍ចំនួន១៨ផ្ទាំង ដែលជាផ្នែកមួយនៃពិព័រណ៍ «ក្តីសុបិនកម្ពុជា» របស់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាចុងក្រោយ សិស្សបន្តទៅកាន់បណ្ណាល័យខ្មែរក្រហមដែលមានតម្កល់សៀវភៅទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហមជាច្រើន និងតម្កល់ឯកសារខ្មែរក្រហម។

កម្មវិធីបន្ទាប់ គឺលោក លី ដេវីត បុគ្គលិកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំសិស្សទៅទស្សនាទីតាំងទំនប់កសាងក្នុងរបបខ្មែរក្រហមដែលស្ថិតនៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម។ លោក លី ដេវីត បានឲ្យសិស្សស្រមៃទៅអតីតកាលដែលប្រជាជនកម្ពុជាទទួលរងទុក្ខវេទនានៅពេលលើកទំនប់នេះ។ ទំនប់នេះបច្ចុប្បន្នប្រែក្លាយទៅជាអាងស្តុកទឹក និងរមណីយដ្ឋាន សម្រាប់ប្រជាជនក្នុងខេត្តកំពង់ចាមមកកម្សាន្ត។

កម្មវិធីបញ្ចប់ គឺការពិភាក្សាទៅលើប្រធានបទ៖ «សុខភាពទ្រុឌទ្រោមរបស់ប្រជាជន និងការដួលរលំរបបខ្មែរក្រហម» ដោយបានបែងចែកសិស្សទាំងអស់ទៅជា៥ក្រុមពិភាក្សា។ ក្រុមពិភាក្សាទាំង៥ទទួលបានសំណួរបែបបំផុសគំនិត និងត្រិះរិះពិចារណា និងឯកសារពាក់ព័ន្ធមួយចំនួន។ ក្រុមពិភាក្សាទាំងអស់មានរយៈ៣០នាទីដើម្បីអាន និងពិភាក្សាគ្នាក្នុងការឆ្លើយតបសំណួរដែលក្រុមរបស់ខ្លួនទទួលបាន។ ខាងក្រោមនេះគឺជាការលើកឡើងរបស់ក្រុមពិភាក្សានីមួយៗ៖

- **ក្រុមទី១)** មានសមាជិកក្រុមរួមមាន៖ ធន វិរៈ, ហ៊ី កន, ឡឿន ស្រីពេជ្រ, សាក់ ស្រីនួន, ឡុញ សុខលី, មៀស ស្រីពេជ្រ, សៀប នាង, វ៉ៃ សុដានិត និង វង្ស វន្នេត ត្រូវពិភាក្សាលើសំណួរ ៖ «មូលហេតុអ្វីបានជាប្រជាជនកម្ពុជាមានសុខភាពទ្រុឌទ្រោមនៅក្នុងសម័យខ្មែរក្រហម»? ចម្លើយ គឺកត្តាដែលធ្វើឲ្យប្រជាជនមានសុខភាពទ្រុឌទ្រោម បណ្តាលមកពីប្រជាជនត្រូវធ្វើការលើកទំនប់ហួសកម្លាំង, មិនមានអាហារហូបគ្រាប់គ្រាន់ ធ្វើការងារគ្មានពេលសម្រាក និងធ្លាក់ខ្លួនឈឺដោយគ្មានថ្នាំព្យាបាលជាដើម។
- **ក្រុមទី២)** មានសមាជិកក្រុម រួមមាន ៖ រិត ស៊ីណេ, ម៉ៅ លីតា, ហេង លីណា, ឡុញ ទីន, ហៀង សុខហេង, ឌឹម សុស៊ីថាវណ្ណ និង ស្រេង លាងស្រ៊ុង ត្រូវពិភាក្សាលើសំណួរ ៖ «ចូររៀបរាប់ពីកត្តាដែលបណ្តាលឲ្យមានអ្នកស្លាប់ច្រើន នៅតាមការដ្ឋានក្នុងសម័យខ្មែរក្រហម»? ចម្លើយគឺមានកត្តាច្រើនបណ្តាលឲ្យមនុស្សស្លាប់ ដូចជា ៖ ការធ្វើវិសុទ្ធកម្ម, កង្វះស្បៀងអាហារ, ការប្រើប្រជាជនឲ្យធ្វើការងារគ្មានពេលឈប់សម្រាក គ្មានអាហារហូបគ្រប់គ្រាន់, ខ្មែរក្រហមចោទទៅលើប្រជាជនថាជាខ្មាំង និង ឈឺគ្មានថ្នាំព្យាបាលត្រឹមត្រូវ។
- **ក្រុមទី៣)** មានសមាជិកក្រុម រួមមាន ៖ អាត់ ចាន់ពិសី, ថា លីហ្សា, ឡូ ចន្ទមិនា, ឡោ ស្រីពេជ្រ, សុខរីម បុត្រី, វិត រ៉ាវីត, រី ដាវីន និង នួន សុខហេង ត្រូវពិភាក្សាលើសំណួរ៖ «មូលហេតុមួយក្នុងចំណោមមូលហេតុទាំងពាធំៗ ដែលធ្វើឲ្យខ្មែរក្រហមដួលរលំ»? ចម្លើយគឺ មកពីខ្មែរក្រហមបានធ្វើសង្គ្រាមជាមួយវៀតណាម។ ខ្មែរក្រហមបានបញ្ជូនកងទ័ពទៅព្រំដែនវៀតណាមដើម្បីធ្វើសង្គ្រាមតាមព្រំដែនរហូតដល់កងទ័ពវៀតណាមបានប្រើប្រាស់កាំភ្លើងទំនើប និងយន្តហោះវាយមកលើកងទ័ពខ្មែរក្រហមវិញ។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើង។ កងទ័ពរណសិរ្ស

សាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពវៀតណាមបានវាយលើកងទ័ពខ្មែរក្រហមឲ្យដកថយ និងរំដោះទីក្រុងភ្នំពេញបាននៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាស្ថាពរ។

• **ក្រុមទី៤)** មានសមាជិកក្រុម រួមមាន៖ ឡាង មុីមុី, វួន សុភា, មុីយ ចន្នី, ម៉ន ម៉េងលី, ម៉ៅ សំភព, ងីង ស, ចំរើន ភារម្យ, ប៉ាន ចន្ថា និង លី ម៉េងជួរ ពិភាក្សាលើសំណួរ ៖ «ចូររៀបរាប់ស្ថានភាពទូទៅនៃទំនប់ក្បាលទឹក»? ចម្លើយគឺ ទំនប់ក្បាលទឹក ត្រូវបានប្រែក្លាយទៅជាកន្លែងស្តុកទឹក កន្លែងទេសចរណ៍ ដែលមានទេសភាពស្ងប់ស្ងាត់ ស្អាតក្នុងពេលបច្ចុប្បន្ន ប៉ុន្តែ ទំនប់ក្បាលទឹក គឺធ្វើឡើងដោយកម្លាំងប្រជាជនដែលត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការងារហួសកម្លាំង។ ទំនប់ក្បាលទឹកគឺជាទីតាំងប្រវត្តិសាស្ត្រឲ្យក្មេងជំនាន់ក្រោយសិក្សាឈ្វេងយល់ និងជាទីកន្លែងដែលមានប្រជាជនបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមច្រើន។

• **ក្រុមទី៥)** មានសមាជិកក្រុម រួមមាន ៖ នៅ ស្រីសរ, ឈើន ណាម៉េងលី, ចក់ រតនា, វ័យ នីសា, រៀម ហុងលី, ឈឿង សុផាត, ឈុនអុី ភារិ, ថាច់ រដ្ឋា និង សុខុម ស្រីខួច ពិភាក្សាលើសំណួរ៖ «ចូររៀបរាប់ស្ថានភាពរបស់ប្រជាជនកម្ពុជា បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩?» ក្រោយពីរបបខ្មែរក្រហមដួលរលំ ស្ថានភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមត្រូវទទួលរង ដូចជា ៖ រងនូវវិបត្តិផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ, បាត់បង់សមាជិកគ្រួសារ, បន្សល់ទុកក្មេងកំព្រា, បន្សល់ទុកស្ត្រីមេម៉ាយជាច្រើន, បន្សល់ទុកនូវជនពិការ, ការបាត់បង់នូវធនធានមនុស្ស និងការអត់ឃ្លានរបស់ប្រជាជនបន្ទាប់ពីអំពើប្រល័យពូជសាសន៍។





នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើប្រធានបទ៖ «សុខភាពទ្រុឌទ្រោមរបស់ប្រជាជន និងការដួលរលំរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប សរុបចំនួន ៥០នាក់។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែងចុះពិនិត្យសុខភាព បឋមជូន ព្រះសង្ឃ ជនពិការ អ្នករស់រាន មានជីវិតពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ចំនួន២២០នាក់ នៅស្រុកវាលវែង និងស្រុកភ្នំក្រវាញ

ឡុង ដានី







ចន្លោះពីថ្ងៃទី១៦ ដល់ ទី១៧ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំពិនិត្យសុខភាពបឋមជូនព្រះសង្ឃ ជនពិការ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន២២០នាក់ នៅភូមិចំនួន៣ គឺភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង និងភូមិសំរោងទី២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងមជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន៖ លោក ឡុង ដានី, អ្នកស្រី គីម សុវណ្ណដានី, លោក សុខវណ្ណៈ, លោក ធី គីមហុង, លោក ចាន់ ណារិទ្ធ, កញ្ញា មឿង ស្រីណុច, កញ្ញា ឡាំ ស្រីនីត និងក្រុមវេជ្ជបណ្ឌិតបម្រើការងារនៅមន្ទីរពេទ្យ ខេរី បានរៀបចំពិនិត្យសុខភាពបឋមជូនព្រះសង្ឃ ជនពិការ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន២២០នាក់ នៅភូមិចំនួន៣ គឺភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង និងភូមិសំរោងទី២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ អ្នករស់រានមានជីវិតទាំងអស់ធ្លាប់ផ្តល់បទសម្ភាសន៍អំពីបញ្ហាផ្នែកសុខភាព និងរឿងរ៉ាវដែលធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) មកកាន់អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ ដំណើរការនៃការពិនិត្យសុខភាពជូនអ្នករស់រាន



ចន្លោះពីថ្ងៃទី១៦ ដល់ ទី១៧ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំពិនិត្យសុខភាពបឋមជូនព្រះសង្ឃ ជនពិការ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន២២០នាក់ នៅភូមិចំនួន៣ គឺភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង និងភូមិសំរោងទី២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានជីវិតពីរបបខ្មែរក្រហម គឺមានរយៈពេលពីរថ្ងៃ គឺថ្ងៃទី១៦ ដល់ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤។

សម្រាប់ថ្ងៃទី១៦ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងក្រុមវេជ្ជបណ្ឌិតនៃមន្ទីរពេទ្យខេរី បានរៀបចំពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១៨ នាក់ ស្ថិតក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ បន្ទាប់ពីពិនិត្យសុខភាពរួចរាល់ ក្រុមវេជ្ជបណ្ឌិតបានរកឃើញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងភូមិដីក្រហម ប្រមាណជា៩៥ភាគរយ មានជំងឺប្រចាំកាយ ដូចជា ជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម ជំងឺក្រពះពោះវៀន ជំងឺលើសជាតិអាស៊ីត ជំងឺសន្លាក់ និងជំងឺផ្លូវចិត្តជាដើម។ លោកវេជ្ជបណ្ឌិត ឡាវ ហាវ៉ាន មានប្រសាសន៍ថា «អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនលើសលប់មានជំងឺលើសសម្ពាធឈាម ឯជំងឺទឹកនោមផ្អែម ឈរនៅលំដាប់ទី២។ បន្ទាប់មកគឺជំងឺក្រពះពោះវៀន ជំងឺលើសអាស៊ីត និងជំងឺសន្លាក់»។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួន គឺជាជនពិការមានបញ្ហាសុខភាពធ្ងន់ធ្ងរ ដោយសារផលប៉ះពាល់នៃពិការភាពកាលពីសម័យសង្គ្រាម។ ក្នុងនោះក៏មានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួនមានជំងឺផ្លូវចិត្តដូចជាជំងឺធ្លាក់ទឹកចិត្ត និងជំងឺបាក់ស្បាតជាដើម។

សម្រាប់ថ្ងៃទី១៧ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងក្រុមវេជ្ជបណ្ឌិតបានរៀបចំពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១០២នាក់ នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រលវាលវែង និងភូមិសំរោងទី២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ក្រោយពីពិនិត្យសុខភាពរួចរាល់ទាំង ១០២នាក់ មក ក្រុមវេជ្ជបណ្ឌិតបានរកឃើញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៃស្រុកទាំងពីរ ខាងលើមានជំងឺប្រចាំកាយស្រដៀងនឹងអ្នករស់រានមានជីវិតរបបខ្មែរក្រហមនៅភូមិដីក្រហមដែរ គឺជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម ជំងឺក្រពះពោះវៀន ជំងឺលើសអាស៊ីត ជំងឺសន្លាក់ជាដើម។ លោកវេជ្ជបណ្ឌិត ឡុង ម៉ារ៉ាដែនបានផ្តល់របាយការណ៍ជាបឋមថា «អ្នករស់រានមានពីជីវិតពីរបបខ្មែរក្រហមមានជំងឺដូចបានរៀបរាប់ខាងលើ គឺភាគច្រើនដោយសារផលប៉ះពាល់មកពីរបបខ្មែរក្រហម វ័យចាស់ជរា និងរបៀបរបបរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ដូចជា

ការហូបអាហារមានរសជាតិផ្អែមខ្លាំង ប្រៃខ្លាំង ហូបអាហារផ្អាប់ទុកយូរដែលប្រើប្រាស់អំបិលច្រើន ភេសជ្ជៈកំប៉ុងដែលកម្រិតជាតិស្ករខ្ពស់ជាដើម»។

បន្ទាប់ពីបញ្ចប់កម្មវិធីពិនិត្យសុខភាពលោកវេជ្ជបណ្ឌិត ឡាវ ហាវ៉ាន និងលោកវេជ្ជបណ្ឌិត ឡុង ម៉ារ៉ាដែន បានណែនាំឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ត្រូវផ្លាស់ប្តូររបបអាហារ ដូចជាការកាត់បន្ថយការហូបប្រៃ ហូបផ្អែម តបផឹកស្រា និងឈប់ជក់បារី។ ម្យ៉ាងទៀតសូមឲ្យអ្នកជំងឺពិសារថ្នាំតាមវេជ្ជបញ្ជាឲ្យបានត្រឹមត្រូវ និងត្រូវទៅពិនិត្យសុខភាពនៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យណាមួយឲ្យបានទៀតទាត់។

នៅចុងបញ្ចប់នៃកម្មវិធីទាំងពីរថ្ងៃ អ្នករស់រានមានជីវិតរបបខ្មែរក្រហមបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំបាទឈ្មោះ **វ៉ែត យ៉ុន** មានអាយុ៥៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយដែលខាងមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានអញ្ជើញក្រុមគ្រូពេទ្យមកពិនិត្យសុខភាពដល់ខ្ញុំ និងប្រជាជនដែលរស់នៅក្នុងភូមិដីក្រហម ដែលអាចឲ្យខ្ញុំនិងប្រជាជនឯទៀតបានដឹងច្បាស់ថាខ្លួនកំពុងកើតមានជំងឺអ្វី ដើម្បីព្យាបាលទប់ស្កាត់ជំងឺនេះកុំឲ្យវិវឌ្ឍន៍ទៅជាធ្ងន់ធ្ងរ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្លាំងដល់ខាងក្រុមគ្រូពេទ្យ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ សូមជួបតែសំណាងល្អ និងសុខភាពល្អទាំងអស់គ្នា។

នាងខ្ញុំឈ្មោះ **ហែម គាន់** គឺជាមេភូមិក្រពើពីរក្រោម ខ្ញុំពិតជាមានសេចក្ដីរីករាយជាខ្លាំង ដែលមានក្រុមគ្រូពេទ្យបានមកពិនិត្យសុខភាពប្រជាជនក្នុងភូមិខ្ញុំ។ ប្រជាជនក្នុងភូមិខ្ញុំមិនដែលបានពិនិត្យសុខភាពជុំគ្នាច្រើនបែបនេះទេ វាជាការជួបជុំដ៏ល្អមួយក្នុងយល់ដឹងពីសុខភាព ហើយក៏មានការណែនាំពីក្រុមគ្រូពេទ្យ។ ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានចុះមកសម្ភាសន៍ប្រជាជនក្នុងភូមិខ្ញុំ ហើយប្រជាជនទទួលបានការពិនិត្យសុខភាព។ ខ្ញុំសូមជូនពរមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យទទួលជោគជ័យជារៀងរហូត។

ខ្ញុំឈ្មោះ **តែម អ៊ីប** គឺជាអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិសំរោង២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយក្រោយពីបានចូលរួមពិនិត្យសុខភាព ព្រោះបានក្រុមគ្រូពេទ្យយកចិត្តទុកដាក់ណែនាំពីសុខភាព និងដឹងពីបញ្ហាសុខភាព ឬលើសសម្ពាធឡើង។ ក្រុមការងារមានទំនាក់ទំនងល្អជាមួយអ្នកភូមិ ព្រមទាំងបានជជែកពីរឿងសុខភាព និងរំឭកពីរឿងរ៉ាវដែលបានឆ្លងកាត់ក្នុងសម័យខ្មែរក្រហមជាមួយអ្នកភូមិផ្សេងទៀត។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានឲ្យគ្រូពេទ្យចុះមកពិនិត្យសុខភាពជូនអ្នកភូមិរបស់ខ្ញុំ។





ចន្លោះពីថ្ងៃទី១៦ ដល់ ទី១៧ ខែមករា ឆ្នាំ២០២៤ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំពិនិត្យសុខភាពបឋមជូនព្រះសង្ឃ ជនពិការ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន២២០នាក់ នៅភូមិចំនួន៣ គឺភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង និងភូមិសំរោងទី២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម

ហង្ស ឆាំឆាន


ហង្ស ឆាំឆាន ពេលបួសជាព្រះសង្ឃ។

## ១. សភាពការណ៍ថ្ងៃ១៧ មេសា ១៩៧៥ នៅទីក្រុងភ្នំពេញ

ខ្ញុំគឺជាសមណនិស្សិតម្នាក់ស្នាក់នៅកុដិលេខ១១ វត្តលង្កា ក្រុងភ្នំពេញ។ ជារៀងរាល់ឆ្នាំ ចាប់ពីក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ មកដោយពុំមានឪពុកម្តាយផ្គត់ផ្គង់ ខែនេះ គឺជាវិស្សមកាលនៃការរៀនសូត្ររបស់ព្រះសង្ឃ ខ្ញុំតែងតែចេញទៅសុំស្នាក់នៅតាមវត្តក្រៅក្រុងដែលខ្ញុំស្គាល់ ដើម្បីសុំអង្ករពីលោកគ្រូចៅអធិការយកមកទុកផ្គត់ផ្គង់ក្នុងពេលសិក្សា។ ដោយឡែកឆ្នាំនេះ ខ្មែរក្រហមវាយមកគ្រប់ទិសនៃទីក្រុងភ្នំពេញ ខ្ញុំពុំអាចចេញទៅក្រៅក្រុងឡើយ។ ល្ងាចថ្ងៃទី១៦ ខែមេសា មានទាហានបាក់ទ័ពជាច្រើននាក់រត់ចូលមកលាក់ខ្លួន និងដេកនៅគ្រប់កន្លែងក្នុងវត្ត ក្នុងចំណោមនោះក៏មានអ្នកដែលធ្លាប់របួសរស់នៅក្នុងវត្តលង្កា នេះខ្លះដែលខ្ញុំបានស្គាល់ដែរ។

### ១.១. ការផ្ទុះអាវុធយ៉ាងខ្លាំងនៅលើ និងជុំវិញវិមានឯករាជ្យ

ម៉ោងប្រហែល៨ព្រឹក ខ្ញុំបានឃើញក្មេងៗកូនសិស្សលោកក្នុងកុដិខ្ញុំរត់មកយកទៃដាក់អង្ករពណ៌សចង់នឹងឈើគ្រវីស្វាគមន៍ទ័ពរំដោះ ដែលកំពុងជិះលើរថក្រោះហែមកពីទិសខាងលិចចូលមកចាប់ដៃគ្នានៅជុំវិញវិមានឯករាជ្យផ្នែកខាងក្រោម ជាមួយកងទ័ពរំដោះមួយក្រុម ទៀតមកពីទិសខាងត្បូង។ ខ្ញុំក៏បានចេញទៅមើលនឹងគេដែរ។ ដោយសប្បាយរីករាយបំផុត តែបន្តិចក្រោយមកនៅផ្នែកខាងលើជុំវិញវិមានឯករាជ្យ មានក្រុមអាវុធហត្ថប្រហែល៤ទៅ៥នាក់ មានម្នាក់កាន់ក្បាលមេក្រូនិយាយយ៉ាងច្បាស់ថា នេះហើយជាការរួបរួមគ្នាបញ្ចប់សង្គ្រាមរវាងខ្មែរនិងខ្មែរដូចគ្នា។ និយាយស្ទើរមិនទាន់ចប់ផង កងទ័ពរំដោះមួយក្រុមហក់ឡើងទៅកញ្ឆក់មេក្រូ រួចបាញ់អាវុធហត្ថនោះដួលនៅហ្នឹងកន្លែង។ ឃើញគ្នាគេដួល ទាហាន លន់ នល់ នៅលើកុដិលេខ១៣ ដែលគេហាក់ត្រៀមទុកជាមុនស្រេច បានបាញ់កាំភ្លើងម៉ាស៊ីនជាច្រើនគ្រាប់ទៅរកពួកខ្មែរក្រហមនៅវិមានឯករាជ្យ។ ឆាកប្រយុទ្ធគ្នាក៏បានចាប់ផ្តើម ខ្ញុំនិងអ្នកដទៃទៀត មានទាំងឧបាសក បានរត់ចូលកន្លែងលាក់ខ្លួន។ រំពេចនោះ ខ្មែរក្រហមបាញ់បេ៤០ ជាច្រើនគ្រាប់បញ្ចោះកុដិលេខ១៤ និងកុដិលេខ១៥ ធ្វើឲ្យកុដិទាំងនោះឆេះសន្ធោឡើងព្រមគ្នា រួចក៏បាញ់នៅមុខគ្រប់កុដិលោកឲ្យមនុស្សចេញ។ ខ្ញុំជាមួយសិស្សខ្ញុំ២នាក់ និងអ្នកផ្សេងទៀតបានរត់ចេញតាមទ្វារខាងត្បូងវត្តទៅទិសខាងលិច។

### ១.២. ការបាញ់សម្លាប់ទាហានក្នុងវិទ្យាល័យបឹងត្របែក

យើងខ្ញុំទាំង៣នាក់ បានរត់កាត់គ្រាប់ដែលខ្មែរក្រហមបាញ់តាមបណ្តោយផ្លូវ និងតាមមុខផ្ទះជាច្រើន ពួកទាហានឈុតខ្មៅជាក្រុមៗ បានឈរបាញ់ដេញប្រជាជនតាមផ្ទះឲ្យចេញៗ។ ម៉ោងប្រហែល១២ ខ្ញុំទៅដល់ស្តុបបូកគោ បម្រុងរត់ចេញទៅលិចបន្តទៀត តែមានយុទ្ធនារីខ្មែរក្រហមលើកកាំភ្លើងភ្ជង់ឲ្យទៅទិសខាងត្បូង និងចេញទៅតាមតាខ្មៅ។ នៅតាមបណ្តោយផ្លូវមុន្នីវង្សពីស្តុបបូកគោទៅដល់ក្បាលថ្នល់ ពួកខ្ញុំ ពុំហ៊ានចេញដើរបានលឿនទេ ព្រោះនៅកន្លែងនេះពួកខ្មែរក្រហមបានភ្ជង់ចាប់ជនណាដែលស្លៀកពាក់ជាទាហាន លន់ នល់ ឲ្យស្រាតខោអាវចេញទាំងអស់ទុកតែខោស្លីប រួចចងស្លាបសេកបណ្តើរចូលទៅក្នុងបរិវេណវិទ្យាល័យ បឹងត្របែក (មុំកូនត្នោតច្រើន) ពេលទៅដល់ទីនោះព្រុស្នូរកាំភ្លើងផ្ទុះ ដែលយើងខ្ញុំសន្មតថាពួកទាហានទាំងនោះត្រូវបានគេបាញ់សម្លាប់។ ម៉ោង៣ យើងខ្ញុំបានទៅដល់រង្វង់មូលក្បាលថ្នល់ ដើរតម្រង់ទៅតាខ្មៅ តែទ័ពអាវខ្មៅចង្អុលឲ្យទៅទិសខាងកើតវិញ។ នៅតាមបណ្តោយផ្លូវជាតិលេខ១១ រហូតដល់ខាងលិចវត្តវាលស្បូវ មានផ្ទះ២ខ្នងដែលម្ចាស់រត់ចោល

អស់ នៅម៉ោង៥ល្ងាច ក៏សម្រេចចិត្តស្នាក់នៅទីនោះរង់ចាំថ្ងៃអង្គការឲ្យត្រឡប់ចូលទីក្រុងភ្នំពេញវិញ។ នៅតាមបណ្តោយផ្លូវមានខ្មោចជាច្រើនដែលគេទើបនឹងសម្លាប់ក្នុងពេលថ្មីៗ ខ្លះកំពុងដកចង្កាមាន់មិនទាន់ស្លាប់ទេ។

## ១.៣. ការប្រជ្រៀតគ្នាចេញពីភ្នំពេញទៅតាមផ្លូវជាតិលេខ១

ពេលយើងខ្ញុំឡើងស្នាក់នៅលើផ្ទះទាំងពីរបានប្រហែលមួយម៉ោងក្រោយមក ប្រជាជនជាច្រើននាក់បានមកបន្តគ្នាកាន់តែច្រើនឡើងៗណែនណាន់តាន់តាប់ពេញផ្លូវ ខ្លះមកសុំជ្រកក្រោមផ្ទះខ្ញុំស្នាក់នៅ ខ្លះដេកលើថ្នល់ អ្នកមានឡានដេកក្នុងឡានលើថ្នល់ ខ្លះចូលទៅបោះតង់ជ្រកក្រោមដើមល្មុតដែលគ្មានម្ចាស់ រហូតដល់ម៉ោង៩ ទើបគេបិទចរាចរលែងឲ្យដើរ ម្នាក់ៗនាំគ្នាសម្ងំសម្រាករៀងៗខ្លួន នៅតែសំឡេងអ្នកបាត់កូនចៅវង្វេងគ្នាទេ ដែលស្រែកដង្ហោយហៅឈ្មោះកូន ចៅ ជាបន្តបន្ទាប់។

## ១.៤. ការរង់ចាំចូលភ្នំពេញវិញ

ដោយម្នាក់ៗទទួលដំណឹងដូចគ្នាថា អង្គការឲ្យចេញពីភ្នំពេញតែរយៈពេល៣ថ្ងៃចូលវិញ ម្ល៉ោះហើយយើងទាំងអស់គ្នាមិនហ៊ានទៅណាឆ្ងាយទេ ខ្លាចលំបាកដល់ពេលចូលក្រុងវិញ។ ដូច្នេះមានតែប្រជ្រៀតគ្នានៅជិតក្រុងរង់ចាំស្តាប់ព័ត៌មាន២ ឬ៣ថ្ងៃ រហូតដល់១អាទិត្យ ឬ២អាទិត្យ នៅតែគ្មានដំណឹង។ ផ្ទះដែលយើងខ្ញុំនៅមានគ្នាជាង៣០នាក់ ដោយខ្វះស្បៀងក៏ដាច់ចិត្តបែកផ្លូវគ្នារៀងៗខ្លួន។ ខ្ញុំសម្រេចចិត្តទៅស្រុកកំណើតដោយដើរទៅ ពិភាក្សាជាមួយមិត្តភក្តិ បងប្អូន ថាបើខ្ញុំទៅស្រុកកំណើត គួរទៅទាំងសង្ឃ ឬចាកសិក្ខាបទ? មតិភាគច្រើនគឺកុំសឹក បើសឹកគេអាចចោទថា យើងធ្លាប់ធ្វើទាហាន ប៉ូលិស ប៉េអឹម។ ជាពិសេសបង សឿង ញាណ ជីទួតមួយខ្ញុំដែលគាត់ជាអ្នកជួយផ្គត់ផ្គង់ខ្ញុំឲ្យរៀនបន្តរយៈពេល៥ឆ្នាំថា លោកប្អូនត្រូវទៅដល់ផ្ទះទាំងសង្ឃកុំសឹកឲ្យសោះណា លោកប្អូន ខ្ញុំក៏លាគ្រួសារបង សឿង ញាណ និងបងៗប្អូនផ្សេងទៀតរួចចេញដំណើរពីផ្សារគគីរទៅរកស្រុកកំណើត នៅស្រុកព្រះស្តេច ខេត្តព្រៃវែង។

## ១.៥. ពាសនាខ្ពស់ ខ្ញុំបានប្អូនជួយសង្គ្រោះជីវិត

រយៈពេល២ថ្ងៃ ខ្ញុំបានដើរទៅឆ្លងកាណូតដល់ត្រើយខាងកើតទន្លេអ្នកលឿង នៅម៉ោង៦ល្ងាច កំពុងតែឈរគិតថា តើត្រូវរកកន្លែងសម្រាកសិនឬក៏ទៅមុខស្រាប់តែឮសូរសំឡេង «លោកបង» ខ្ញុំក្រឡេកទៅរកសំឡេងហៅ ឃើញប្អូនឈ្មោះ ជា ត្រស់ ជាប្អូនជីទួតមួយខ្ញុំ និងពូរបស់ខ្ញុំ៣នាក់ទៀតបណ្តើរកង់មករកខ្ញុំ។ ពួកយើងមិនទាន់ទាំងបាននិយាយអ្វីផង ប្អូនត្រស់ ក៏និយាយទាំងបង្ខំថា និមន្តឡើងកង់កូរណាមក តោះយើងប្រញាប់ទៅយប់ហើយ។ ចាប់ឡើងកង់ភ្លាមប្អូនត្រស់ ក៏បោះពួយយ៉ាងលឿនហាក់ដូចជាប្រញាប់ណាស់ ខ្ញុំក៏មិនបាននិយាយអ្វីច្រើនដែរ ព្រោះមិនដឹងរឿង។ តាមពិតប្អូនខ្ញុំបានដឹងរឿងច្រើន ដែលពួកកម្មាភិបាលខ្មែរក្រហមបានវាយប្រហារ និងមូលបង្កាច់មកលើរូបខ្ញុំ និងមានអ្នកកំពុងរង់ចាំស្ទាក់ផ្លូវយកខ្ញុំទៅបាញ់ចោលនៅស្ពានស្ទឹងស្លូតទៀតផង។ ម៉ោងប្រហែលជាង១០យប់ ពួកយើងបានទៅដល់ផ្ទះកំណើតខ្ញុំដូចបំណង គេដេកលក់អស់ហើយ ម្តាយខ្ញុំពេលដឹងថា ខ្ញុំមកហើយគាត់ស្ទើរលោតពីលើផ្ទះចុះមកឱបខ្ញុំយំហើយនិយាយថា «កូនម៉ែអាយុថ្ងៃណាស់ គេប្រាប់ថា កូនងាប់ហើយ ដោយគេបាញ់ទម្លាក់ពីយន្តហោះ២នាក់ កូនសៅ» កូនសៅ គឺជាបងជីដូនមួយខ្ញុំឈ្មោះ ម៉ុក សៅ គាត់នៅរៀនជាសមណនិស្សិតស្នាក់នៅកុដិជាមួយខ្ញុំ តែក្រោយមកគាត់ចូលរៀនជានិស្សិតនាយទាហានសកម្មជនទី៣១ នៅសាលានាយទាហានកំពង់ឆ្នាំង និងបានទៅកាន់កងអនុសេនាតូចនៅព្រៃវែង ក្រោយបែកព្រៃវែង គេយកគាត់ទៅសម្លាប់នៅគុកព្រៃប្រង់ស្រុកបាភ្នំ។ ឪពុកខ្ញុំក៏នាំខ្ញុំ និងអ្នកម្តាយឡើងលើផ្ទះ ហើយហាមកុំឲ្យនិយាយឮៗពេក នាំគ្នាសម្រាកទៅ ចាំជិតភ្លឺសឹមនិយាយគ្នាទៀត។

## ១.៦. ដំបូន្មានឪពុក

ពេលទៅដល់ភូមិពូៗ៣នាក់ ក៏ចូលទៅផ្ទះរៀងៗខ្លួន នៅសល់តែប្អូនត្រស់ បានលាយើងខ្ញុំក្រោយគេ។ នៅយប់នោះអ្នកម្តាយ និងលោកឪពុកខ្ញុំមកសម្រាន្តអមខ្ញុំទាំងសងខាង ជជែកគ្នាខ្សឹបៗ និងប្រាប់ឲ្យប្អូនស្រីខ្ញុំទៅអង្គុយក្រោមផ្ទះចាំមើល ក្រែងមានគេមកលបស្តាប់។ ឪពុកខ្ញុំរយៈពេល៥ឆ្នាំនេះ គាត់ត្រូវបានខ្មែរក្រហមយកទៅរៀនសូត្រ៣ដងហើយ តែរយៈពេលខ្លីៗលើកទី១មួយខែដោយសារប្រកែកមិនព្រមវិភាគទានឲ្យដីទៅអង្គការស្នើសុំ។ ទី២ រយៈពេលបីខែ រឿងស្នើសុំដីទាំងអស់ទុកតែ៤ហិកតាល្មមនឹងកម្លាំងគ្រួសារនេះធ្វើបានហើយ និងទី៣ រឿងគប់កូនគោ គេងាប់ក៏បីខែដែរ។ ពេលនោះម្នាក់ៗក្នុងផ្ទះខ្ញុំគ្មានអ្នកណាមួយដេកលក់ទេ លោកឪពុក បានសួរពីរយៈពេលរៀន៥ឆ្នាំមានបញ្ហាអ្វីខ្លះ? ខ្ញុំឆ្លើយថា មិនជាលំបាកណាស់ណាទេ ព្រោះមានគេជួយខ្ញុំរហូតដល់រៀនចប់ តែអ្វីដែលគាត់ចាប់អារម្មណ៍នោះគឺឆាយាបួសជាភិក្ខុមានហត្ថលេខា និងត្រាសម្តេចព្រះសង្ឃរាជ ហួត តាត ជាឧបជ្ឈាយ៍ខ្ញុំនិងកាតកូនសិស្សគាត់ថា បើពួកវាដឹង កូនមិនអាចនៅរស់ទេ កុំស្តាយ មកសូមខមាទោស ហើយដុតចោលឥឡូវទៅកូន។ ក្រៅពីនេះ កូនត្រូវដាំដើមគ កុំអួត កុំធ្វើចេះ ចង់អ្នកណាសួរក៏ដោយ កុំនិយាយថាខ្លួនចេះធ្វើជាល្ងង់ទើបរស់កូន។

រូបក្របមុខ ៖
ប្រជាជនកម្ពុជាលើកបង្ហាញមេដឹកនាំ និងរបបដឹកនាំថ្មី បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖
ប្រជាជនកម្ពុជាអបអរសាទររបបដឹកនាំថ្មី សាធារណរដ្ឋប្រជាមានិតកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 289, January 2024 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.